ISSN 1560-7615 / ISBN 978-99950-52-06-5

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៧ លេខ ១ ខែមីនា ឆ្នាំ២០១៣ តម្លៃ ១.៥០០រ

# ការពង្រឹងអនាគតប្រទេសកម្ពុជា៖ និន្នាការ និងអាទិភាពគោលនយោបាយ ទទួលបានពីសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៣[១]

សន្និសីទ ចក្ខុវិស័យប្រទេសកម្ពុជាប្រចាំឆ្នាំលើកទី៧ ដែលជាកិច្ចសហការជាដៃគូរវាងវិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal បានប្រារព្ធឡើងនៅថ្ងៃទី២០ កុម្ភៈ ២០១២ នៅរាជធានីភ្នំពេញ។ ថ្នាក់ដឹកនាំមកពីខាង រដ្ឋាភិបាល វិស័យឯកជន ដៃគូអភិវឌ្ឍន៍ សហគមន៍ស្រាវជ្រាវ និង អង្គការមិនមែនរដ្ឋាភិបាល (NGOs) បានមកជួបប្រជុំពិភាក្សាគ្នា ក្រោមប្រធានបទ "ការពង្រឹងអនាគតប្រទេសកម្ពុជា - ស្បៀងអាហារ ថាមពល និងធនធានធម្មជាតិ"។ ក្នុងពេលថ្លែងសុន្ទរកថាបើកសន្និសីទ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកសរសើរ វិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal ដែលមានកិច្ចសហការជាដៃគូរយៈពេលវែងប្រកបដោយជោគជ័យ និងបានគូសបញ្ជាក់ពី តួនាទីដ៏សំខាន់របស់សន្និសីទក្នុងការផ្តល់ព័ត៌មានដល់រដ្ឋាភិបាលអំពី វិស័យនានាដែលទាមទារនូវសកម្មភាពខាងគោលនយោបាយ។

អត្ថបទនេះបង្ហាញត្រួសៗពីវគ្គនានាក្នុងសន្និសីទ និងបញ្ហាចម្បងៗទាក់ទងនឹងកំណើនមានចីរភាព និងសម្រាប់គ្រប់គ្នានៅកម្ពុជា។ ផ្នែកទី១ ពិនិត្យពីសូចនាករម៉ាក្រូសេដ្ឋកិច្ចដ៏រឹងមាំរបស់កម្ពុជា និងទទួលស្គាល់ពីតម្រូវការបន្តអនុវត្តគំរូអភិវឌ្ឍន៍សម្រាប់គ្រប់គ្នាឲ្យបានកាន់តែប្រសើរ។ ផ្នែកទី២ បំផុសឲ្យឃើញថា កសិកម្មជាប្រភពដ៏សំខាន់មួយនៃកំណើនសម្រាប់គ្រប់គ្នា និងលើកឡើងនូវគោលនយោបាយដើម្បីបង្កើនប្រសិទ្ធភាព និងសមធម៌ក្នុងវិស័យនេះ។ ផ្នែកទី៣ ពិភាក្សាពីការផ្លាស់ប្តូរត្រូវធ្វើឡើងដើម្បីជំរុញកម្ពុជាឲ្យឈានឡើង និងចូលក្នុងក្រុមប្រទេសមានចំណូលមធ្យម ដោយផ្តោតលើថាមពល និងការដឹកជញ្ជូន ហើយផ្នែកចុងក្រោយបង្ហាញថា តើកម្ពុជាគួរអនុវត្តគោលនយោបាយយ៉ាងណា ដើម្បីទទួលផលចំណេញពីការរីកលូតលាស់នៅអាស៊ី។



ឯ.ឧ. បណ្ឌិត សុក ស៊ីផាន់ណា ប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថាន CDRI ថ្លែងសុន្ទរកថាស្វាគមន៍ក្នុងពិធីបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ នៃសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ។

## កំណើនខ្ពស់ ប៉ុន្តែមិនសម្រាប់គ្រប់គ្នា

កំណើនសេដ្ឋកិច្ចកម្ពុជា ដែលគេបានគន់គូរឡើងវិញនាពេលថ្មីៗដំឡើងដល់ ៧,៧% នៅតែរឹងមាំដដែល សម្រាប់ឆ្នាំ២០១២។ កម្ពុជាសម្រេចបានកំណើនស្ទើរក្នុងគ្រប់វិស័យនៃសេដ្ឋកិច្ច ក្នុងនេះវិស័យកសិកម្ម កើន ៤,៣% ដោយទទួលបានអត្ថប្រយោជន៍ពីគំនិតផ្តួចផ្តើមពាណិជ្ជកម្ម "ទំនិញគ្រប់មុខក្រៅពីអាវុធ" របស់

## មាតិកា

ការពង្រឹងអនាគតប្រទេសកម្ពុជា៖ និន្នាការ និងអាទិភាពគោលនយោបាយ ទទួលបានពីសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៣ ........ ១
ការលើកកម្ពស់ពាណិជ្ជកម្មដើម្បីកំណើនសេដ្ឋកិច្ចនៅកម្ពុជា .... ៨
វិសមភាពយេនឌ័រក្នុងវិស័យកសិកម្ម៖ អង្កេតគ្រួសារសមាជិកអង្គការកសិករក្នុងបួនខេត្ត ........ ១៣
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ........ ១៨
— ស្ថានភាពក្នុងប្រទេស ........ ២០
— សូចនាករ ........ ២២
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ........ ២៨

[១] រៀបរៀងដោយ Benjamin C. R. Flower, គឹម សួ, រ័ត្ន វឌ្ឍនា និង ស៊ុំ ស្រីមុំ នៃវិទ្យាស្ថាន CDRI។ បទបង្ហាញនានានៅក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាមានចុះក្នុងគេហទំព័ររបស់វិទ្យាស្ថាន CDRI៖ www.cdri.org.kh ។

សហភាពអឺរ៉ុប និងកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការជំរុញពាណិជ្ជកម្មស្រូវអង្ករ និងកៅស៊ូ។ ជាលទ្ធផល ការនាំចេញអង្ករកើនដល់ ១៨០.០០០តោន ក្នុងឆ្នាំ២០១១ និង ២០៧.១៦៨តោន ក្នុងឆ្នាំ២០១២ ហើយក្នុងនោះមានជាង ៨០% បាននាំចេញទៅអឺរ៉ុប។ វិស័យឧស្សាហកម្ម កើន ៩,២% ដោយមានការនាំចេញសម្លៀកបំពាក់ទៅសហភាពអឺរ៉ុប កើនពី ២៣% ដល់ ៣០% នៃការនាំចេញសរុប ដែលជាលទ្ធផលនៃគំនិតផ្តួចផ្តើមពាណិជ្ជកម្ម "ទំនិញគ្រប់មុខក្រៅពីអាវុធ"នោះដែរ។វិស័យសេវាកម្មកើន៨,១% ដោយមានភ្ញៀវទេសចរកើនឡើង ២៤,៤% ធៀបនឹងមួយឆ្នាំមុន ដល់ជាង ៣,៥លាននាក់ ដែលផ្តល់ចំណូលបានប្រមាណ ២ពាន់លានដុល្លារ ដល់សេដ្ឋកិច្ចកម្ពុជា។ បន្ទាប់ពីបានរួមចុះយ៉ាងខ្លាំងក្នុងពេលមានវិបត្តិហិរញ្ញវត្ថុ វិស័យសំណង់កំពុងបន្តរើបឡើងវិញ ដោយមានសញ្ញាបង្ហាញពីលទ្ធផលរឹងមាំក្នុងឆ្នាំ២០១២ ទោះបីមិនទាន់មានតួលេខច្បាស់លាស់ក្តី។

ក្នុងវិស័យនីមួយៗ គេឃើញមានសញ្ញានៃពិពិធកម្មឈានទៅកាន់សកម្មភាពសេដ្ឋកិច្ចមានតម្លៃបន្ថែមខ្ពស់ និងទៅកាន់ប្រភពកំណើនថ្មីៗទៀត។ ក្នុងវិស័យកសិកម្ម កំណែទម្រង់ដ៏សំខាន់ផ្នែកជលផល ដើម្បីបង្កើតនូវសហគមន៍នេសាទថ្មីៗ បានចាប់ផ្តើមចេញជាផ្លែផ្កា ដោយផលិតផលនៃអនុវិស័យជលផលកើនឡើង ៦,៧% ក្នុងឆ្នាំ២០១២។ មានសញ្ញាបង្ហាញថា វិស័យទេសចរណ៍កំពុងធ្វើពិពិធកម្មទៅខាងផ្នែកឆ្នេរសមុទ្រ និងអេកូទេសចរណ៍ ជាពិសេស តាមការអភិវឌ្ឍកោះមួយចំនួននៅកម្ពុជា ដែលបានផ្តល់ឱកាសថ្មីៗសម្រាប់កំណើនក្នុងវិស័យនេះ។ ការជីកយករ៉ែ កំពុងក្លាយជាប្រភពសំខាន់មួយនៃកំណើនសេដ្ឋកិច្ច ចាប់តាំងពីមានការរកឃើញធនធានត្បូងថ្មយ៉ាងច្រើននៅខេត្តក្រចេះ។

កំណើនតាមវិស័យ កន្លងមកអាចសម្រេចបានលើមូលដ្ឋានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងអត្រាអតិផរណាទាប ដែលគេព្យាករណ៍ថា ត្រូវធ្លាក់ចុះទៀតដល់ ២,៩% នៅឆ្នាំ២០១២ ទោះបីមានកំណើនកម្រិតខ្ពស់ក្តី (តារាង១)។ ការប្រមូលចំណូលសម្រេចបានជោគជ័យជាច្រើន ដោយរដ្ឋាភិបាលព្យាយាមបង្កើនធនធានសម្រាប់ផ្នែកសុខាភិបាល អប់រំ និងហេដ្ឋារចនាសម្ព័ន្ធ។ ការប្រមូលចំណូលក្នុងស្រុក ដោយអគ្គនាយកដ្ឋានពន្ធដារ មានកំណើនប៉ាន់ស្មាន ២៧% ដល់ ២៥០១ពាន់លានរៀល (៦២៥លានដុល្លារ) ក្នុងឆ្នាំ២០១២។ នៅក្នុងបរិយាកាសសេដ្ឋកិច្ចអំណោយផលនេះ វិស័យធនាគារកម្ពុជាកាន់តែមានការអភិវឌ្ឍទៅមុខ ដោយប្រាក់បញ្ញើកើន ២៦,២% ពី ៤,៩ពាន់លានដុល្លារ នៅខែធ្នូ ២០១១ ដល់ ៦,២ពាន់លានដុល្លារនៅឆ្នាំ២០១២ ហើយការផ្តល់ឥណទានដល់វិស័យឯកជន ក្នុងឆ្នាំ២០១២ កើន ៣៥,៤% ធៀបនឹងមួយឆ្នាំមុន ដល់ ៥,៩ពាន់លានដុល្លារ។ ប្រាក់បញ្ញើមីក្រូហិរញ្ញវត្ថុ ក៏កើនឡើងជាងមួយជាពីរដែរ ដល់ ២៧៣,៩លានដុល្លារ ក្នុងឆ្នាំ២០១២ រីឯកម្ចីផ្តល់សរុប កើន ៣៧,៩% ដល់ ៨៨៥,៨លានដុល្លារ។

នៅកម្ពុជា ការល្អប្រសើរឡើងនៃសូចនាករអភិវឌ្ឍន៍សម្រាប់គ្រប់គ្នា ដូចជា សម្រាប់ផ្នែកអប់រំ និងការថែទាំសុខភាព វានៅឃើតយ៉ាវជាង ការអភិវឌ្ឍសេដ្ឋកិច្ចដ៏គួរឲ្យស្ញប់ស្ញែងរបស់ខ្លួន។ ការស្រាវជ្រាវជាពេលថ្មីៗ បង្ហាញថា កម្ពុជាមាន សូចនាករ

តារាង១៖ សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ

| (គិតជា % នៃ ផសស បើសិនគ្មានការបញ្ជាក់ផ្សេង) | 2009 | 2010 | 2011 | 2012p |
|---|---|---|---|---|
| ផសស ចារឹក (លានដុល្លារ) | 10400 | 11634 | 12937 | 14231 |
| ផសស ពិត (% នៃកំណើន) | 0.1 | 6.0 | 7.1 | 7.3 |
| - កសិកម្ម | 33.5 | 33.9 | 34.6 | 36.8 |
| - ឧស្សាហកម្ម | 21.7 | 21.9 | 22.1 | 21.9 |
| - សេវាកម្ម | 38.8 | 38.3 | 37.5 | 35.9 |
| ផសស គិតក្នុងមនុស្សម្នាក់ (ដុល្លារ) | 753 | 830 | 911 | 990 |
| អតិផរណា (%) | -0.6 | 4.0 | 5.5 | 2.9 |
| ប្រាក់សន្សំជាតិ (% នៃ ផសស) | 21.1 | 24.7 | 24.4 | 23.7 |
| ចំណូលក្នុងស្រុក | 11.9 | 13.2 | 13.2 | 13.7 |
| ចំណាយថវិកា | 20.5 | 21.3 | 20.7 | 19.0 |
| ឱនភាពសរុប | -6.4 | -8.7 | -7.3 | -5.3 |
| ចំណាយវិនិយោគ | 9.1 | 10.3 | 9.3 | 7.3 |
| វិនិយោគក្នុងស្រុក | 13.4 | 14.1 | 13.7 | 13.3 |
| វិនិយោគឯកជន | 16.6 | 18.2 | 16.8 | 16.7 |

ប្រភព៖ បណ្ឌិត ហង់ ជួន ណារ៉ុន នៅក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៣

ចំណាយប្រើប្រាស់អំណោយផលបង្គួរដល់អ្នកក្រ ប៉ុន្តែនៅយឺតយ៉ាវ ក្នុងការញ៉ាំងឲ្យចំណាយមិនប្រើប្រាស់មានលក្ខណៈសម្រាប់គ្រប់គ្នា។ តួយ៉ាង ក្នុងផ្នែកអប់រំ ប្រជាជនជាច្រើន ជាពិសេសនារី និងអ្នករស់នៅក្នុងគ្រួសារក្រីក្រ មិនមានលទ្ធភាពបង់ថ្លៃសិក្សានៅកម្រិតមធ្យមសិក្សា និងកម្រិតសាកលវិទ្យាល័យឡើយ។ ប្រព័ន្ធថែទាំសុខភាពនៅកម្ពុជា មិនទាន់គ្របដណ្ដប់បានគ្រប់គ្រាន់ដល់គ្រួសារក្រីក្រទេ និងជាឧបសគ្គមួយដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចសម្រាប់គ្រប់គ្នា។ ប្រជាជន ក៏ទទួលរងការប៉ះពាល់ពីអត្រាខ្ពស់នៃវិសមភាពផ្នែកចំណាយប្រើប្រាស់ និងដីធ្លីផងដែរ ទោះជាថ្មីៗនេះ មានភស្តុតាងបង្ហាញពីការធ្លាក់ចុះអត្រា វិសមភាពចំណាយប្រើប្រាស់ ក៏ដោយ។

ការមិនបានដោះស្រាយបញ្ហាដ៏ចម្បងនៃ កំណើនសេដ្ឋកិច្ចសង្គមកិច្ចសម្រាប់គ្រប់គ្នា អាចបង្កការខូចខាតដល់សមិទ្ធផលដែលកម្ពុជាសម្រេចបានដោយលំបាក ក្នុងពីរទសវត្សរ៍កន្លងមកនេះ។ មានការមូលមតិថា វិសមភាពកម្រិតខ្ពស់និងរ៉ាំរ៉ៃក្នុងប្រាក់ចំណូល និងជាពិសេសក្នុងឱកាសរកចំណូល នឹងបង្កអន្តរាយដល់កំណើនមានចីរភាព។ ធ្ងន់ធ្ងរជាងនេះទៀត វិសមភាពអាចបំផ្លាញភាពរួបរួមគ្នាក្នុងសង្គម និងដុតបញ្ឆេះការវឹកវរក្នុងសង្គម។ ដូច្នេះ កម្ពុជាត្រូវតែប្រុងប្រយ័ត្នខ្លាំងចំពោះកម្រិតនៃវិសមភាពក្នុងសង្គម ហើយធានាថា វិបុលភាពបានពីកំណើន ត្រូវបានចែកចាយទៅដល់គ្រប់ផ្នែកនៃសង្គម។

## វិស័យកសិកម្មដើម្បីការអភិវឌ្ឍសម្រាប់គ្រប់គ្នា

ការអភិវឌ្ឍវិស័យកសិកម្ម ជាពិសេសការដាំស្រូវ ជាគន្លឹះនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចសម្រាប់គ្រប់គ្នា និងការកាត់បន្ថយភាពក្រីក្រ។ អនុវិស័យស្នូលនានា (ស្រូវ ដំណាំផ្សេងទៀត ការចិញ្ចឹមសត្វ ការនេសាទ និងរុក្ខាប្រមាញ់) ដើរតួនាទីសំខាន់ណាស់ក្នុងការផ្តល់នូវសន្តិសុខស្បៀង និងជីវភាពរស់នៅល្អប្រសើរសម្រាប់ប្រជាជនភាគច្រើន ដោយផ្តល់ការងារដល់ប្រហែល ៧២% នៃកម្លាំងពលកម្ម រួមទាំងអ្នកក្រមួយភាគធំផង។

ផលិតកម្មកសិកម្ម ត្រូវរារាំងដោយបញ្ហាធាតុចូលកសិកម្មដែលមានតម្លៃថ្លៃ និងគ្មានការត្រួតពិនិត្យត្រឹមត្រូវ។ ករណីសិក្សាមួយក្នុងឆ្នាំ២០១២ រកឃើញថា បទបញ្ញត្តិមិនមានប្រសិទ្ធភាពបានកាត់បន្ថយរបាំងលើការនាំចូល ដែលនាំឲ្យមានការលក់ចែកចាយជីមានគុណភាពទាបៈ ជាក់ស្តែង ប្រហែល ១០% នៃជីនៅក្នុងតំបន់សិក្សា គឺជាផលិតផលក្លែងក្លាយ។ ការប្រើធាតុចូលក្លែងក្លាយ ឬមានការលាយបន្លំ អាចកាត់បន្ថយទិន្នផលដំណាំរហូតដល់ប្រហែល ២៨៥-៣៥០ដុល្លារ ក្នុងមួយកសិដ្ឋានក្នុងមួយឆ្នាំ ហើយវាបានប៉ះទង្គិចធ្ងន់បំផុត ទៅលើជនក្រីក្រខ្លាំង (CEFP 2011: 22)។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) បានប្រឹងប្រែងផ្សព្វផ្សាយនូវ ពូជស្រូវមានទិន្នផលខ្ពស់ក្នុងទូទាំងប្រទេស។ ប៉ុន្តែការបញ្ចុះបញ្ចូលកសិករឲ្យប្រើពូជស្រូវទាំងនេះជាការលំបាក ព្រោះពួកគាត់តែងជ្រើសប្រើប្រាស់ពូជស្រូវមានទីផ្សារស្រាប់ ដូចជា ពូជស្រូវ IR 504 មកពីវៀតណាម ជាដើម។ ម្យ៉ាងទៀត កសិករក៏លំបាកនឹងរកបានគ្រាប់ពូជទាំងនេះដែរ ដោយសារការផ្គត់ផ្គង់នៅខ្វះខាត និងថ្លៃដ៏ខ្ពស់។ ការសិក្សានាពេលថ្មីៗមួយរកឃើញថា ការផ្គត់ផ្គង់គ្រាប់ពូជមានត្រឹម ២០% នៃតម្រូវការប៉ុណ្ណោះ។ គោលនយោបាយទៅថ្ងៃអនាគត ត្រូវផ្តោតលើការលុបបំបាត់ឧបសគ្គរាំងស្ទះការផ្គត់ផ្គង់គ្រាប់ពូជ (CDRI: 2012)។

ឥណទានស្ថិតក្នុងចំណោមធាតុចូលដ៏ថ្លៃៗបំផុតនៃការដាំដុះជាពិសេសសម្រាប់កសិករមានដីតូចៗ ដែលពឹងផ្អែកលើទីផ្សារឥណទានក្រៅផ្លូវការ។ កសិករភាគច្រើនទទួលយកកម្ចីមានការប្រាក់ខ្ពស់ (ប្រហែល ៥% ក្នុងមួយខែ) ពីអ្នកផ្តល់កម្ចីក្រៅផ្លូវការ ព្រោះពួកគាត់អាចរកវាបានយ៉ាងឆាប់ទាន់ពេលត្រូវការ។ ចំពោះសកម្មភាព ស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFI) វិញ ទោះបីវាកើនឡើងក្តី ក៏អត្រាការប្រាក់នៅតែមានកម្រិតខ្ពស់ដល់ប្រហែល ២,៥% ក្នុងមួយខែ ដែលជាបន្ទុកដ៏ធ្ងន់សម្រាប់កសិករមានដីតូចៗ។

ឥណទាន ជី ថ្នាំសម្លាប់សត្វចង្រៃ និងប្រេងឥន្ធនៈ មានថ្លៃខ្ពស់ គួបផ្សំនឹង កង្វះសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម បានធ្វើឲ្យការដាំដំណាំខ្នាតតូចជាច្រើនមិនមានប្រសិទ្ធភាព។ កម្ពុជាត្រូវតែកែលំអ សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម បើសិនចង់ឲ្យវិស័យកសិកម្មកាន់តែមានប្រសិទ្ធភាព និងមានពិពិធកម្មខ្លាំង។ ឧទាហរណ៍ នៅក្នុងផលិតកម្មស្រូវ កសិករត្រូវតែទទួលបានការបណ្តុះបណ្តាលពីវិធីគ្រប់គ្រងសត្វចង្រៃ ការប្រើប្រាស់ជី និងបច្ចេកទេសដាំដុះបែបទំនើបផ្សេងៗ។ ក្នុងកម្មវិធីការចិញ្ចឹមសត្វ គួរបង្កើតគោលនយោបាយជំរុញការចិញ្ចឹមសត្វ កម្មវិធីបង្កាត់ពូជ និងសេវាផ្សព្វផ្សាយបច្ចេកទេសបសុពេទ្យ។

ការស្រាវជ្រាវបង្ហាញថា ការជំរុញការធ្វើកសិកម្មតាមកិច្ចសន្យានៅកម្ពុជា បានដោះស្រាយនូវឧបសគ្គជាច្រើនដែលកសិករតូចតាចត្រូវប្រឈមមុខ។ កសិករជាប់កិច្ចសន្យា ទទួលបានគ្រាប់ពូជមានគុណភាពល្អជាងមុន និងអាចរៀនសូត្របច្ចេកទេសកសិកម្មទំនើបៗ មានលទ្ធភាពទទួលបានឥណទានមានការប្រាក់ទាប និងអាចធ្វើការដោះដូរនៅក្នុងក្របខ័ណ្ឌស្ថាប័ននានាដែលផ្តល់នូវកម្រិតថ្លៃមានសមធម៌ និងតម្រូវការកាន់តែមានស្ថិរភាព។ ប៉ុន្តែការដាំដុះស្រូវតាមកិច្ចសន្យា នៅមានបញ្ហាចោទជាច្រើន។ បញ្ហាចម្បងគឺ អ្នកផ្តល់កិច្ចសន្យាត្រួតត្រាលើដំណើរការផលិតកម្ម ហើយកសិករមានអំណាចតិចតួចណាស់ក្នុងការចរចាលើថ្លៃផលស្រូវ ដោយជាទូទៅ គ្រាន់តែអាចឯកភាព ឬមិនឯកភាពនឹងលក្ខខណ្ឌក្នុងកិច្ចសន្យាប៉ុណ្ណោះ។ លក្ខខណ្ឌមួយចំនួន ស្មុគស្មាញខ្លាំងណាស់ចំពោះកសិករតូចតាច ហើយមានច្រើននាក់បានដកខ្លួនចេញពីគម្រោងចុះកិច្ចសន្យានានា ដោយសារតែកត្តាទាំងនេះ។ ដូច្នេះ គោលនយោបាយទៅអនាគត គួរផ្តោតលើការធ្វើឲ្យកិច្ចព្រមព្រៀងកាន់តែសាមញ្ញឡើង ដើម្បីឲ្យកសិករអាចបញ្ចេញមតិបានកាន់តែច្រើន។

អង្គការកសិករ ជាយន្តការផ្លូវការមួយផ្នែកផលិតកម្មនិងទីផ្សារដែលកំពុងរីកលូតលាស់ សម្រាប់ផ្តល់សិទ្ធិអំណាចដល់កសិករ។ នាបច្ចុប្បន្ន នៅទូទាំងប្រទេសមានដល់ ១៤.០០០ ផលិតករ និងក្រុមអ្នកប្រើប្រាស់ធនធាន ក្នុងនេះមានទាំង ២៤០ សហករណ៍កសិកម្មផង។ អង្គការទាំងនេះធ្វើការជំរុញផលិតភាព

រូបភាព ១៖ ការបែងចែកដីធ្លីនៅកម្ពុជា




ប្រភព៖ បណ្ឌិត ចេង វុទ្ធី នៅក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៣

ដោយជួយឲ្យកសិករមានលទ្ធភាពកាន់តែប្រសើរក្នុងការចរចាថ្លៃសម្រាប់ផលិតផលរបស់ខ្លួន និងដោយជួយផ្សព្វផ្សាយនូវព័ត៌មាន និងបច្ចេកទេសកសិកម្ម។ ទោះយ៉ាងនេះក្តី អង្គការកសិករមិនបានដោះស្រាយបញ្ហាជាមូលដ្ឋានគ្រឹះ គឺលទ្ធភាពរបស់កសិករតូចតាចក្នុងការប្រើប្រាស់ធាតុចូល និងចូលទៅក្នុងទីផ្សារលក់ផលិតផលឡើយ។ ដូច្នេះ ត្រូវមានវិធីសាស្ត្រដោះស្រាយកាន់តែទាំងមូលឡើង ដើម្បីតភ្ជាប់អង្គការកសិករ ទៅនឹងការធ្វើកសិកម្មតាមកិច្ចសន្យា និងដើម្បីដោះស្រាយឧបសគ្គជាច្រើនដែលរារាំងវិនិយោគរបស់កសិករតូចតាច។

សមត្ថភាពទាបនៃស្ថាប័នអភិបាលកិច្ចដី ជាឧបសគ្គចម្បងមួយដល់ការអភិវឌ្ឍវិស័យកសិកម្ម និងជាប្រភពមួយនៃការផាត់ចេញពីផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច។ បញ្ហានេះបណ្តាលឲ្យមានការបែងចែកដីកសិកម្មមិនមានសមធម៌នៅកម្ពុជាដែលជះឥទ្ធិពលអវិជ្ជមាន ទាំងទៅលើប្រសិទ្ធភាពផលិតកម្ម និងលើសមធម៌នៅចំពោះមុខភាពក្រីក្រ។ រូបភាព ១ បង្ហាញថា ក្នុងទសវត្សរ៍កន្លងទៅនេះ គ្រួសារនៅជនបទដែលគ្មានដីធ្លី មានពី ១៥% ទៅ ២០% ហើយអ្នកមានដីតិចជាងមួយហិកតា មានប្រហែល ៤០%។ ក្នុងករណីជាច្រើន ពួកគាត់មានលទ្ធភាពត្រឹមការធ្វើកសិកម្មចិញ្ចឹមពោះប៉ុណ្ណោះ ដោយសារតែបញ្ហាកង្វះទ្រព្យធន។ ក្រុមគ្រួសារកសិករភាគច្រើន មិនអាចបង្កើតនូវអតិរេកផលដំណាំដែលរួមចំណែកនាំឲ្យមានការរីកលូតលាស់នោះទេ ហើយពួកគាត់ត្រូវជាប់គាំងនៅក្នុងវដ្តនៃភាពក្រីក្រជាប់រហូត។

ស្ថាប័នអភិបាលកិច្ចដីរបស់រដ្ឋាភិបាល គឺជាដើមហេតុ និងជាដំណោះស្រាយដ៏មានសក្តានុពល នៃការបែងចែកដីមិនមានសមធម៌។ ម្យ៉ាងវិញទៀត សម្បទានដីសេដ្ឋកិច្ច (ELCs) ដែលមិនមានការត្រួតពិនិត្យត្រឹមត្រូវ គេបានប្រើប្រាស់វាជាមធ្យោបាយដកហូតដីពីគ្រួសារតូចតាចងាយរងគ្រោះ ហើយក៏បានរួមចំណែកបង្កជាវិសមភាពដីធ្លី។ ប្រសិនបើមានការត្រួតពិនិត្យត្រឹមត្រូវ ELCs និង សម្បទានដីសង្គមកិច្ច (SLCs) ជាឧបករណ៍ដ៏ខ្លាំងក្លា ដែលរដ្ឋាភិបាលអាចប្រើប្រាស់ដើម្បីបង្កើនប្រសិទ្ធភាព និងសមធម៌នៃការបែងចែកដីកសិកម្ម។ ដោយទទួលស្គាល់នូវចំណុចនេះរដ្ឋាភិបាលបញ្ជាឲ្យធ្វើការត្រួតពិនិត្យឡើងវិញលើដំណើរការបែងចែក ELCs ដែលភាគច្រើនត្រូវបានលុបចោលដោយសារការបំពានលើលក្ខខណ្ឌកិច្ចសន្យា។ ការបែងចែកដីឡើងវិញនេះ កំពុងអនុវត្តហើយ ប៉ុន្តែក្នុងល្បឿនយឺត។ ELCs មានផ្ទៃដីប្រមាណ ១៣៣.០០០ហិកតា ត្រូវបានលុបចោល តាំងពីសម្តេចនាយករដ្ឋមន្ត្រី បានប្រកាសពីនីតិវិធីត្រួតពិនិត្យឡើងវិញឲ្យបានកាន់តែតឹងរ៉ឹង ប៉ុន្តែក្នុងនេះ មានផ្ទៃដីតែ ៤០.០០០ ទៅ ៥០.០០០ហិកតាប៉ុណ្ណោះ ដែលបានបម្រុងទុកសម្រាប់ការបែងចែកឡើងវិញក្នុងលក្ខណៈជាសម្បទានដីសង្គមកិច្ច។

កម្មវិធីចុះបញ្ជីដីធ្លីថ្នាក់ជាតិ ក៏មានបំណងធានាសន្តិសុខដីធ្លីស្របច្បាប់របស់គ្រួសារនៅទូទាំងប្រទេសផងដែរ។ តាមការបញ្ជារបស់សម្តេចនាយករដ្ឋមន្ត្រី កម្មវិធីនេះ ត្រូវបានពង្រីកបន្ថែមនាពេលថ្មីៗ ដើម្បីពន្លឿនការធ្វើប្លង់កម្មសិទ្ធិដីសម្រាប់គ្រួសារមានដីតូចៗនៅទីជនបទ និងបង្កើននូវសន្តិសុខនៃការកាន់កាប់ដីធ្លីរបស់ពួកគាត់។ កិច្ចព្យាយាមទាំងនេះ ត្រូវអនុវត្តប្រកបដោយចីរភាព ប្រសិនកម្ពុជាចង់សម្រេចឲ្យបាននូវ សន្តិសុខដីធ្លីជាលក្ខណៈសាកល ដែលជាមូលដ្ឋានគ្រឹះនៃកំណើនសម្រាប់គ្រប់គ្នា។

ការគ្រប់គ្រងធនធានជលផល និងព្រៃឈើឲ្យមានចីរភាព ក៏កំពុងជួបបញ្ហាមួយចំនួនដែរ។ ជលផលជាអនុវិស័យជំរុញកំណើនសំខាន់មួយ ប៉ុន្តែ ត្រូវធ្វើការត្រួតពិនិត្យឲ្យការនេសាទមានលក្ខណៈស្របច្បាប់ ដើម្បីថែរក្សាស្តុកត្រី និងជីវៈចម្រុះឲ្យ

នៅគង់វង្ស។ គួរធ្វើការស្រាវជ្រាវច្រើនថែមទៀតអំពីស្ដុកត្រី ដើម្បីជួយឲ្យការបែងចែកឡូត៍នេសាទអនុវត្តបានត្រឹមត្រូវ។ ម្យ៉ាងទៀត ត្រូវបង្កើនកិច្ចប្រឹងប្រែងក្នុងការចាត់ថ្នាក់និងកំណត់ព្រំដែនព្រៃឈើ និងការពិនិត្យតាមដានទៅលើការប្រើប្រាស់ធនធានព្រៃឈើ។ ការអភិរក្សជីវៈចម្រុះសំខាន់ខ្លាំងណាស់ ទាំងចំពោះចីរភាពបរិស្ថាន និងចីរភាពនៃការប្រើប្រាស់ព្រៃឈើជាធនធានសេដ្ឋកិច្ច។

## ការធានាឲ្យមានការអភិវឌ្ឍក្នុងរយៈពេលមធ្យមនៅកម្ពុជា

ស្របគ្នានឹងការអភិវឌ្ឍសម្រាប់គ្រប់គ្នា ចំណុចដ៏សំខាន់មួយទៀតដើម្បីឲ្យកម្ពុជារក្សាអត្រាកំណើនខ្ពស់បាន គឺការរៀបចំរចនាសម្ព័ន្ធសេដ្ឋកិច្ចឡើងវិញ ដើម្បីឆ្លើយតបនឹងការផ្លាស់ប្ដូរលក្ខខណ្ឌសេដ្ឋកិច្ចផ្នែកខាងក្នុង និងខាងក្រៅ។ គួរកត់សម្គាល់ថា សេដ្ឋកិច្ចកម្ពុជានឹងផ្លាស់ប្ដូរ នៅពេលកម្ពុជាឈានឡើងជិតដល់ឋានៈជាប្រទេសមានប្រាក់ចំណូលមធ្យម។ ក្នុងនេះក៏មានក្ដីបារម្ភពីគ្រោះថ្នាក់មួយហៅថា "អន្ទាក់នៃភាពជាប្រទេសមានចំណូលមធ្យម" ពោលគឺ ការអភិវឌ្ឍសេដ្ឋកិច្ចត្រូវជាប់គាំង ដោយសារកំណើន ផសស គិតក្នុងមនុស្សម្នាក់ បានកាត់បន្ថយឥទ្ធិពលនៃឧត្តមភាពប្រៀបធៀបដែលជាកត្តាជំរុញដល់ កំណើនខ្ពស់ក្នុងអតីតកាល។ ប្រសិនបើមិនបានទប់ទល់ឥឡូវនេះទេ ឥទ្ធិពលនេះវាអាចបញ្ចប់កំណើនយ៉ាងលឿនក្នុងពេលសព្វថ្ងៃនៃសេដ្ឋកិច្ចកម្ពុជា។

នាបច្ចុប្បន្ន អត្ថប្រយោជន៍ចម្បងមួយដែលទាក់ទាញវិនិយោគ និងធ្វើឲ្យការនាំចេញមានលក្ខណៈប្រកួតប្រជែង គឺពលកម្មមានតម្លៃទាប ប៉ុន្តែអត្ថប្រយោជន៍នេះនឹងត្រូវបាត់បង់នៅពេល ផសស គិតក្នុងមនុស្សម្នាក់ កើនខ្ពស់ឡើង។ ដូច្នេះ កម្លាំងពលកម្មត្រូវតែមានជំនាញសមស្របដើម្បីធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចឲ្យមានលក្ខណៈកាន់តែជឿនលឿន និងមានតម្លៃបន្ថែមខ្ពស់ ទាំងផ្នែកឧស្សាហកម្ម កសិកម្ម និងសេវាកម្ម។ រដ្ឋាភិបាលបាននិងកំពុងជំរុញ កម្មវិធីអប់រំបណ្ដុះបណ្ដាលផ្នែកបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) ដើម្បីបង្កើនកម្រិតជំនាញនៃកម្លាំងពលកម្ម និងគេចផុតពីអន្ទាក់គ្រោះថ្នាក់នៃ ភាពជាប្រទេសមានចំណូលមធ្យម។ កម្មវិធីទាំងនេះត្រូវតែពង្រីកបន្ថែម ដំណាលគ្នានឹងការអនុវត្តនូវ យន្តការផ្នែកស្ថាប័នមួយដែលជំរុញឲ្យរដ្ឋាភិបាលស្ថាប័នអប់រំថ្នាក់ខ្ពស់ និងវិស័យឯកជន ធ្វើការរួមគ្នាសំដៅបង្កើតកម្មវិធីសិក្សាផ្សេងៗដែលពោរពេញដោយថាមពល និងមានភាពបត់បែនល្អ ស្របតាមលក្ខខណ្ឌសេដ្ឋកិច្ចដែលកំពុងផ្លាស់ប្ដូរយ៉ាងលឿន។

ផ្នែកដ៏សំខាន់មួយនៃ យុទ្ធសាស្ត្រសេដ្ឋកិច្ចរយៈពេលមធ្យមរបស់រដ្ឋាភិបាល គឺបង្កើនការនាំចេញអង្ករឲ្យបានច្រើនសន្ធឹកសន្ធាប់ ដើម្បីក្លាយជាប្រទេសនាំអង្ករចេញធំជាងគេទីបី លើពិភពលោក នៅត្រឹមឆ្នាំ២០១៥។ ប៉ុន្តែកម្ពុជាត្រូវដោះស្រាយបញ្ហាជាច្រើន ប្រសិនបើចង់ឲ្យក្ដីបំណងខាងលើក្លាយជាការពិត។ អគ្គិសនីមានតម្លៃខ្ពស់នាំចូលពីប្រទេសថៃ និងវៀតណាមអាចផ្គត់ផ្គង់តម្រូវការថាមពលនៅកម្ពុជាបានប្រមាណ ៤១% ដែលធ្វើឲ្យអ្នកប្រើប្រាស់ប្រឈមមុខនឹង ការបង់ថ្លៃអគ្គិសនីកម្រិតខ្ពស់បំផុតក្នុងតំបន់។ កម្ពុជា ខ្វះខាតហេដ្ឋារចនាសម្ព័ន្ធសម្រាប់បញ្ជូនថាមពលផលិតបានទៅឲ្យប្រជាជន ជាពិសេសអ្នកនៅតាមតំបន់ជនបទ។ នៅឆ្នាំ២០១០ បណ្ដាញអគ្គិសនីផ្គត់ផ្គង់បានត្រឹមតែ ៧% នៃគ្រួសារនៅជនបទ និង ប្រមាណ ១១% នៃតំរូវការថាម

តារាង ២៖ ថ្លៃអគ្គិសនីសម្រាប់រោងម៉ាស៊ីនកិនស្រូវ ក្នុងឆ្នាំ២០១២

| ខេត្ត | ថ្លៃក្នុងមួយគីឡូវ៉ាត់ម៉ោង | |
|---|---|---|
| | ដុល្លារ | រៀល |
| បន្ទាយមានជ័យ | 0.25 | 1000 |
| សៀមរាប | 0.21 | 820 |
| បាត់ដំបង | 0.25 | 1000 |
| ពោធិ៍សាត់ | 0.40 | 1600 |
| ស្វាយរៀង | 0.16 | 650 |
| កណ្ដាល | 0.28 | 1100 |
| កំពង់ចាម | 0.33 | 1300 |
| ព្រៃវែង | 0.26 | 1050 |
| តាកែវ | 0.24 | 950 |

ប្រភព៖ លោក David Van, សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៣

ពលសរុបរបស់ភូមិនានាប៉ុណ្ណោះ។ ថ្លៃអគ្គិសនីក៏ប្រែប្រួលខុសគ្នាខ្លាំងដែរ ទៅតាមតំបន់នានាដែលបានតភ្ជាប់ទៅនឹងបណ្តាញអគ្គិសនី។

ហេដ្ឋារចនាសម្ព័ន្ធថាមពលអន់ខ្សោយ ជះឥទ្ធិពលដោយផ្ទាល់ទៅលើប្រតិបត្តិការកិនស្រូវ ដោយបន្ថែមបន្ទុកចំណាយយ៉ាងច្រើនដល់ផលិតករ។ អង្កេតនៅឆ្នាំ២០១២ ទៅលើរោងម៉ាស៊ីនកិនស្រូវ បានរកឃើញថា ខេត្តពោធិ៍សាត់ដែលនៅឆ្ងាយពីព្រំដែន និងទំនប់វារីអគ្គិសនីជាងគេនោះ មានថ្លៃអគ្គិសនីខ្ពស់បំផុតរហូតដល់ ០,៤០ដុល្លារ/គីឡូវ៉ាត់ម៉ោង រីឯខេត្តស្វាយរៀងដែលស្ថិតនៅជិតព្រំដែនវៀតណាម មានថ្លៃអគ្គិសនីទាបបំផុត ត្រឹមប្រមាណ ០,១៦ដុល្លារ/គីឡូវ៉ាត់ម៉ោង (តារាង ២)។ ភាពខុសគ្នាក្នុងថ្លៃអគ្គិសនី និងបញ្ហាផ្គត់ផ្គង់មិនអាចទុកចិត្តបាន ធ្វើឲ្យអាជីវកម្មជាច្រើន ត្រូវប្រើប្រាស់ប្រភពថាមពលរបស់ខ្លួនផ្ទាល់។ អង្កេតលើ ៩៧រោងម៉ាស៊ីនកិនស្រូវ នៅខេត្តបន្ទាយមានជ័យ សៀមរាប កំពង់ចាម កំពង់ធំ ព្រៃវែង កណ្តាល និងកំពង់ស្ពឺ បង្ហាញថា រោងម៉ាស៊ីនភាគច្រើន (៨៣សហគ្រាស) ប្រើប្រាស់ម៉ាស៊ីនភ្លើងរបស់ខ្លួនផ្ទាល់ដើរដោយប្រេងម៉ាស៊ូត។

ហេដ្ឋារចនាសម្ព័ន្ធរឹងមានសមត្ថភាពទាប ធ្វើឲ្យតម្លៃដឹកជញ្ជូននៅកម្ពុជាស្ថិតក្នុងកម្រិតដ៏ខ្ពស់ៗជាងគេក្នុងតំបន់។ ការដឹកជញ្ជូនតាមផ្លូវគោក ជាមធ្យោបាយដឹកជញ្ជូនចម្បង និងមានតម្លៃជាមធ្យមប្រហែល ១៥-១៧ដុល្លារ/តោន ដែលខ្ពស់ជាខ្លាំង បើធៀបនឹងប្រទេសថៃ និងវៀតណាម នៅជិតខាង។ ប្រាក់កម្រៃផ្លូវការ និងមិនផ្លូវការ ពាក់ព័ន្ធនឹងនីតិវិធីនាំចេញ (ឧទាហរណ៍ ឯកសារគយ, ការត្រួតពិនិត្យអនាម័យ) វាបន្ថែមចំណាយមួយចំនួនទៀតទៅលើបន្ទុកចំណាយនាំចេញ។ ក្នុងករណីការនាំចេញអង្ករ តម្លៃប៉ាន់ស្មានសរុបសម្រាប់រត់ការ វាស្មើនឹងពីរដងនៃកម្រៃផ្លូវការ គឺបូកបន្ថែមប្រហែល ១០ដុល្លារ/តោនទៀត ទៅលើចំណាយសរុប។ យុទ្ធសាស្ត្របច្ចុប្បន្នរបស់រដ្ឋាភិបាល ដើម្បីកែលំអហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ផ្តល់អាទិភាពលើការអភិវឌ្ឍផ្លូវថ្នល់ ផ្លូវដែក និងស្ពាន។ ប៉ុន្តែការដឹកជញ្ជូនតាមទន្លេស្ទឹង ក៏ជាវិធីដឹកជញ្ជូនអាចមានប្រសិទ្ធភាពល្អ និងតម្លៃថោកដែរ។ ឧទាហរណ៍ នៅប្រទេសវៀតណាម ការដឹកជញ្ជូនតាមទន្លេស្ទឹងមានតម្លៃត្រឹមតែ ៣ដុល្លារ/តោន ដែលថោកច្រើនជាងតម្លៃដឹកជញ្ជូនតាមផ្លូវគោកនៅកម្ពុជា។ ថ្វីបើការដឹកជញ្ជូនតាមទន្លេស្ទឹងមានសក្តានុពលខ្លាំងក្តី ក៏កន្លងមកមានការវិនិយោគ និងការចាប់អារម្មណ៍តិចតួចណាស់ពីអ្នកបង្កើតគោលនយោបាយ។

ភាពជាដៃគូរវាងរដ្ឋនិងឯកជន (PPP) អាចគួបផ្សំនូវចំណុចបំពេញឲ្យគ្នាផ្សេងៗរបស់អង្គភាពរដ្ឋ និងឯកជន ដើម្បីធ្វើការកែលំអហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងអគ្គិសនី និងបង្កើនសមត្ថភាពការអប់រំថ្នាក់ខ្ពស់។ PPP មានសារៈសំខាន់ណាស់ចំពោះករណីប្រទេសកម្ពុជា ព្រោះវិស័យសាធារណៈ និងវិស័យឯកជនតែឯកឯង មិនអាចបំពេញតាមតម្រូវការដ៏ច្រើនសម្រាប់កំណើនសេដ្ឋកិច្ចកម្ពុជាឡើយ។ វិនិយោគរបស់រដ្ឋទៅលើហេដ្ឋារចនាសម្ព័ន្ធ មានកម្រិតទាប ដោយសារចំណូលពន្ធដែលមានតិច និងការថយចុះលំហូរចូលនៃជំនួយអភិវឌ្ឍន៍ពីបរទេស (ODA) បានកាត់បន្ថយលទ្ធភាពខាងហិរញ្ញវត្ថុ។ ថ្វីត្បិតបរិយាកាសអាជីវកម្មបានល្អប្រសើរឡើងក្នុងប៉ុន្មានឆ្នាំថ្មីៗ ប៉ុន្តែក្រុមហ៊ុនឯកជននានា ហាក់នៅខ្វះលទ្ធភាពធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ ជាពិសេសក្នុងផ្នែកថាមពល។

ភាពជាដៃគូរវាងរដ្ឋនឹងឯកជន បាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការកែលំអហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងថាមពលនៅកម្ពុជា។ គម្រោងបណ្តាញបញ្ជូនថាមពលអគ្គិសនី រួមមាន ខ្សែបញ្ជូនថាមពលអគ្គិសនីកម្លាំង ១១៥គីឡូវ៉ុល ក្នុងចម្ងាយ ២២១គីឡូម៉ែត្រ ចាប់ពីប៉ោយប៉ែត ទៅដល់ខេត្តសៀមរាប និង បាត់ដំបង ព្រមទាំង អនុស្ថានីយ៍ចែកចាយបន្ត ៣កន្លែង និង ស្ថានីយ៍បិទបើកចរន្ត ១កន្លែង។ ខ្សែបញ្ជូនថាមពលនេះ បញ្ជូនអគ្គិសនីពីប្រទេសថៃ ទៅកាន់ខេត្តសៀមរាប បន្ទាយមានជ័យ និងបាត់ដំបង។ ខាងផ្នែកដឹកជញ្ជូន រដ្ឋាភិបាលបានជួយសម្រួលដល់គម្រោងស្តារជួសជុលផ្លូវដែកមានតម្លៃដល់ ១៤១,៦លានដុល្លារ តាមរយៈការចុះកិច្ចព្រមព្រៀងសម្បទានជាមួយ ប្រតិបត្តិករផ្លូវដែកឯកជន Toll Royal Railway កាលពីខែមិថុនា ២០០៩។ រដ្ឋាភិបាល នៅរក្សាកម្មសិទ្ធិលើផ្លូវដែកដែលមានស្រាប់ និងស្តារជួសជុលឡើងវិញនោះ ហើយក្រុមហ៊ុនសម្បទានិក ត្រូវបង់ថ្លៃសម្បទានទៅឲ្យរដ្ឋាភិបាល។ គួរមានការពង្រីកកម្មវិធីស្រដៀងគ្នានេះ ទៅកាន់វិស័យអប់រំផងដែរ។

ដើម្បីឲ្យភាពជាដៃគូរវាង រដ្ឋនឹងឯកជនអនុវត្តបានសក្តិសិទ្ធិទៅថ្ងៃអនាគត ត្រូវមានក្របខ័ណ្ឌស្ថាប័នរឹងមាំកំណត់នូវ នីតិវិធីអនុវត្តការងារដ៏ល្អប្រសើរ ដែលរួមមាន ការកំណត់ច្បាស់នូវលក្ខណៈវិនិច្ឆ័យនៃលទ្ធផល ការបង់ថ្លៃសេវាកម្ម ការគណនាតម្លៃពេញមួយអាយុកាលនៃគម្រោង ការលៃចែកហានិភ័យឲ្យបានប្រសើរបំផុតរវាងភាគីនីមួយៗ ការដេញថ្លៃមានលក្ខណៈប្រកួតប្រជែង ការប្រើកម្ចីបន្ថែមលើធនធានសាធារណៈ និងការគ្រប់គ្រងទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព។ ការសម្របសម្រួលកាន់តែប្រសើររវាងក្រសួង និងអ្នកពាក់ព័ន្ធនានា គឺសំខាន់បំផុត ហើយអាចសម្រេចបានតាមការកសាង យន្តការអន្តរក្រសួងផ្សេងៗ ដូចជា ភាពជាដៃគូរវាងរដ្ឋនឹងឯកជន អង្គភាពគ្រប់គ្រងហានិភ័យ ជាដើម។ និតិវិធីប្រតិបត្តិការមានតម្លាភាព និងគណនេយ្យភាព សំខាន់ខ្លាំងណាស់ ដើម្បីឆ្លើយតបនឹងការយកចិត្តទុកដាក់នាពេលថ្មីៗទៅលើផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថាន នៃគម្រោង PPP ដូចជា ការផ្លាស់ប្តូរកន្លែងរស់នៅរបស់សហគមន៍ដែលត្រូវរងការប៉ះពាល់ពី គម្រោងកែលំអគុណភាពហេដ្ឋារចនាសម្ព័ន្ធ។ ផលប៉ះពាល់អាចកើតមានឡើងពីគម្រោង គឺត្រូវមានដាក់បញ្ចូលនៅក្នុងប្លង់គម្រោង និងមានការព្យាយាមកាត់បន្ថយវា ជាមួយនឹងការបែងចែកទំនួលខុសត្រូវឲ្យបានច្បាស់លាស់ ក្នុងចំណោមគូភាគីទាំងឡាយ។

## ការធ្វើផែនការសម្រាប់ តំបន់អាស៊ីក្នុងរយៈពេលមួយសតវត្ស

ការផុសឡើងនៃទ្វីបអាស៊ី ជាពិសេសប្រទេសចិន ក្នុងលក្ខណៈជា កម្លាំងចម្បងជំរុញកំណើនសេដ្ឋកិច្ចសាកលនោះ ផ្តល់នូវឱកាសថ្មីៗសម្រាប់អ្នកធ្វើគោលនយោបាយ ក្នុងការជំរុញយុទ្ធសាស្ត្រកំណើនមានចីរភាព និងសម្រាប់គ្រប់គ្នា នៅទូទាំងតំបន់។ ហើយព្រឹត្តិការណ៍ដ៏គួរចាប់អារម្មណ៍បំផុត គឺឱកាសផ្សេងៗដែលទទួលបានពី ការឈានឡើងនៃប្រទេសចិនជាមហាអំណាចខាងសេដ្ឋកិច្ច។ វត្តមានរបស់ចិននៅក្នុងតំបន់ កើនឡើងជាខ្លាំងក្នុងប៉ុន្មានឆ្នាំថ្មីៗ ហើយសព្វថ្ងៃបានក្លាយជាស្នូលនៃបណ្តាញផលិតកម្ម ដោយតភ្ជាប់សមាសភាគផ្សេងៗនៃដំណើរការផលិតកម្មក្នុងតំបន់ ជួយសម្រួលការផ្គត់ផ្គង់ទំនិញទៅទីផ្សារសាកល និងជាប្រភពសំខាន់មួយនៃវិនិយោគផ្ទាល់ពីបរទេស (FDI) ។ សេដ្ឋកិច្ចប្រទេសអាស៊ីជាប់ទាក់ទងគ្នាខ្លាំងណាស់ ជាពិសេសសម្រាប់មហាអនុតំបន់មេគង្គ (GMS) ហើយការផ្លាស់ប្តូរបន្តិចបន្តួចក្នុងកំណើន ផសស នៅចិន អាចមានផលប៉ះពាល់ខ្លាំងទៅលើសេដ្ឋកិច្ចនៅតាមប្រទេសនីមួយៗ។

ប្រសិនបើសេដ្ឋកិច្ចប្រទេសចិនបន្តកើនឡើង ហើយសង្គមមនុស្សនៅចិនកាន់តែសម្បូរទ្រព្យធននោះ ទីផ្សារធំៗនឹងផុសឡើងសម្រាប់ផលិតផលផ្សេងៗរបស់ GMS។ តម្រូវការផលិតផលកសិកម្ម និងទំនិញប្រើបានយូរ បាននិងកំពុងកើនឡើងជាខ្លាំង នៅពេលដែលចំណាយប្រើប្រាស់របស់ប្រជាជនចិនមានការផ្លាស់ប្តូរ។ ដើម្បីឲ្យការអភិវឌ្ឍឧស្សាហកម្មមានចីរភាព និងបានចម្រុះមុខ ចិនត្រូវការជាចាំបាច់នូវ វត្ថុធាតុដើមយ៉ាងច្រើន សន្ទឹកសន្ធាប់ ធនធានរ៉ែ និងថាមពល ហើយ GMS មានស្ថានភាពល្អទាំងផ្នែកភូមិសាស្ត្រ សេដ្ឋកិច្ច និងនយោបាយ ដើម្បីបំពេញតម្រូវការនេះ។

ដោយសារថ្លៃពលកម្មនៅចិន បានកើនឡើងនោះ ឧស្សាហកម្ម នឹងរំកិលទៅរកតំបន់ដែលមានថ្លៃដើមផលិតកម្មទាបជាង។ មហាអនុតំបន់មេគង្គមានស្ថានភាពល្អដើម្បីទទួលយកតួនាទីជាមជ្ឈមណ្ឌលផលិតកម្មសាកល ហើយកំពុងក្លាយជាតំបន់ដែលផលិតកម្មអតិពលកម្មនានាមកប្រមូលផ្តុំគ្នា។

បញ្ហាប្រឈមសម្រាប់អ្នកធ្វើគោលនយោបាយកម្ពុជា គឺការរៀបចំរចនាសម្ព័ន្ធសេដ្ឋកិច្ចឡើងវិញ ដើម្បីចាប់យកឱកាសល្អផុសចេញពីកំណើននៅចិន។ បើសិនប្រើប្រាស់បានសក្តិសិទ្ធិឧបករណ៍ផ្នែកគោលនយោបាយអាចទាញយក ផលប្រយោជន៍ពីបម្រែបម្រួលលំនាំនៃលំហូរមូលធនក្នុងតំបន់ ដើម្បីបង្កើនការងារ បង្កើនផលិតភាពកម្លាំងពលកម្ម បង្កើនការផ្ទេរបច្ចេកវិទ្យាឈានទៅផលិតទំនិញកាន់តែមានតម្លៃខ្ពស់ ហើយសម្រេចបានកំណើន ផសស ខ្ពស់ប្រកបដោយចីរភាព។

អាស៊ានមានកម្លាំងរឹងមាំ ជួយបង្កើនអំណាចចរចារបស់កម្ពុជា និងធ្វើឲ្យសេដ្ឋកិច្ចកម្ពុជា ទទួលបានអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀមអនុគ្រោះផ្នែកពាណិជ្ជកម្ម ជាមួយប្រទេសចិន និងបណ្តាប្រទេសមានសេដ្ឋកិច្ចកំពុងស្ទុះឡើង នៅតំបន់អាស៊ី។ ក្នុងឋានៈជាប្រធានអាស៊ាននៅឆ្នាំ២០១២ កម្ពុជាបានលើកទឹកចិត្តឲ្យប្រទេសជាសមាជិក ដាក់បញ្ចូលនូវកំណែទម្រង់ចាំបាច់នានា ដើម្បីបានចូលទៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននៅឆ្នាំ២០១៥។ ប៉ុន្តែក៏មានគ្រោះថ្នាក់មួយដែរ គឺលទ្ធភាពកំណត់គោលនយោបាយផ្សេងទៀតរបស់កម្ពុជា អាចនឹងត្រូវថយចុះដោយសារកាតព្វកិច្ចផ្សេងៗចំពោះអាស៊ាន។ នេះជាបញ្ហាសំខាន់មួយសម្រាប់កម្ពុជា ដែលមានវិស័យជាច្រើនដើរយឺតជាងប្រទេសជិតខាង ហើយត្រូវមានសកម្មភាពខាងគោលនយោបាយច្បាស់លាស់ និងឥតរារែក។

ចំណុចសំខាន់បំផុតមួយទៀត គឺក្របខ័ណ្ឌគោលនយោបាយនានាត្រូវជួយសម្រួលដល់កំណើនលំហូរវិនិយោគបរទេសនៅក្នុងតំបន់ ហើយក្នុងនេះ ការកែលំអបរិយាកាសអាជីវកម្មនៅកម្ពុជា ជាលក្ខខណ្ឌមួយត្រូវបំពេញឲ្យបានជាមុន។ ឧបសគ្គធំបំផុតក្នុងការបង្កើតបរិយាកាសអំណោយផលដល់ដំណើរការអាជីវកម្ម គឺអំពើពុករលួយ ជាពិសេស នៅពេលវារាំងស្ទះដល់ការដោះស្រាយទំនាស់ និងការពង្រឹងអនុវត្តន៍កិច្ចសន្យា។ ក្នុងរយៈពេលវែង វិនិយោគបរទេសចម្រុះមុខ ទាមទារនូវបរិយាកាសស្ថាប័នមួយដែលលើកកម្ពស់កម្មសិទ្ធិទ្រព្យសម្បត្តិ និងការបែងចែកព័ត៌មានទីផ្សារឲ្យបានស្មើភាព។ សមត្ថភាពស្ថាប័នមានស្រាប់ ត្រូវតែអភិវឌ្ឍបន្ថែម ដើម្បីបំពេញតម្រូវការនេះ។ រដ្ឋាភិបាលត្រូវប្រឹងប្រែងពង្រឹងវិស័យហិរញ្ញវត្ថុ ដើម្បីជួយដល់ដំណើរការរៀបចំសេដ្ឋកិច្ចឡើងវិញនេះ តាមរយៈការពង្រីកឥណទានមានការត្រួតពិនិត្យត្រឹមត្រូវ ទៅឲ្យសហគ្រាសធុនតូច និងមធ្យម។ នៅក្នុងរយៈពេលវែង ការធ្វើបដិដុល្លារូបនីយកម្មក្នុងសេដ្ឋកិច្ច សំខាន់ខ្លាំងណាស់ ចំពោះការអភិវឌ្ឍ និងស្ថិរភាពរយៈពេលវែងនៃវិស័យហិរញ្ញវត្ថុ។ សេដ្ឋកិច្ចចិនកំពុងក្លាយជាកម្លាំងជំរុញធំមួយនៅក្នុងតំបន់ ហេតុនេះរដ្ឋាភិបាលគួរពិចារណាមើលថា តើប្រាក់រ៉េនមិនប៊ី (renminbi) របស់ចិន ងាយស្រួលធ្វើការជាមួយជាង ប្រាក់ដុល្លារអាមេរិក ឬយ៉ាងណា។

## ឯកសារយោង


CEFP –Committee for Economic and Financial Policy (2011), *Review Report on the Implementation of Policy paper on the Promotion of Paddy Production and Rice Export* (Phnom Penh: Ministry of Economy and Finance/ Committee for Economic and Financial Policy)

CDRI–Cambodia Development Resource Institute (2012), “Fertiliser Value Chains in Cambodia: A Case Study in Takeo Province” *Cambodia Development Review,* Volume 16, p 5 – 9 (Phnom Penh: CDRI)

# ការលើកកម្ពស់ពាណិជ្ជកម្មដើម្បីកំណើនសេដ្ឋកិច្ចនៅកម្ពុជា[១]

## សេចក្ដីផ្ដើម

គ្មានប្រទេសណាអាចរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ បានយូរអង្វែង ដោយមិនធ្វើការពង្រីកពាណិជ្ជកម្មឡើយ។ ការបើកចំហចំពោះពាណិជ្ជកម្ម វាជះឥទ្ធិពលទៅលើកំណើនតាមបែបបទជាច្រើនៈ ១) វាធ្វើឲ្យប្រទេសនោះអាចទាញផលចំណេញពីឧត្ដមភាពប្រៀបធៀប និងបង្កើនប្រសិទ្ធភាពនៃការបែងចែកធនធាន ២) វាសម្រួលដល់ការទទួលយកចំណេះដឹង និងបច្ចេកវិជ្ជាពីបរទេស ដែលនឹងជួយបង្កើនផលិតភាព និង ៣) ទាក់ទាញវិនិយោគបានកាន់តែច្រើន ជំរុញការប្រកួតប្រជែង និងកែលំអសមត្ថភាពប្រកួតប្រជែង។ កម្ពុជាបានអនុវត្តតាមគន្លងកំណើននេះ ក្នុងពេលសេដ្ឋកិច្ចកំពុងស្ទុះឡើងក្នុងប៉ុន្មានទសវត្សរ៍កន្លងទៅ ដោយមានការផ្លាស់ប្ដូរដ៏សំខាន់ពី របបពាណិជ្ជកម្មគ្រប់គ្រងជាក់ស្ដែងដោយរដ្ឋ ទៅជា របបពាណិជ្ជកម្មតម្រង់ទិសទៅទីផ្សារខាងក្រៅ។ នៅពេលបច្ចុប្បន្នដែលវិស័យពាណិជ្ជកម្មបានក្លាយជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិនោះ បញ្ហាប្រឈមធំគឺ តើត្រូវធ្វើដូចម្ដេចដើម្បីឲ្យពាណិជ្ជកម្មជួយជំរុញកំណើនសេដ្ឋកិច្ច។ អត្ថបទនេះព្យាយាមឆ្លើយនឹងសំនួរសំខាន់ពីរៈ ១) ហេតុអ្វីពាណិជ្ជកម្មសំខាន់ជាខ្លាំងចំពោះគន្លងកំណើនសេដ្ឋកិច្ចនៅកម្ពុជា? ២) តើត្រូវមានគោលនយោបាយអ្វីខ្លះ ដើម្បីឲ្យពាណិជ្ជកម្មជួយជំរុញកំណើនសេដ្ឋកិច្ចនៅកម្ពុជា?

## ហេតុអ្វីពាណិជ្ជកម្មសំខាន់ជាខ្លាំង ចំពោះគន្លងកំណើនសេដ្ឋកិច្ចនៅកម្ពុជា?

ពាណិជ្ជកម្មនិងគោលនយោបាយពាណិជ្ជកម្មសំខាន់ជាខ្លាំងចំពោះគន្លងកំណើនសេដ្ឋកិច្ចនៅកម្ពុជា ដោយសារហេតុផលធំៗ ៣ គឺៈ ១) ការផ្លាស់ប្ដូរក្នុងគោលនយោបាយពាណិជ្ជកម្ម បានបង្កើតនូវលក្ខខណ្ឌអំណោយផលសម្រាប់យុទ្ធសាស្ត្រពាណិជ្ជកម្មបន្តទៅមុខទៀត ២) ពាណិជ្ជកម្មបានដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការរីកលូតលាស់នាពេលកន្លងមក និង ៣) ទិដ្ឋភាពនៃពាណិជ្ជកម្មអន្តរជាតិកំពុងផ្លាស់ប្ដូរលឿនណាស់ ដែលទាមទារឲ្យមានការកែសម្រួលផ្នែកគោលនយោបាយជាប្រចាំ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមនៃសាកលភាវូបនីយកម្ម។

## ឥទ្ធិពលល្អនៃការវិវត្តក្នុងពេលកន្លងមក

*ការផ្លាស់ប្ដូរគោលនយោបាយពាណិជ្ជកម្មប្រកបដោយជោគជ័យ*

កម្ពុជា បានធ្វើការផ្លាស់ប្ដូរប្រកបដោយជោគជ័យពីសេដ្ឋកិច្ចបែបផែនការប្រមូលផ្ដុំ ទៅជាសេដ្ឋកិច្ចបែបទីផ្សារ ដោយបានបោះបង់នូវរបបសេដ្ឋកិច្ចមួយ ដែលរដ្ឋជាអ្នកត្រួតត្រាយ៉ាងតឹងរ៉ឹងទៅលើថ្លៃ និងបរិមាណទំនិញដែលត្រូវផលិត នាំចូល និងនាំចេញ ហើយមកចាប់អនុវត្តនូវយុទ្ធសាស្ត្រពាណិជ្ជកម្មមួយ ដែលតម្រង់ទិសទៅទីផ្សារខាងក្រៅ។ កំណែទម្រង់បន្ទាន់ៗបំផុតមួយចំនួនមានដូចជា ការលុបចោលនូវការគ្រប់គ្រងផ្ដាច់មុខរបស់រដ្ឋទៅលើពាណិជ្ជកម្មក្រៅប្រទេស ការប្រកាសឲ្យប្រើច្បាប់វិនិយោគបរទេសដែលអនុញ្ញាតឲ្យក្រុមហ៊ុនឯកជន ចូលរួមក្នុងពាណិជ្ជកម្មក្រៅប្រទេស ការលុបចោលនូវការគ្រប់គ្រងលើថ្លៃទំនិញ ការលុបបំបាត់នូវការដាក់កំហិតផ្នែកបរិមាណ យុទ្ធនាការកសាងទំនាក់ទំនងជាមួយដៃគូពាណិជ្ជកម្មធំៗ និងសមាជិកភាពក្នុងប្រព័ន្ធពាណិជ្ជកម្មក្នុងតំបន់និងពហុភាគី។ ជាលទ្ធផល សេដ្ឋកិច្ចកម្ពុជាកាន់តែបើកទូលាយ និងមានសមាហរណកម្មកាន់តែខ្លាំង ហើយគោលនយោបាយពាណិជ្ជកម្ម ត្រូវបានកែតម្រឹមឲ្យស៊ីគ្នាទៅនឹងវិធាន និងច្បាប់ពាណិជ្ជកម្មអន្តរជាតិ។ យុទ្ធសាស្ត្រទាំងនេះបានក្លាយជាមូលដ្ឋានដ៏សមស្រប សម្រាប់កំណែទម្រង់គោលនយោបាយជាបន្តទៀត និងពង្រឹងទំនុកចិត្តនៃវិស័យសាធារណៈ និងឯកជន ទៅលើការគ្រប់គ្រងដំណើរការកំណែទម្រង់របស់រដ្ឋាភិបាល។

*លក្ខខណ្ឌសេដ្ឋកិច្ចអំណោយផលសម្រេចបាន តាមរយៈកំណែទម្រង់ពីមុន*

កន្លងមក កម្ពុជាអនុវត្តបានយ៉ាងល្អក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ អតិផរណាអាចរក្សាបានឲ្យនៅក្រោមកម្រិត ៥% អត្រាប្ដូរប្រាក់រៀលទល់នឹងដុល្លារមានស្ថិរភាពល្អ ហើយទំនុកចិត្តខាងផ្នែកហិរញ្ញវត្ថុក៏កាន់តែរឹងមាំឡើង។ វិស័យហិរញ្ញវត្ថុបានរីកចម្រើនគួរឲ្យកោតសរសើរ ទាំងនៅក្នុងបរិយាកាសអាជីវកម្ម គំនិតគិតគូរបែបថ្មី និងការប្រកួតប្រជែង។

បរិយាកាសធ្វើអាជីវកម្ម និងវិនិយោគ បានល្អប្រសើរឡើងគួរឲ្យកត់សម្គាល់។ រយៈពេលត្រៀមរៀបចំសម្រាប់ការនាំចេញបានថយចុះពី ៤៣ថ្ងៃ នៅឆ្នាំ២០០៦ មកត្រឹម ២២ថ្ងៃ នៅឆ្នាំ២០១១ ហើយរយៈពេលត្រៀមរៀបចំសម្រាប់ការនាំចូលបានថយចុះពី ៥៣ថ្ងៃ មកត្រឹម ២៦ថ្ងៃ (World Bank 2013)។ តាមការចាប់អនុវត្តប្រើប្រព័ន្ធទិន្នន័យគយស្វ័យប្រវត្តិ (ASYCUDA) លិខិតប្រកាសការនាំចូលជាង ៩០% អាចដោះស្រាយបានក្នុងរយៈពេល ២៤ម៉ោង (គិតចាប់ពីការដាក់លិខិតប្រកាសទំនិញដល់ការបញ្ចេញទំនិញ) (WTO 2011)។ លើសពីនេះទៀត ការធ្វើអង្កេតមួយនៅកម្រិតក្រុមហ៊ុននៅកម្ពុជា បានបង្ហាញនូវការយល់ឃើញប្រសើរជាងមុនអំពីបរិយាកាសធ្វើវិនិយោគ ជាពិសេសទាក់ទងនឹងកំណែទម្រង់ផ្នែកច្បាប់ និងលទ្ធភាពក្នុងការប្រើប្រាស់ហិរញ្ញវត្ថុ និងការធ្វើពាណិជ្ជកម្ម។ ទោះបីនៅមានការងារត្រូវធ្វើជាច្រើនទៀត ដើម្បីបង្កើតបរិយាកាសវិនិយោគអំណោយផលដល់ការចាប់ផ្ដើម និងកិច្ចដំណើរការអាជីវកម្មក្ដី ក៏បរិយាកាសនាបច្ចុប្បន្នមានផ្ដល់នូវលក្ខខណ្ឌដ៏ចាំបាច់ៗ សម្រាប់ការធ្វើវិនិយោគពាណិជ្ជកម្ម និងកំណើនកម្រិតខ្ពស់។

---

[១] រៀបរៀងដោយលោក ហ៊ីង វុត្ថា អ្នកស្រាវជ្រាវក្នុង កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ នៃវិទ្យាស្ថាន CDRI។

*តួអង្គសកម្មនៅក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការក្នុងតំបន់*

កម្ពុជាបានចូលរួមយ៉ាងសកម្មនៅក្នុង មហាអនុតំបន់មេគង្គ (GMS) យុទ្ធសាស្ត្រសហប្រតិបត្តិការសេដ្ឋកិច្ច តំបន់ Ayeyawady-Chao Phrayay-មេគង្គ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) និងគ្រោងការផ្តួចផ្តើមដោយអាស៊ានមួយចំនួនទៀត ដូចជា តំបន់ពាណិជ្ជកម្មសេរីអាស៊ាន តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ជប៉ុន និងគំនិតផ្តួចផ្តើមអាស៊ានបូកបី។

ការផ្តួចផ្តើមធ្វើសហប្រតិបត្តិការក្នុងតំបន់ ផ្តល់អត្ថប្រយោជន៍ច្រើនបែបយ៉ាងដល់កម្ពុជា។ កម្ពុជាទទួលបានប្រយោជន៍ពីគម្រោងការតភ្ជាប់ និងហេដ្ឋារចនាសម្ព័ន្ធ GMS និងអាស៊ានក្នុងរូបភាពជា ផ្លូវថ្នល់សំខាន់ៗ ផ្លូវដែក ស្ពាន ផ្លូវទឹក និងកំពង់ផែ។ ទន្ទឹមគ្នានឹងការរីកលូតលាស់ហេដ្ឋារចនាសម្ព័ន្ធរឹងទាំងនេះ ក៏មានការជឿនលឿនក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធទន់ដែរៈ កំណែទម្រង់បទបញ្ញត្តិរបស់ស្ថាប័នរដ្ឋាភិបាល និងការកសាងសមត្ថភាពមន្ត្រីទទួលខុសត្រូវធ្វើឲ្យចលនាទំនិញ និងមនុស្សឆ្លងកាត់ព្រំដែន មានភាពរលូន តម្លាភាព និងប្រសិទ្ធភាពផ្នែកចំណាយ។ សេដ្ឋកិច្ចក៏បានបើកទូលាយជាងមុនដែរ។ ឧទាហរណ៍ នៅក្រោមគម្រោងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន កម្ពុជាបានប្តេជ្ញាចិត្តកាត់បន្ថយជាបណ្តើរៗនូវ ពន្ធស្ទើរតែទាំងអស់លើទំនិញនាំចូលពីសមាជិកអាស៊ាន ឲ្យមកនៅក្នុងចន្លោះពី 0% និង ៥% នៅត្រឹមឆ្នាំ ២០១០។ នៅក្រោមគម្រោងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន កម្ពុជាត្រូវលុបបំបាត់ពន្ធគយទាំងអស់ នៅត្រឹមថ្ងៃទី១ មករា ២០១៥។

សមាជិកភាពក្នុងក្របខ័ណ្ឌផ្សេងៗនៃ ពាណិជ្ជកម្មក្នុងតំបន់ ផ្តល់ឲ្យកម្ពុជានូវបទពិសោធន៍អំពីកិច្ចសហប្រតិបត្តិការក្នុងតំបន់។ កម្ពុជាកំពុងរៀនសូត្រដោយអនុវត្តផ្ទាល់លើកិច្ចការពាណិជ្ជកម្មអន្តរជាតិ និងដំណើរការកែទម្រង់ក្នុងស្រុក ហើយសំខាន់បំផុត គឺកំពុងបង្កើតគោលនយោបាយក្រៅប្រទេសធ្វើសហប្រតិបត្តិការប្រកបដោយមិត្តភាព ដើម្បីលើកកម្ពស់កេរ្តិ៍ឈ្មោះរបស់ខ្លួននៅក្នុងតំបន់ និងពិភពលោក។

*កំណើនកម្រិតពាណិជ្ជកម្ម និងការប្រកួតប្រជែង*

ចាប់ពីពាក់កណ្តាលទសវត្សរ៍១៩៩០ មក ការរីកលូតលាស់ឡើងវិញយ៉ាងឆាប់រហ័សនៃវិស័យពាណិជ្ជកម្ម បានក្លាយជាកម្លាំងជំរុញមួយដ៏សំខាន់នៃកំណើនសេដ្ឋកិច្ច។ ពាណិជ្ជកម្មសរុបនៅឆ្នាំ២០១១ ស្ទុះឡើងយ៉ាងខ្លាំងដល់ ១២,១៦ពាន់លានដុល្លារ ធៀបនឹង ៣,៣៣ពាន់លានដុល្លារ នៅឆ្នាំ២០០០ ឬមានអត្រាកំណើនប្រចាំឆ្នាំជាមធ្យម ១៤%។ ការវិភាគលើសន្ទស្សន៍ឧត្តមភាពប្រៀបធៀប (RCA) បង្ហាញថា កម្ពុជាមានឧត្តមភាពខ្លាំងក្នុងការប្រកួតប្រជែងលើផ្នែកផលិតកម្មអតិពលកម្ម ដូចជាសម្លៀកបំពាក់ (HS[២] 61, 62, 63) និង ស្បែកជើង (HS 64) ហើយការនាំចេញផលិតផលទាំងនេះមានទំហំជិតដល់ ២/៣ នៃការនាំចេញសរុប។ ទោះជាតម្រូវការសម្លៀកបំពាក់ និងស្បែកជើង បានធ្លាក់ចុះនៅទីផ្សារនាំចេញសំខាន់ៗក្តី ក៏ផលិតកម្មទំនិញទាំងនេះនឹងបន្តកើនឡើង ជាពិសេសក្នុងអនាគតដ៏ខ្លីខាងមុខ ហើយលក្ខណៈប្រកួតប្រជែងនៃទំនិញនេះនៅតែខ្លាំងក្លាដដែល។

កម្ពុជា មិនទាន់អាចប្រកួតប្រជែងក្នុងផ្នែកពាណិជ្ជកម្មកសិកម្មបានទេ ហើយផលិតផលកសិកម្មរួមចំណែកតែ ៤,៩% នៃការនាំចេញសរុបប៉ុណ្ណោះ ប៉ុន្តែមានការព្យាករណ៍ពីនិន្នាការវិជ្ជមានក្នុងផ្នែកនេះ។ សន្ទស្សន៍ RCA ផ្តល់នូវការប្រមើលឃើញលើផលិតផលកសិកម្មមួយចំនួន។ ផលិតផលខ្លះដែលមិនមានឧត្តមភាពប្រៀបធៀបកាលពីបួនឆ្នាំមុន ឥឡូវនេះហាក់ដូចកើនលក្ខណៈប្រកួតប្រជែង និងរួមចំណែកកាន់តែច្រើនក្នុងការនាំចេញសរុប។ គ្រាប់ធញ្ញជាតិជាផលិតផលមានជោគជ័យខ្លាំងជាងគេទាំងនៅក្នុងកំណើនតម្លៃនាំចេញ និងភាពប្រកួតប្រជែង ដូចអាចមើលឃើញតាមកំណើនគួរឲ្យកត់សម្គាល់ក្នុងសន្ទស្សន៍ RCA ពី 0,៨ពិន្ទុ នៅឆ្នាំ២០០៧ ដល់ ៤,៨ពិន្ទុ នៅឆ្នាំ២០១១។ ផលិតផលនាំចេញចម្បងៗផ្សេងទៀត ដែលមានកំណើនឧត្តមភាពប្រៀបធៀបខ្លាំងដែរ រួមមាន ស្ករ នំធ្វើពីស្ករ សត្វរស់ កៅស៊ូ និងបន្លែ និងមើមឈើអាចបរិភោគបាន។

**តួនាទីពាណិជ្ជកម្មក្នុងដំណើរពីអតីតកាលនៃកំណើន**

ទោះបីមិនមានភស្តុតាងជាក់ស្តែងក៏ដោយ ក៏គេពិបាកនឹងបដិសេធពីតួនាទីដ៏សំខាន់នៃគោលនយោបាយពាណិជ្ជកម្ម ក្នុងការជំរុញកំណើនដែរ។ កម្ពុជាទទួលបានអត្ថប្រយោជន៍ច្រើនពីគោលនយោបាយវិនិយោគ និងពាណិជ្ជកម្មសេរីរបស់ខ្លួន រាប់ទាំង ការតភ្ជាប់សេដ្ឋកិច្ចកាន់តែរឹងមាំទៅនឹងទីផ្សារក្នុងតំបន់និងសាកលលោក ហើយនិង កំណើនពាណិជ្ជកម្ម ការវិនិយោគ និងការប្រកួតប្រជែង។ កំណើនភាគច្រើនកើតចេញពីវិស័យ ៤ គឺ កាត់ដេរសម្លៀកបំពាក់និងស្បែកជើង ទេសចរណ៍ សំណង់ និងកសិកម្ម។ កំណើនខ្លាំងក្នុងវិស័យកាត់ដេរ ជាឧទាហរណ៍បង្ហាញយ៉ាងច្បាស់ពី បែបបទដែលគោលនយោបាយពាណិជ្ជកម្មតម្រង់ទិសទៅខាងក្រៅវាជះឥទ្ធិពលទៅលើកំណើន។ វិស័យទេសចរណ៍សម្រេចបានកំណើនលឿន ដោយផ្អែកលើគោលនយោបាយសំខាន់ៗ ដូចជា គោលនយោបាយបើកចំហជើងមេឃ ដែលដាក់អនុវត្តចុងឆ្នាំ១៩៩៧ និងកិច្ចសហប្រតិបត្តិការក្នុងតំបន់លើគោលនយោបាយ ឈ្មោះថា យុទ្ធសាស្ត្រទេសចរណ៍ក្នុងមហាអនុតំបន់មេគង្គ ដែលសំដៅបង្កើតវិស័យទេសចរណ៍អនុតំបន់មួយឲ្យដើរតួជាក្បាលម៉ាស៊ីនសម្រាប់ការអភិវឌ្ឍ ឬនិងផែនការយុទ្ធសាស្ត្រអាស៊ាន។ សេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុជាពិសេស ក្រោមក្របខ័ណ្ឌប្រព័ន្ធពាណិជ្ជកម្មកសិកម្មពិភពលោក (GATS) បានជួយពង្រឹងដល់ប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា (Hing 2009)។ ដែនគ្រប់ដណ្តប់នៃប្រព័ន្ធហិរញ្ញវត្ថុបានរីកធំ និងរឹងមាំឡើង ហើយលក្ខណៈប្រកួតប្រជែង និងប្រសិទ្ធភាពរបស់វា ក៏បានល្អប្រសើរឡើងគួរឲ្យកត់សម្គាល់។

[២] ប្រព័ន្ធដាក់លេខកូដ និងធ្វើសុខដុមនីយកម្មមុខទំនិញ (HS) នៃតារាងពន្ធគយ។

### *ការប្រែប្រួលទិដ្ឋភាពពាណិជ្ជកម្ម*

អភិបាលកិច្ចពាណិជ្ជកម្មអន្តរជាតិ មានការប្រែប្រួលគួរឲ្យកត់សម្គាល់។ ពិភពលោកកាន់តែមានការតភ្ជាប់គ្នាខ្លាំងឡើង៖ ពាណិជ្ជកម្មពហុភាគីដែលគាំទ្រដោយច្បាប់នានារបស់ អង្គការពាណិជ្ជកម្មពិភពលោក (WTO) នៅតែជាសសរស្តម្ភនៃប្រព័ន្ធពាណិជ្ជកម្មអន្តរជាតិ, របៀបរបបពាណិជ្ជកម្មក្នុងតំបន់ (RTAs) បានកើនស្មុគស្មាញដែលអាចជំពាក់គ្នាស្មុគស្មាញដូច "មីមួយចាន" (spaghetti bowl) ហើយខ្សែចង្វាក់ផ្គត់ផ្គង់ជាសាកលកើតមានកាន់តែច្រើនឡើង។ បទពិសោធន៍ពិភពលោកបង្ហាញថា មិនមានប្រទេសណាមួយ អាចរក្សាកំណើនខ្ពស់បានយូរអង្វែង ដោយមិនធ្វើសមាហរណកម្មទៅក្នុង សេដ្ឋកិច្ចពិភពលោកនោះទេ ហើយវាគួរតែជាមធ្យោបាយសម្រាប់ឈានទៅមុខ នៃយុទ្ធសាស្រ្តកំណើន និងពាណិជ្ជកម្មរបស់កម្ពុជា ផងដែរ។

ការរំពឹងទុកអំពី ទីផ្សារនិងប្រព័ន្ធផលិតកម្មអាស៊ីធ្វើសមាហរណកម្មបញ្ចូលគ្នាចាប់ពីចិនភាគខាងត្បូង កាត់តាមប្រទេស GMS ទៅកាន់ប្រទេសដទៃទៀតនៅអាស៊ីអាគ្នេយ៍ បានផ្តល់ឲ្យកម្ពុជានូវការតភ្ជាប់ទំនាក់ទំនងយ៉ាងល្អនៃវិនិយោគ និងពាណិជ្ជកម្ម ដើម្បីជំរុញវិបុលភាព និងការអភិវឌ្ឍវិស័យឯកជន។ កន្លងមក កម្ពុជាមិនទាន់បានក្លាយជាផ្នែកមួយនៃប្រព័ន្ធចែករំលែកផលិតកម្មដ៏មានសន្ទុះក្នុងតំបន់នោះទេ ប៉ុន្តែការប្រែប្រួលថ្មីមួយនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ជាសាកលរបស់តំបន់អាស៊ី ទំនងជាការចាប់ផ្តើមសម័យថ្មីមួយពោរពេញដោយឱកាសល្អ សម្រាប់ប្រទេសដែលមានសេដ្ឋកិច្ចកំពុងស្ទុះឡើង។ កំណើនបន្ទុកចំណាយ បានជំរុញឲ្យក្រុមហ៊ុនច្រើនណាស់ផ្លាស់ទីតាំងផលិតកម្មចេញពីប្រទេសចិន ទៅកាន់ប្រទេសមានបន្ទុកចំណាយទាបជាង ដើម្បីទាញយកអត្ថប្រយោជន៍ពីឧត្តមភាពប្រៀបធៀប ពោលគឺ ថ្លៃពលកម្មទាប កំណើនភាពពឹងផ្អែកគ្នាក្នុងតំបន់ និងលទ្ធភាពចូលទៅកាន់ទីផ្សារប្រទេសទី៣។ និន្នាការនេះ អាចមើលឃើញយ៉ាងច្បាស់នៅក្នុង វិនិយោគរបស់ក្រុមហ៊ុនជប៉ុនពីរ គឺ Minebea ដែលជាក្រុមហ៊ុននាំមុខគេក្នុងពិភពលោកខាងការផលិតគ្រឿងម៉ាស៊ីនតូចៗ និង Sumitomo Electric ជាក្រុមហ៊ុននាំមុខគេខាង ការផលិតបណ្តាញខ្សែអគ្គិសនីគ្រឿងយន្ត ដែលបានបង្កើតកន្លែងផលិតកម្មដ៏ទំនើបនៅកម្ពុជា ដើម្បីបម្រើទីផ្សារសាកល។ ដោយសារខ្សែចង្វាក់ផ្គត់ផ្គង់សាកលត្រូវពឹងផ្អែកលើប្រព័ន្ធពាណិជ្ជកម្មបើកចំហ ហេតុនេះគោលនយោបាយឧស្សាហកម្ម និងពាណិជ្ជកម្ម ដើរតួនាទីសំខាន់ណាស់ក្នុងការកំណត់អត្រាដែលក្រុមហ៊ុនបរទេសមកបើកសាខានៅកម្ពុជា។

### អាទិភាពគោលនយោបាយសម្រាប់ពាណិជ្ជកម្មអន្តរជាតិ និងកំណើនសេដ្ឋកិច្ច

អត្ថបទនេះឯកភាពតាមមតិថា ពាណិជ្ជកម្មជាលក្ខខណ្ឌចាំបាច់មួយសម្រាប់កំណើនសេដ្ឋកិច្ច ប៉ុន្តែពាណិជ្ជកម្មតែមួយមុខមិនទាន់គ្រប់គ្រាន់ទេ។ ដើម្បីរក្សាកំណើនក្នុងរយៈពេលវែង ត្រូវមានកត្តារួមផ្សំជាច្រើនទៀត ក្រៅពីគោលនយោបាយជម្រុញការនាំចេញ ដូចជា រដ្ឋាភិបាលមានសមត្ថភាព ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការផ្ទេរចំណេះដឹងនិងបច្ចេកវិទ្យា និងការវិនិយោគកម្រិតខ្ពស់ក្នុងហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ និងការថែទាំសុខភាព។ ខាងក្រោមនេះ ជាអាទិភាពគោលនយោបាយ ដើម្បីជម្រុញការនាំចេញ និងលើកកម្ពស់ពិពិធកម្ម ដែលជាគន្លឹះសម្រាប់កំណើនសេដ្ឋកិច្ចមានចីរភាព។

*រក្សាការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចបានល្អ៖* ការធានាឲ្យបរិយាកាសម៉ាក្រូសេដ្ឋកិច្ចធន់នឹងវិបត្តិ និងមានស្ថិរភាព នៅតែជាគន្លឹះដ៏សំខាន់ញ៉ាំងឲ្យគោលនយោបាយជំរុញពាណិជ្ជកម្មសម្រេចជោគជ័យ។ អាទិភាពគោលនយោបាយដើម្បីការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចបានល្អ រួមមាន ការរក្សាអតិផរណាឲ្យនៅក្រោម ៥% ការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ ការកសាងភាពធន់ទៅនឹងកត្តាខាងក្រៅ ការកែលំអការប្រមូលចំណូល និងការពង្រឹងសេវាកម្មវិស័យហិរញ្ញវត្ថុ។

*កែលំអបរិយាកាសវិនិយោគ៖* បរិយាកាសអំណោយផលដល់វិនិយោគ មានកត្តារួមផ្សំជាច្រើន ដូចជា កម្រិតប្រាកដប្រជានៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ច, គុណភាព និងភាពងាយស្រួលប្រើប្រាស់នៃហេដ្ឋារចនាសម្ព័ន្ធ, វិសាលភាពបទបញ្ញត្តិរដ្ឋាភិបាល, លក្ខណៈនៃការយកពន្ធ, ចំណាយ និងលទ្ធភាពទទួលបានហិរញ្ញវត្ថុសម្រាប់ក្រុមហ៊ុន, លទ្ធភាពបានប្រើប្រាស់ គុណភាព និងតម្លៃនៃកត្តាផលិតកម្ម, លក្ខណៈស្មើភាពគ្នាផ្តល់ឲ្យដោយរដ្ឋាភិបាលចំពោះក្រុមហ៊ុននានា, អភិបាលកិច្ច និងអំពើពុករលួយ, និងសន្តិសុខ។ អាទិភាពគោលនយោបាយជាបន្ទាន់ដើម្បីកែលំអចំណុចខ្សោយនៃបរិយាកាសវិនិយោគ រួមមាន ការកែលំអហេដ្ឋារចនាសម្ព័ន្ធ ការតម្រឹមនីតិវិធីគយ ការបង្កើនប្រសិទ្ធភាពផ្នែកភស្តុភារ និង ការវិនិយោគលើមូលធនមនុស្ស។

*សម្រួលនីតិវិធីពន្ធគយ៖* ទម្រង់បែបបទពន្ធគយ ដែលរួមមាន ការងារក្រដាសស្នាម ការពិនិត្យយល់ព្រម បទបញ្ញត្តិ និងប្រាក់កម្រៃ ជាឧបសគ្គចម្បងបំផុតបីដែលរារាំងដល់ការនាំចេញ (World Bank 2009; ADB 2012)។ ដំណើរការនាំចូល និងនាំចេញមិនមានប្រសិទ្ធភាពនេះ វាជះឥទ្ធិពលដោយផ្ទាល់ដល់ចំណាយពាណិជ្ជកម្មផលិតភាពកត្តាផលិតកម្មសរុបនិងការប្រកួតប្រជែង។ កម្ពុជា ត្រូវធ្វើកំណែទម្រង់គ្រប់ជ្រុងជ្រោយនានា ដើម្បីជួយសម្រួលលើឧបសគ្គចម្បងៗចំពោះវិស័យឯកជន ជាពិសេសក្នុងដំណើរការជម្រះឯកសារគយនិងពាណិជ្ជកម្ម ការសម្របសម្រួលក្នុងចំណោមស្ថាប័នជួយសម្រួលផ្នែកពាណិជ្ជកម្ម និងលទ្ធភាពទទួលបានព័ត៌មានស្តីពី នីតិវិធីនាំចេញ បទបញ្ញត្តិ និងប្រាក់កម្រៃផ្សេងៗ។

*លើកកម្ពស់ប្រសិទ្ធភាពផ្នែកភស្តុភារ៖* កម្ពុជាស្ថិតក្នុងចំណោមប្រទេស មានសេវាកម្មភស្តុភារខ្វះប្រសិទ្ធភាពបំផុតនៅក្នុងតំបន់។ ការបំពេញមុខងារផ្នែកភស្តុភារមិនបានល្អ បណ្តាលមកពីកត្តាជាច្រើន មានជាអាទិ៍ គុណភាពអន់និងកង្វះហេដ្ឋារចនាសម្ព័ន្ធ ប្រសិទ្ធភាពនិងប្រសិទ្ធផលទាបក្នុងដំណើរការជម្រះឯកសារអនុវត្តដោយមន្ត្រីគយ និងភ្នាក់ងារត្រួតពិនិត្យនៅច្រកព្រំដែន ព្រមទាំងសមត្ថភាពនិងគុណភាពទាបនៃសេវាភស្តុភារ។ អន្តរាគមន៍គោលនយោបាយ អាចមានតាំងពីការកែលំអហេដ្ឋារចនាសម្ព័ន្ធរឹង ពាក់ព័ន្ធនឹងផ្នែកពាណិជ្ជកម្ម រហូតដល់ការលើកកម្ពស់ការគ្រប់គ្រងព្រំដែន ដែលមានជាអាទិ៍ កំណែ

ទម្រង់និងទំនើបកម្មបែបបទគយ ការចែកចាយព័ត៌មានធំទូលាយជាងមុន ការលើកកម្ពស់ភាពប្រកួតប្រជែងក្នុងសេវាដឹកជញ្ជូនទំនិញតាមផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស និងលទ្ធភាពទទួលបានភ្លាមៗ នូវព័ត៌មានស្ដីពីកិច្ចព្រមព្រៀងដឹកទំនិញឆ្លងកាត់ព្រំដែន។

*ពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការក្នុងតំបន់៖* កម្ពុជានៅមិនទាន់ទាញប្រយោជន៍បានពេញលេញពី ឱកាសល្អនានាផុសចេញពីការធ្វើសមាហរណកម្មក្នុងតំបន់នោះទេ (ឯកសារបោះពុម្ពផ្សាយរបស់ CDRI នាពេលខាងមុខ)។ បញ្ហាប្រឈមចំពោះមុខ គឺការធានាឲ្យវិស័យពាណិជ្ជកម្មអាចទទួលបាន និងទាញយកចំណេញពីកិច្ចសហប្រតិបត្តិការក្នុងតំបន់ ដើម្បីឲ្យការនាំចេញអាចមានចម្រុះមុខ លែងពឹងផ្អែកតែលើវិស័យមួយចំនួនតូច។ កម្ពុជាត្រូវពង្រឹងភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការក្នុងតំបន់ ដើម្បីសម្រេចនូវចំណុចខាងលើ ព្រមទាំងគោលដៅអភិវឌ្ឍន៍ក្នុងរយៈពេលវែង។ ចំណុចសំខាន់បំផុតនៅក្នុងនេះ គឺការសម្របសម្រួល និងការបន្សីចម្ងាក់គ្នារវាង កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍GMS-អាស៊ាន-អាស៊ីបូព៌ា និងសមាហរណកម្មក្នុងតំបន់ ដើម្បីញ៉ាំងឲ្យមានការយកចិត្តទុកដាក់លើ កំណើនយូរអង្វែង និងការភ្ជិតគំលាតផ្នែកអភិវឌ្ឍន៍ ដោយមានការធ្វើវិនិយោគក្នុងតំបន់ទៅលើការអភិវឌ្ឍសមត្ថភាពស្ថាប័នក្នុងរយៈពេលវែង។

*ពង្រឹងប្រតិបត្តិការតំបន់សេដ្ឋកិច្ចពិសេស (SEZ)៖* SEZs ត្រូវបានបង្កើតឡើងជិតមួយទស្សវត្សរ៍មកហើយ ប៉ុន្តែមិនទាន់បានជោគជ័យដូចការរំពឹងទុក ក្នុងការទាក់ទាញវិនិយោគិននោះទេ។ ក្នុងចំណោម SEZs បានទទួលការអនុម័តទាំង ២១ មានត្រឹមតែ ៨ប៉ុណ្ណោះ ដែលមានដំណើរការ។ ក្រៅពីហេដ្ឋារចនាសម្ព័ន្ធមានគុណភាពខ្ពស់ និងការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុនោះ SEZs ត្រូវគ្រប់គ្រងពន្ធ និងពង្រឹងអនុវត្តន៍បទបញ្ញត្តិឲ្យមានប្រសិទ្ធភាពនិងមានស្តង់ដារខ្ពស់ លុបបំបាត់ឧបសគ្គផ្នែកការិយាធិបតេយ្យនិងរដ្ឋបាល ស្វែងរកដំណោះស្រាយជួយសម្រួលបញ្ហាផ្សេងៗដែលវិនិយោគិនជួបប្រទះ បង្កើតទំនាក់ទំនងការងារឲ្យកាន់តែមានភាពបត់បែនល្អ និងធានាលទ្ធភាពរកបានជានិច្ច ទាំងកម្លាំងពលកម្មមានជំនាញខ្ពស់ និងមានជំនាញទាប។

*ធ្វើវិនិយោគក្នុងមូលធនមនុស្ស៖* ទីផ្សារពលកម្មកម្ពុជានាបច្ចុប្បន្ន មានលក្ខណៈសម្គាល់ដោយឡែកគឺ ចំនួនភាគច្រើននៃកម្លាំងពលកម្មមានកម្រិតអប់រំទាប មុខជំនាញពលករមិនស៊ីគ្នានឹងការងារ និងកង្វះខាតជំនាញតាមផ្នែកមួយចំនួន។ ពិនិត្យតាមបទពិសោធន៍ប្រទេសមានជោគជ័យក្នុងការនាំចេញ កម្ពុជាត្រូវធ្វើវិនិយោគច្រើនៗទៅលើការអភិវឌ្ឍមូលធនមនុស្ស។ គោលនយោបាយផ្នែកអប់រំ គួរសង្កត់ធ្ងន់លើការអប់រំថ្នាក់បឋមសិក្សាជាសាកល និងការកែលំអគុណភាពអប់រំនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា។ ការអប់រំថ្នាក់ឧត្តមសិក្សា គួរផ្ដោតលើការអប់រំជាន់ខ្ពស់ខាងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងការអប់រំនិងបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ។ ជម្រើសគោលនយោបាយជាអាទិភាព គួររួមមាន ការកែលំអហេដ្ឋារចនាសម្ព័ន្ធសាលារៀន ជាពិសេសនៅតំបន់ជនបទ ការបង្កើនចំនួនសាលាបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីបំពេញតម្រូវការនូវពលករមានជំនាញ ការលើកកម្ពស់គុណភាពការបង្រៀន និងអភិបាលកិច្ចនៃការអប់រំថ្នាក់ឧត្តមសិក្សា និងការដាក់បញ្ចូលជាផ្លូវការនូវសមត្ថភាពផ្នែកស្រាវជ្រាវ និងអភិវឌ្ឍន៍ទៅក្នុងស្ថាប័នអប់រំជាន់ខ្ពស់។

*កែលំអសេវាផ្ដល់ព័ត៌មានពីទីផ្សារនាំចេញ៖* វិស័យឯកជនខ្វះខាតចំណេះដឹងពីនីតិវិធីនាំចេញ និងទីផ្សារនាំចេញ (WTO 2011)។ ពិនិត្យតាមតួនាទីនៃបណ្ដាអង្គការជំរុញពាណិជ្ជកម្ម ក្នុងការលុបបំបាត់បញ្ហាទទួលបានព័ត៌មានមិនដូចគ្នានោះ ការពង្រឹងតួនាទីនៃនាយកដ្ឋានលើកកម្ពស់ពាណិជ្ជកម្ម (TPD) ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រជំរុញការនាំចេញ គឺជាសកម្មភាពដ៏ត្រឹមត្រូវ។ វិធានការជាអាទិភាពក្នុងរយៈពេលខ្លី គួរផ្ដោតលើការផ្ដល់ការគាំទ្រ និងព័ត៌មានដែលក្រុមហ៊ុននាំចេញត្រូវការ ជាពិសេសក្នុងការអភិវឌ្ឍផលិតផលនិងទីផ្សារ និងសេវាព័ត៌មានពីទីផ្សារ។ មូលនិធិបានពីដៃគូអភិវឌ្ឍន៍នានា អាចមានប្រយោជន៍ក្នុងដំណាក់កាលដំបូងនៃកំណែទម្រង់ ព្រោះវាអាចជួយជំរុញរបៀបរបបអនុវត្តល្អ និងការរៀបចំប្រកបដោយប្រសិទ្ធភាព។ ប៉ុន្តែការជួយទ្រទ្រង់បែបនេះគួរតែមានលក្ខណៈបណ្ដោះអាសន្ន ហើយត្រូវបន្តដំណើរការដោយប្រើធនធានក្នុងស្រុក តាមរយៈការផ្ដល់ថវិកាទាំងស្រុងពីរដ្ឋាភិបាល ឬការគួបផ្សំគ្នារវាងថវិកាពីរដ្ឋាភិបាល និងការបង់ថ្លៃសេវា។ សមាសធាតុសំខាន់មួយទៀតក្នុងការពង្រឹង TPD គឺការធានាគុណភាពបុគ្គលិកតាមរយៈការកសាងសមត្ថភាពជាប្រចាំ និងការជ្រើសរើសបុគ្គលិកមានទេពកោសល្យ និងបទពិសោធន៍ផ្នែកពាណិជ្ជកម្ម។ វិធានការផ្នែកគោលនយោបាយ គួរផ្ដោតផងដែរលើការកសាងបណ្ដាញពាណិជ្ជកម្មក្នុងស្រុក (រដ្ឋាភិបាល វិស័យឯកជន និងវិនិយោគិន) និងបណ្ដាញក្រៅប្រទេស (រដ្ឋាភិបាលបរទេស អ្នកទិញនិងវិនិយោគិនអន្តរជាតិ) និងការកែលំអប្រព័ន្ធផ្ដល់ព័ត៌មាន។

*ជំរុញការអនុវត្តតាមស្តង់ដារ៖* កម្ពុជាបានជួបបញ្ហាប្រឈមធំៗណាស់ ក្នុងការអនុវត្តតាមស្តង់ដារបច្ចេកទេសរបស់ប្រទេសនាំចូល។ ការត្រួតពិនិត្យ និងពង្រឹងអនុវត្តន៍តាមស្តង់ដារ បានជួបឧបសគ្គធ្ងន់ធ្ងរ មានជាអាទិ ក្របខ័ណ្ឌច្បាប់និងបទបញ្ញត្តិអន់ខ្សោយ កង្វះការសម្របសម្រួល និងការជាន់តួនាទីគ្នាក្នុងចំណោមទីភ្នាក់ងារផ្សេងៗ អវត្តមានការធ្វើតេស្តជាប្រព័ន្ធក្នុងមន្ទីរពិសោធន៍ ដើម្បីជួយទ្រទ្រង់ដល់ការត្រួតពិនិត្យ ដោយសារធនធានមនុស្សនិងហិរញ្ញវត្ថុមានតិច កង្វះការពិនិត្យតាមដាន និងអធិការកិច្ចជាលក្ខណៈប្រព័ន្ធ និងប្រព័ន្ធចេញលិខិតបញ្ជាក់ដោយមិនមានការធ្វើតេស្តផ្ទៀងផ្ទាត់ (FAO 2010)។ កំណែទម្រង់គ្រប់ជ្រុងជ្រោយនានាក៏ត្រូវធ្វើដែរ ដើម្បីដោះស្រាយបញ្ហាចម្បងៗនៅក្នុងប្រព័ន្ធគ្រប់គ្រងស្តង់ដារ។ វិធានការជាក់ស្ដែងនានា គួរផ្ដោតលើការពង្រឹងក្របខ័ណ្ឌស្ថាប័ន ជាពិសេសទាក់ទងនឹង អាណត្តិ និងការសម្របសម្រួល, ការកសាងសមត្ថភាពផ្នែកគ្រប់គ្រង និងបច្ចេកទេស, និងការបង្កើតអង្គភាពវាយតម្លៃរបស់កម្ពុជា ដែលទទួលស្គាល់ដោយទីភ្នាក់ងារផ្ដល់ការទទួលស្គាល់ថ្នាក់អន្តរជាតិ។

## សេចក្ដីបញ្ចប់

ថ្វីបើពាណិជ្ជកម្មជាលក្ខខណ្ឌចាំបាច់ សម្រាប់គន្លងកំណើនរបស់កម្ពុជាក្ដី ប៉ុន្តែពាណិជ្ជកម្មតែមួយមុខមិនទាន់គ្រប់គ្រាន់ទេ។ គោលនយោបាយពាណិជ្ជកម្ម អាចជួយបង្កើនល្បឿនការធ្វើសមាហរណកម្មចូលទៅក្នុងសេដ្ឋកិច្ចពិភពលោក និងពង្រឹងយុទ្ធសាស្ត្រកំណើនដ៏ឈ្លាសវៃមួយ ប៉ុន្តែវាមិនអាចធានាឲ្យដំណើរការទាំងនេះពិតជាមានជោគជ័យនោះទេ។ នៅមានសមាសធាតុជាច្រើនទៀតដែលជួយកាត់បន្ថយឧបសគ្គរារាំងកំណើន ដូចជាការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចល្អប្រសើរ បរិយាកាសអំណោយផលសម្រាប់ពាណិជ្ជកម្មនិងវិនិយោគ ស្ថាប័នមានសមត្ថភាព និងការធ្វើវិនិយោគយ៉ាងត្រឹមត្រូវក្នុងមូលធនមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធ។ កំណែទម្រង់បន្ថែម និង សេរីភាវូបនីយកម្មគោលនយោបាយពាណិជ្ជកម្ម ត្រូវតែមាន ឆន្ទៈនយោបាយពីថ្នាក់ដឹកនាំសន្ទុះដ៏ខ្លាំងនិងកម្លាំងជំរុញថ្មីៗពីអ្នកពាក់ព័ន្ធសំខាន់ៗ ហើយនិងរដ្ឋាភិបាលដែលមានសមត្ថភាពនិងទំនួលខុសត្រូវខ្ពស់។

## ឯកសារយោង


ADB–Asian Development Bank (2012), *Trade and Trade Facilitation in the Greater Mekong Subregion* (Manila: ADB)

CDRI–Cambodia Development Resource Institute (forthcoming), *ASEAN 2030: Growing Together for Economic Prosperity – The Challenges*, *the Cambodia Background Paper* (Phnom Penh: CDRI)

FAO–Food and Agriculture Organisation (2010), "An Action Plan to Improve SPS Capacity in Cambodia", STDF Project 246, http://www.standardsfacility.org/files/Project_documents/Project_Grants/STDF_246_Final_Report_Jul-10.pdf (accessed at 15 March 2013)

Hing Vutha (2009), "Trade Liberalisation in Financial Sector: Experience from Cambodia", final research paper, University of Barcelona, Spain

World Bank (2013), "Ease of doing Business in Cambodia", **http://www.doingbusiness.org/data/exploreeconomies/cambodia** (accessed on 15 March 2013)

WTO–World Trade Organisation (2011), *Trade Policy Review: Cambodia*, WT/TPR/S/253 (Geneva: WTO)



**ឯកសារពិភាក្សាចេញផ្សាយថ្មីៗនៅលើគេហទំព័រ** www.cdri.org.kh

**New Working Papers (WP) Online Publications at www.cdri.org.kh**

WP 70) Hing Vutha, Saing Chan Hang and Khieng Sothy (August 2012), *Baseline Survey for Socioeconomic Impact Assessment: Greater Mekong Sub-region Transmission Project*

71) Kim Sedara and Joakim Öjendal with Chhoun Nareth and Ly Tem (December 2012), *A Gendered Analysis of Decentralisation Reform in Cambodia*

72) Hem Socheth (March 2013), *Impact of the Global Financial Crisis on Cambodian Economy at Macro and Sectoral Levels*

73) Hay Sovuthea (March 2013), *Government Response to Inflation Crisis and Global Financial Crisis*

74) Ngin Chanrith (March 2013), *Impact of the Global Financial Crisis on Employment in SMEs in Cambodia*

75) Tong Kimsun (March 2013), *Impact of the Global Financial Crisis on Poverty: Evidence from Nine Villages in Cambodia*

76) Hing Vutha (March 2013), *Impact of the Global Financial Crisis on the Rural Labour Market: Evidence from Nine Villages in Cambodia*

77) Saing Chan Hang (March 2013), *Household Vulnerability to Global Financial Crisis and Their Risk Coping Strategies: Evidence from Nine Rural Villages in Cambodia*

78) Tong Kimsun and Phay Sokcheng (March 2013), *The Role of Income Diversification during the Global Financial Crisis: Evidence from Nine Villages in Cambodia*

79) Lun Pidé (March 2013), *The Role of Rural Credit during the Global Financial Crisis: Evidence From Nine Villages in Cambodia*

80) Saing Chan Hang (March 2013), *Binding Constraints on Economic Growth in Cambodia: A Growth Diagnostic Approach*

# វិសមភាពយេនឌ័រក្នុងវិស័យកសិកម្ម៖ អង្កេតគ្រួសារសមាជិកអង្គការកសិករក្នុងបួនខេត្ត[1]

អត្ថបទនេះបង្ហាញពី ការវិភាគបែបពណ៌នាលើលទ្ធផលអង្កេតគ្រួសារកសិករ អនុវត្តដោយវិទ្យាស្ថាន CDRI នៅឆ្នាំ២០១១ ដែលជាផ្នែកមួយនៃការសិក្សា ដើម្បីពិនិត្យពីអត្ថប្រយោជន៍ និងឧបសគ្គនៃការចូលរួមក្នុងអង្គការកសិករ (FO) សម្រាប់គ្រួសារមានស្ត្រីជាមេគ្រួ និងគ្រួសារមានបុរសជាមេគ្រួ។ យោងតាមលទ្ធផលអង្កេត គ្រួសារមានស្ត្រីជាមេគ្រួ តំណាងឲ្យប្រហែល ២៦% នៃគ្រួសារទាំងអស់ដែលធ្វើកសិកម្ម ក្នុងតំបន់សិក្សា (CDRI ចេញផ្សាយក្នុងពេលឆាប់ៗ)[2] ។ ដូច្នេះ ការសិក្សាមានជាប់ទាក់ទងដោយផ្ទាល់ទៅនឹងគ្រួសារទាំងនេះ ព្រមទាំងបញ្ហាប្រឈមទូទៅដែល កសិករជាស្ត្រីត្រូវជួបប្រទះ។ ការសិក្សាផ្តោតទៅលើផលិតកម្មស្រូវ ដែលជាសកម្មភាពចម្បងគេក្នុងវិស័យកសិកម្ម និងជាអាទិភាពគោលនយោបាយរបស់រដ្ឋាភិបាល ហើយក៏ពិនិត្យផងដែរពីការចិញ្ចឹមសត្វ ដោយសារវាជាសកម្មភាពទូទៅមួយនៃអង្គការកសិករនៅកម្ពុជា។

## សាវតា និងហេតុផលនៃការសិក្សា

កំណើនសេដ្ឋកិច្ចនៅកម្ពុជា មានមូលដ្ឋានតូចចង្អៀត ដោយពឹងផ្អែកលើសសរស្តម្ភ ៤ រួមមាន វិស័យកាត់ដេរ ទេសចរណ៍ សំណង់ និងកសិកម្ម។ ទោះបីកម្ពុជាមានការផ្លាស់ប្តូររចនាសម្ព័ន្ធគួរឲ្យកត់សម្គាល់ចេញពីសេដ្ឋកិច្ចផ្អែកលើ កសិកម្មបែបចិញ្ចឹមពោះក៏ដោយ ក៏សេដ្ឋកិច្ចកម្ពុជានៅបន្តពឹងផ្អែកខ្លាំងលើវិស័យកសិកម្មដែលរួមចំណែកជាងមួយភាគបី (ប្រមាណ ៣៤% នៅឆ្នាំ២០១០) នៃ ផសស (NIS 2011)។ ទោះបីវិស័យកសិកម្មមានអត្រាកំណើនមធ្យមទាបជាងវិស័យឧស្សាហកម្ម និងសេវាកម្មក្តី ប៉ុន្តែវានៅតែមានលក្ខណៈធន់ល្អទៅនឹងផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុសកលនៅឆ្នាំ២០០៩ ដោយបានដើរតួជាសំណាញ់សុវត្ថិភាពសង្គមដ៏សំខាន់ និងជាពោងសុវត្ថិភាពសេដ្ឋកិច្ច ហើយជួយសង្គ្រោះប្រជាជនមិនឲ្យយ៉ាប់យ៉ឺនខ្លាំងពេក ព្រមទាំងទប់ស្កាត់ ផសស មិនឲ្យមានកំណើនអវិជ្ជមាន។

វិស័យកសិកម្ម មានសក្តានុពលខ្លាំងដើម្បីក្លាយជាក្បាលម៉ាស៊ីនជំរុញកំណើន សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចនៅកម្ពុជា ដោយបានផ្តល់ការងារដល់ប្រមាណ ៤៩,៥% នៃកម្លាំងពលកម្មសរុបនៅឆ្នាំ២០១១ (NIS 2012)។ វិស័យនេះមានលក្ខណៈសម្គាល់ចម្បងមួយគឺ គ្រួសារនៅជនបទមានកម្មសិទ្ធិលើក្បាលដីតូចៗ៖ ដោយឡែកនៅឆ្នាំ២០០៩ ៤៦,៩% នៃគ្រួសារទាំងអស់ មានដីកសិកម្មតិចជាងមួយហិកតា។ ម៉្យាងទៀត ទិន្នន័យបានពីជំរឿនឆ្នាំ២០០៨ បង្ហាញថា ៦៦,១% នៃស្ត្រីមានការងារធ្វើ (អាយុពី ១៥ ទៅ ៦៤ឆ្នាំ) បានចូលរួមធ្វើកសិកម្មបែបចិញ្ចឹមពោះ ធៀបនឹងប្រហែល ៦០% នៃបុរសដែលមានការងារធ្វើ (NIS 2009)[3]។ ដូច្នេះការអភិវឌ្ឍវិស័យកសិកម្ម ជាមធ្យោបាយមានឥទ្ធិពលធំទូលាយ និងប្រសិទ្ធភាពខ្ពស់ ក្នុងការលើកកម្ពស់កម្រិតជីវភាពនៅតាមជនបទ ជាពិសេសសម្រាប់ស្ត្រី។

ដើម្បីសម្រេចចក្ខុវិស័យថ្នាក់ជាតិនៃ ការអភិវឌ្ឍវិស័យកសិកម្ម រដ្ឋាភិបាលបានទទួលស្គាល់ និងផ្តល់អាទិភាពលើការជំរុញកសិកម្មរបស់ម្ចាស់ដីតូចៗ និងការបង្កើតអង្គការកសិករ ដោយកំណត់វាជាគន្លឹះនៃ យុទ្ធសាស្ត្រក្នុងការលើកកម្ពស់ជីវភាព ការអភិវឌ្ឍសេដ្ឋកិច្ចតំបន់ជនបទ និងការកាត់បន្ថយភាពក្រីក្រ (Chea 2010)។ អង្គការកសិករ រំពឹងថាអាចជួយពួកសមាជិកឲ្យមានលទ្ធភាពកាន់តែច្រើនក្នុងការទទួលបានព័ត៌មានធាតុចូល និងបច្ចេកទេសផ្សេងៗ ដែលជួយលើកកម្ពស់ផលិតភាពកសិកម្មរបស់កសិករមានដីធ្លីតូចៗ និងបង្កើតលទ្ធភាពរួមគ្នាក្នុងការចូលទៅកាន់ទីផ្សារធាតុចូល និងផលិតផលកសិកម្ម ដើម្បីឲ្យផលិតករខ្នាតតូច នៅតាមជនបទអាចទាញយកគុណប្រយោជន៍ពីសេដ្ឋកិច្ចមាត្រដ្ឋាន។

## ការពិនិត្យគ្រួសៗពីអង្គការកសិករនៅកម្ពុជា

ទាំងក្នុងគោលគំនិត និងការអនុវត្តជាក់ស្តែង អង្គការកសិករក្នុងលក្ខណៈជាមធ្យោបាយដើម្បីសម្រេចបានការអភិវឌ្ឍកសិកម្មសន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រនៅកម្រិតមូលដ្ឋាន បានកើតមានជាយូរមកហើយ និងមានច្រើនបែបយ៉ាងនៅកម្ពុជា។ Couturier *et al.* (2006) រាយការណ៍ថា មានប្រហែល ១៣.០១៧ អង្គការកសិករ បានកកើតឡើងគិតត្រឹមឆ្នាំ២០០៥ ក្នុងនេះមានជាង ៦០% បានកកើតឡើងតាំងពីឆ្នាំ២០០០។ អង្គការកសិករនៅកម្ពុជាភាគច្រើន មានសមាជិកតិចជាង ៣០នាក់ ហើយមានតែ ១២% ប៉ុណ្ណោះដែលមានសមាជិកលើសពី ១០០នាក់។

អង្គការកសិករ ត្រូវបានបង្កើតឡើងដើម្បីជំរុញការអភិវឌ្ឍជនបទ តាមរយៈការកសាងសមត្ថភាពនិងសកម្មភាពរួមគ្នា ដោយផ្អែកលើគោលការណ៍នៃការស្ម័គ្រចិត្ត ការជួយខ្លួនឯង ការពឹងលើខ្លួនឯង ប្រជាធិបតេយ្យ សមភាព សមធម៌ សាមគ្គីភាព និងការពង្រឹងសិទ្ធិអំណាច (Nou 2006)។ អង្គការកសិករភាគច្រើននៅកម្ពុជា ត្រូវបានអង្គការមិនមែនរដ្ឋាភិបាល ឬស្ថាប័នរដ្ឋាភិបាលបង្កើតឡើង និងផ្តល់ជំនួយហិរញ្ញវត្ថុ និង/ឬ បច្ចេកទេសឲ្យ ដោយមានតួនាទីចម្បងជួយលើកកម្ពស់ លទ្ធភាពទទួលបានឥណទានតាមរយៈគម្រោងប្រាក់សន្សំជាក្រុម អាជីវកម្មជាក្រុម ការកសាងសមត្ថភាពផ្នែកបច្ចេកទេសកសិកម្ម និងការអភិវឌ្ឍសហគមន៍ (Couturier *et al.* 2006)។

ដំបូងឡើយ អង្គការកសិករមួយចំនួនធ្វើការតែជាមួយកសិករក្រីក្រខ្លាំងប៉ុណ្ណោះ ប៉ុន្តែវិធីសាស្ត្រនេះ មិនបានទទួលជោគជ័យទេ

[1] រៀបរៀងដោយ កែវ សុជាតិ អ្នកស្រាវជ្រាវ កម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ នៅវិទ្យាស្ថាន CDRI។

[2] តាមពិតអត្ថប្រយោជន៍ និងឧបសគ្គនៃអង្គការកសិករ សម្រាប់ស្ត្រីដែលរស់នៅក្នុងគ្រួសារមានបុរសជាមេគ្រួក៏គួរពិនិត្យផងដែរប៉ុន្តែប្លង់អង្កេតដែលប្រើប្រាស់ក្នុងករណីសិក្សានេះ មិនអនុញ្ញាតឲ្យធ្វើការវិភាគបែបនេះទេ។

[3] ការគណនារបស់អ្នកនិពន្ធដោយផ្អែកលើទិន្នន័យទទួលបានពីជំរឿនថ្នាក់ជាតិឆ្នាំ២០០៨។

តារាង ១៖ ប្រាក់កម្ចីជាមធ្យមរបស់សមាជិកអង្គការកសិករ បែងចែកតាមភេទរបស់មេគ្រួសារ

| | គ្រួសារសរុប | មេគ្រួសារជាស្ត្រី | មេគ្រួសារជាបុរស | t-test |
|---|---|---|---|---|
| ចំនួនគ្រួសារ | 330 | 83 | 247 | - |
| ប្រាក់កម្ចីជាមធ្យម | 306,000 | 208,000 | 339,000 | -1.4040 |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកទៅលើទិន្នន័យអង្កេតរបស់ CDRI (ចេញផ្សាយនាពេលឆាប់ៗ)។ សម្គាល់៖ ដោយសារសមាជិកនៃអង្គការកសិករត្រូវផ្លាស់វេនគ្នាទទួលប្រាក់កម្ចី ហេតុនេះគ្រួសារមានស្ត្រីជាមេគ្រួ និងគ្រួសារមានបុរសជាមេគ្រួ មិនមែនទទួលបានប្រាក់កម្ចីដំណាលគ្នារហូតនោះទេ។ ១ដុល្លារ=៤០០០រៀល។

ដោយសារកសិករទាំងនោះខ្វះខាតទ្រព្យផលិតកម្ម ទុន អក្ខរកម្ម និងជំនាញគ្រប់គ្រងចាំបាច់នានា ដើម្បីអនុវត្តតាមការណែនាំរបស់អង្គការកសិករ។ អ្នកមកពីខាងក្រៅ មានជាអាទិ រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ឬទីភ្នាក់ងារផ្តល់ជំនួយដទៃទៀត ជាអ្នកផ្តួចផ្តើមបង្កើតអង្គការកសិករភាគច្រើន ហើយក្នុងគំរូតាង គ្មានអង្គការកសិករណាមួយបានកកើតឡើងដោយខ្លួនឯងទេ ប៉ុន្តែមានជាង ៦០% ប្រាប់ថា ទីភ្នាក់ងារផ្តល់ជំនួយផ្សេងៗបានបង្កើតពួកគេឡើង។ គោលបំណងរបស់អង្គការកសិករប្រែប្រួលខុសគ្នាទៅតាម របៀបវារៈខុសៗគ្នារបស់ទីភ្នាក់ងារផ្តល់ជំនួយ ប៉ុន្តែការផ្តល់ប្រាក់សន្សំក្រៅផ្លូវការ និងគម្រោងឥណទានឆ្លាស់វេនគ្នា គឺជាទិសដៅរួម។

## ទិន្នន័យ និងវិធីសាស្ត្រស្រាវជ្រាវ

អង្កេតគ្រួសារបានធ្វើឡើងនៅឆ្នាំ២០១១ ក្នុងបួនខេត្ត គឺមាន បាត់ដំបង កំពង់ធំ កំពត និងស្វាយរៀង។ គំរូតាងនៃអង្កេត រួមមាន ៦៩៩គ្រួសារ ក្នុងនោះ ៣៣០គ្រួសារជាសមាជិកអង្គការកសិករ និង ៣៦៩គ្រួសារទៀត មិនមែនជាសមាជិកអង្គការកសិករទេ។ លើសពីនេះទៀតព័ត៌មានបែបគុណវិស័យ បានប្រមូលយកតាមការធ្វើសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ និងការពិភាក្សាតាមក្រុមស្នូល ដើម្បីផ្ទៀងផ្ទាត់នឹងការវិភាគបែបពណ៌នាលើលទ្ធផលបានពីអង្កេត។ អ្នកស្រាវជ្រាវបានប្រៀបធៀបគុណប្រយោជន៍ និងគុណវិបត្តិនៃសមាជិកភាពក្នុងអង្គការកសិករ សម្រាប់គ្រួសារមានស្ត្រីជាមេគ្រួ និងគ្រួសារមានបុរសជាមេគ្រួ។ ទោះបីជាមិនអាចសិក្សាពីសមាជិកគ្រួសារជាស្ត្រី និងជាបុរសម្នាក់ៗក្តី ក៏ការសិក្សាពីផលប៉ះពាល់នៃសមាជិកភាពនៅក្នុងអង្គការកសិករ សម្រាប់គ្រួសារមានស្ត្រីជាមេគ្រួសារ អាចជួយកំណត់ពីចន្លោះខ្វះខាតក្នុងការបង្កើតបរិយាកាសអំណោយផល សម្រាប់ការលើកកម្ពស់សមភាពយេនឌ័រ ការពង្រឹងសិទ្ធិអំណាច និងការចូលរួមដ៏មានន័យរបស់ស្ត្រី។

## អត្ថប្រយោជន៍នៃការចូលជាសមាជិកអង្គការកសិករ

ជាទូទៅ សមាជិកអង្គការកសិករទទួលបានផលប្រយោជន៍ពីការសន្សំប្រាក់ជាក្រុម ការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម និងការងារជាក្រុម។ ទិន្នន័យអង្កេតបង្ហាញថា សកម្មភាពចម្បងៗប្រាំរបស់អង្គការកសិករ សម្រាប់ទាំងគ្រួសារមានបុរសជាមេគ្រួ និងមានស្ត្រីជាមេគ្រួ គឺគម្រោងឥណទាននិងការសន្សំប្រាក់ បច្ចេកទេសចិញ្ចឹមសត្វ ការជួញដូរជី បច្ចេកទេសដាំដំណាំនិងដាំបន្លែ និងផលិតកម្មគ្រាប់ពូជ។ គ្រួសារទាំងពីរប្រភេទ មិនមានការយល់ឃើញខុសប្លែកគ្នាគួរឲ្យកត់សម្គាល់ទេចំពោះអង្គការកសិករ ទាំងក្នុងការជឿទុកចិត្ត ការពេញចិត្តនឹងផលប្រយោជន៍ និងការងារជាក្រុម។

## លទ្ធភាពទទួលបានឥណទាន

ពួកសមាជិកប្រើប្រាស់ឥណទានទទួលបានពី អង្គការកសិករ ដើម្បីធ្វើវិនិយោគក្នុងការងារកសិកម្មជាសំខាន់។ នៅតាមតំបន់ជនបទ កសិករមានដីតូចៗកំពុងបង្កើតជាក្រុមជួយខ្លួនឯងបានកាន់តែច្រើនឡើង ដោយក្នុងនោះសមាជិកនានាចូលរួមចំណែកក្នុងការសន្សំប្រាក់ ដើម្បីបង្កើតជាមូលនិធិសហគមន៍មួយដែលអាចឲ្យពួកគេខ្ចីប្រាក់បាន[៤]។ ឥណទាននៅក្នុងក្រុមជួយខ្លួនឯងច្រើនផ្តល់ទៅឲ្យសមាជិកក្រុម សម្រាប់ធ្វើវិនិយោគក្នុងការងារកសិកម្មតែប៉ុណ្ណោះ មានទាំងការទិញធាតុចូលល្អៗ ដូចជា ចំណីសត្វ ជី គ្រាប់ពូជ ជាដើម។ ប៉ុន្តែក្រុមខ្លះអាចមានលទ្ធភាពបង្កើតសេវាឥណទាន សម្រាប់បំពេញតម្រូវការបន្ទាន់របស់សមាជិកក្រុមផងដែរ។ ការដាក់ពាក្យសុំខ្ចីប្រាក់ មានលក្ខខណ្ឌបែបបទសាមញ្ញ ប្រើពេលវេលា និងលិខិតស្នាមតិច ហើយអត្រាការប្រាក់មានកម្រិតទាប បើធៀបនឹងការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

> *យើងអាចទទួលបានកម្ចីយ៉ាងលឿននៅពេលកូនឈឺ។ ឧទាហរណ៍ តួយ៉ាង មានម្តងនោះខ្ញុំគ្មានលុយសម្រាប់ចុះឈ្មោះកូនឲ្យចូលរៀនទេ។ ខ្ញុំបានព្យាយាមខ្ចីពីអ្នកផ្សេង (ប៉ុន្តែ) គេមិនឲ្យខ្ញុំខ្ចីសោះ។ ខ្ញុំបានស្នើទៅក្រុម ហើយសមាជិកក្រុមបានសម្រេចឲ្យខ្ញុំខ្ចីលុយខ្លះ ព្រោះពួកគេយល់ពីស្ថានភាពខ្ញុំ។ (សមាជិកស្ត្រីម្នាក់នៃអង្គការកសិករ នៅខេត្តបាត់ដំបង)*

ប្រាក់កម្ចីជាមធ្យមដែលអង្គការកសិករផ្តល់ឲ្យសមាជិក មានប្រហែល ៣០៦.០០០រៀល (តារាង ១)។ ទឹកប្រាក់នេះតិចខ្លាំងណាស់សម្រាប់ឲ្យ កសិករពង្រីកផលិតកម្មកសិកម្មរបស់ខ្លួន។ ទឹកប្រាក់អប្បបរមាដែលអាចជួយបង្កើនផលិតភាព និងប្រាក់ចំណូលពីការដាំដុះ ឲ្យបានច្រើនគួរសម មិនមានកត់ត្រានៅក្នុងអង្កេតទេ ប៉ុន្តែកសិករមួយចំនួនបានឲ្យដឹងក្នុងពេលសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះថា ពួកគាត់ត្រូវការប្រហែល ២ លានរៀល។ ទោះយ៉ាងនេះក្តី កសិករក្រីក្រនានានៅតែយល់ថា ប្រាក់កម្ចីរបស់អង្គការកសិករមានប្រយោជន៍ចំពោះគាត់ ព្រោះ

[៤] ក្រុមជួយខ្លួនឯង ជាប្រភេទសម្បូរជាងគេនៃអង្គការកសិករនៅកម្ពុជា ហើយជាទូទៅមានសមាជិកតិចជាង ៣០នាក់។ ប្រភេទធំៗ២ទៀត គឺមាន សមាគមកសិករ (សមាជិកលើសពី ៣០នាក់) និងសហករណ៍កសិកម្ម (សមាជិកលើសពី ៣០នាក់ និងបានចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)។ ដោយសារភាពកំហិតផ្នែកពេលវេលា និងធនធាន ការសិក្សានេះប្រើពាក្យអង្គការកសិករ ជាពាក្យរួម តំណាងឲ្យអង្គការទាំងបីប្រភេទនេះ។

តារាង ២៖ ការបណ្ដុះបណ្ដាលពីផលិតកម្មកសិកម្ម ទទួលបានដោយគ្រួសារជាសមាជិកអង្គការកសិករ

| សេវាបណ្ដុះបណ្ដាល/ការណែនាំ | ចំនួនគ្រួសារ | សរុប (% គ្រួសារ) | គ្រួសារស្ដ្រីជាមេគ្រួ (% គ្រួសារស្ដ្រីជាមេគ្រួ) | គ្រួសារបុរសជាមេគ្រួ (% គ្រួសារបុរសជាមេគ្រួ) |
|---|---|---|---|---|
| ស្រូវ/បន្លែ | | | | |
| - ការគ្រប់គ្រងសត្វចង្រៃ និងជំងឺ | 221 | 66.97 | 60.24 | 69.23 |
| - បច្ចេកទេសដាំដំណាំ | 243 | 73.64 | 63.86 | 76.92 |
| - ពូជល្អៗ និងការជ្រើសគ្រាប់ពូជ | 236 | 71.52 | 68.67 | 72.47 |
| - ការប្រើជីគីមី | 186 | 56.36 | 49.40 | 58.70 |
| - ការធ្វើជីកំប៉ុសនិងការគ្រប់គ្រងកាកសំណល់សរីរាង្គ | 234 | 70.91 | 72.79 | 70.45 |
| - ការស្រោចស្រព និងការគ្រប់គ្រងទឹក | 176 | 53.33 | 43.37 | 56.68 |
| បច្ចេកទេសចិញ្ចឹមសត្វ | | | | |
| - ការកែលំអពូជសត្វ | 212 | 64.24 | 56.63 | 66.80 |
| - ការធ្វើជម្រកសត្វ | 232 | 70.3 | 66.27 | 71.66 |
| - ការគ្រប់គ្រងជំងឺ | 215 | 65.15 | 59.04 | 67.21 |
| - ចំណីសត្វ និងការបំប៉ន | 207 | 62.73 | 60.24 | 63.56 |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យអង្កេតរបស់ CDRI ឆ្នាំ២០១១

លក្ខខណ្ឌខ្ចីប្រាក់មិនសូវតឹងតែង។ អង្គការកសិករមួយចំនួនថែមទាំងផ្ដល់កម្ចីមិនយកការប្រាក់ទៀតផង សម្រាប់រយៈពេលខ្លីៗ (សងវិញក្នុងរយៈពេលមួយខែ ឬឆាប់ជាងនេះ)។

គ្រួសារមានស្ដ្រីជាមេគ្រួ ទទួលបានប្រាក់កម្ចីជាមធ្យម ២០៨.០០០រៀល ដែលស្មើនឹង ៦១% នៃប្រាក់កម្ចីផ្ដល់ទៅឱ្យគ្រួសារមានបុរសជាមេគ្រួ ហើយទឹកប្រាក់នេះ នៅតិចខ្លាំងណាស់បើធៀបនឹងទឹកប្រាក់ដែលត្រូវការ សម្រាប់ពង្រីកផលិតកម្មកសិកម្ម។ ម្យ៉ាងទៀត មានគ្រួសារមានស្ដ្រីជាមេគ្រួ (៣៥%) តិចជាង គ្រួសារមានបុរសជាមេគ្រួ (៤១%) ដែលបានខ្ចីប្រាក់សម្រាប់ធ្វើវិនិយោគក្នុងផលិតកម្មផលដំណាំ និងមានគ្រួសារមានស្ដ្រីជាមេគ្រួ ច្រើនជាង គ្រួសារមានបុរសជាមេគ្រួ ដែលប្រើប្រាក់កម្ចីបានពីអង្គការកសិករក្នុងគោលដៅផ្សេងទៀត ក្រៅពីការងារកសិកម្ម។

## ***សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងផលិតកម្មកសិកម្ម***

ទោះបីជាសមាជិកអង្គការកសិករ មិនអាចយល់បានទាំងអស់នូវការណែនាំបង្ហាត់បង្ហាញរបស់មន្ត្រីផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់ពួកគេក្ដី ក៏ពួកគេទទួលបានចំណេះដឹងអនុវត្តជាក់ស្ដែងលើបច្ចេកទេសកសិកម្មមួយចំនួន ដូចជា របៀបធ្វើជីកំប៉ុស និងប្រើជីលាមកសត្វ ការដាំដំណាំសម្រាប់ធ្វើជីធម្មជាតិ របៀបដាំបន្លែ និងការចិញ្ចឹមមាន់ ទា ជ្រូក។ ការពិភាក្សាតាមក្រុមស្នូល ក៏បានបង្ហាញដែរថា សមាជិកអង្គការកសិករមួយចំនួនទទួលបានសេវាបណ្ដុះបណ្ដាលពីទីភ្នាក់ងារផ្ដល់ជំនួយ ខណៈដែលសមាជិកផ្សេងទៀតទទួលបានជំនួយពីទីភ្នាក់ងារផ្ដល់ជំនួយផង[៥] និងពីមន្ទីរកសិកម្មខេត្តផង។

*មន្ទីរកសិកម្មខេត្តផ្ដល់វគ្គបណ្ដុះបណ្ដាលបច្ចេកទេសកសិកម្មទៅឱ្យសមាជិកអង្គការកសិករ យ៉ាងហោចណាស់បីខែម្ដង។ (មន្ត្រីផ្នែកផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ខេត្តស្វាយរៀង)*

កម្មវិធីបណ្ដុះបណ្ដាលដែល សមាជិកអង្គការកសិករតែងទទួលបានញឹកញាប់បំផុត រួមមាន បច្ចេកទេសដាំដំណាំ ពូជដំណាំល្អៗ ផលិតកម្មគ្រាប់ពូជ ការធ្វើជីកំប៉ុស និងការគ្រប់គ្រងកាកសំណល់សរីរាង្គ ព្រមទាំងការធ្វើជម្រកសម្រាប់សត្វចិញ្ចឹមនិងមាន់ទា។ មានស្ដ្រីភាគតិចជាងបុរសដែលទទួលបានអត្ថប្រយោជន៍ផ្ទាល់ពីការបណ្ដុះបណ្ដាលបច្ចេកទេសកសិកម្ម លើកលែងតែការណែនាំអំពីការធ្វើជីកំប៉ុស និងការគ្រប់គ្រងកាកសំណល់សរីរាង្គ (តារាង ២)។

ភាពខុសគ្នានៃ លទ្ធភាពទទួលបានសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម រវាងគ្រួសារមានបុរសជាមេគ្រួសារ និងគ្រួសារមានស្ដ្រីជាមេគ្រួសារ (ទោះបីមិនសូវមានសារៈសំខាន់ខាងស្ថិតិក្ដី) អាចជាលទ្ធផលនៃការរើសអើងដោយអចេតនារបស់ មន្ត្រីផ្ដល់សេវា ចំពោះគ្រួសារមានស្ដ្រីជាមេគ្រួ។ ម្យ៉ាងទៀត គ្រួសារមានស្ដ្រីជាមេគ្រួ ទទួលបានទិន្នផលដំណាំ និងប្រាក់ចំណូលពីការចិញ្ចឹមសត្វ តិចជាង គ្រួសារមានបុរសជាមេគ្រួដែលមានដីកសិកម្មធំជាងផងដែរ (តារាង ៣)។

មន្ត្រីផ្ដល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មខេត្ត បានរាយការណ៍ថា ហេតុផលមួយដែលធ្វើឱ្យគ្រួសារមានស្ដ្រីជាមេគ្រួ ចូលរួមក្នុងការបណ្ដុះបណ្ដាលពីការធ្វើជីកំប៉ុស និងការគ្រប់គ្រងកាកសំណល់សរីរាង្គ ច្រើនជាង ក្នុងវគ្គបណ្ដុះបណ្ដាលផ្សេងទៀត គឺស្ដ្រីមិនមានពេលគ្រប់គ្រាន់ ដើម្បីចូលរួមក្នុងគ្រប់សកម្មភាពរបស់អង្គការកសិករនោះទេ ហើយម្យ៉ាងទៀតបច្ចេកទេសសាមញ្ញទាំងនេះ វាជាប់ទាក់ទងនឹងការងារផ្ទះប្រចាំថ្ងៃផង។

[៥] ទីភ្នាក់ងារផ្ដល់ជំនួយទាំងនោះ ជាអង្គការមិនមែនរដ្ឋាភិបាលដែលផ្ដល់ជំនួយផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសទៅឱ្យអង្គការកសិករ។ អង្គការកសិករខ្លះទទួលជំនួយពីអង្គការមិនមែនរដ្ឋាភិបាល ឬពីមន្ទីរកសិកម្មខេត្ត ហើយខ្លះទៀតទទួលជំនួយពីអង្គភាពទាំងពីរនេះ ជាពិសេសសហករណ៍កសិកម្មព្រោះមន្ទីរកសិកម្មខេត្តមានទំនួលខុសត្រូវជួយដល់ពួកគេ។

តារាង ៣៖ ផលិតកម្មស្រូវ និងសត្វចិញ្ចឹម នៃគ្រួសារជាសមាជិកអង្គការកសិករ

| | ទាំងពីរប្រភេទ | ស្ត្រី | បុរស | t-test |
|---|---|---|---|---|
| ដីដាំស្រូវ(ហិកតា) | 1.60 | 1.10 | 1.80 | -3.04 |
| ទិន្នផលស្រូវក្នុងមួយឆ្នាំ (គីឡូក្រាម/ហិកតា) | 1958 | 1783 | 2015 | -1.57 |
| ចំណូលពីដំណាំស្រូវក្នុងមួយឆ្នាំ (ម៉ឺនរៀល/ហិកតា) | 206.170 | 169 | 219 | -2.22 |
| ចំណាយលើធាតុចូលសម្រាប់ដំណាំស្រូវ*ក្នុងមួយឆ្នាំ (ម៉ឺនរៀល/ហិកតា) | 62 | 61.77 | 61.19 | -0.018 |
| ចំណេញដុលពីដំណាំស្រូវក្នុងមួយឆ្នាំ (ម៉ឺនរៀល/ហិកតា) | 162.53 | 124.85 | 174.93 | -1.89 |
| ចំណូលពីសត្វចិញ្ចឹមក្នុងមួយឆ្នាំ (ម៉ឺនរៀល) | 465.12 | 336.37 | 506.35 | -1.85 |
| ចំណាយលើសត្វចិញ្ចឹមក្នុងមួយឆ្នាំ (ម៉ឺនរៀល) | 75.23 | 34.44 | 88.19 | -0.93 |
| ចំណូលសុទ្ធពីសត្វចិញ្ចឹមក្នុងមួយឆ្នាំ**(ម៉ឺនរៀល) | 389.89 | 301.92 | 417.85 | -1.89 |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យអង្កេតរបស់ CDRI (ឆ្នាំ២០១១)

សម្គាល់៖ ១ ដុល្លារ = ៤០០០រៀល; *មិនរួមបញ្ចូលថ្លៃពលកម្ម; **ចំណូលសុទ្ធ = ចំណូល - ចំណាយលើធាតុចូល

ចំណូលពីដំណាំស្រូវរបស់គ្រួសារមានស្ត្រីជាមេគ្រួ វាទាបជាង ចំណូលពីដំណាំស្រូវរបស់គ្រួសារមានបុរសជាមេគ្រួ (ក្នុងកម្រិតសារៈសំខាន់ផ្នែកស្ថិតិ ៥%) បើទោះជាគ្រួសារទាំងពីរក្រុមទទួលបានទិន្នផលស្រូវប្រហាក់ប្រហែលគ្នាក្តី (តារាង ៣)។ ហេតុផលមួយក្នុងនោះ អាចមកពីផ្ទៃដីដាំស្រូវជាមធ្យមរបស់គ្រួសារមានបុរសជាមេគ្រួសារ វាធំជាង ផ្ទៃដីដាំស្រូវរបស់គ្រួសារមានស្ត្រីជាមេគ្រួ។ បើគិតពីប្រាក់ចំណេញដុលផង[៦] ផលិតកម្មស្រូវរបស់គ្រួសារមានស្ត្រីជាមេគ្រួ មានប្រសិទ្ធភាពតិចជាង ផលិតកម្មស្រូវរបស់គ្រួសារមានបុរសជាមេគ្រួ (ក្នុងកម្រិតសារៈសំខាន់ផ្នែកស្ថិតិ ១០%)។ ចំណុចនេះបង្ហាញថា គ្រួសារមានស្ត្រីជាមេគ្រួសារអាចបង្កើនផលិតកម្មកសិកម្មបាន ប្រសិនបើពួកគេចេះប្រើប្រាស់កាន់តែប្រសើរនូវសេវាផ្នែកផលិតកម្មកសិកម្ម និងមានលទ្ធភាពកាន់តែច្រើនក្នុងការទទួលបានប្រាក់កម្ចីសម្រាប់កែលំអការដាំដុះរបស់ខ្លួន។ ទាក់ទងនឹងផលិតកម្មសត្វចិញ្ចឹមវិញ គ្រួសារមានស្ត្រីជាមេគ្រួសារ ទទួលបានប្រាក់ចំណូលសុទ្ធពីការចិញ្ចឹមសត្វ តិចជាខ្លាំង បើធៀបនឹង គ្រួសារមានបុរសជាមេគ្រួ ទោះបីភាពខុសគ្នានេះមិនសូវមានសារៈសំខាន់ផ្នែកស្ថិតិក្តី។

## បញ្ហាប្រឈមចំពោះអង្គការកសិករ

អង្កេតគ្រួសារ បង្ហាញពី កត្តាមួយចំនួនដែលរាំងស្ទះប្រសិទ្ធភាពរបស់អង្គការកសិករ ក្នុងលក្ខណៈជាយន្តការសម្រាប់លើកកម្ពស់ផលិតភាព និងផ្សារភ្ជាប់កសិករតូចតាចទៅនឹងទីផ្សារ (តារាង ៤)។ កត្តារាំងស្ទះទី១ គឺកង្វះទុន ដែលជាប់ទាក់ទងផ្ទាល់ទៅនឹងចីរភាពនៃអង្គការកសិករ។ មុខងារបឋមរបស់អង្គការកសិករនៅកម្ពុជា គឺពង្រីកការផ្តល់ឥណទានដែលប្រហែលត្រូវពឹងផ្អែកលើហិរញ្ញប្បទានពី អង្គការមិនមែនរដ្ឋាភិបាល ឬទីភ្នាក់ងាររដ្ឋាភិបាល (Nou 2006)។ មានគ្រួសារមានបុរសជាមេគ្រួ (៨៥,៤៣%) ច្រើនជាង គ្រួសារមានស្ត្រីជាមេគ្រួសារ (៧៤,៧%) ដែលយល់ឃើញថា កង្វះឥណទានជាបញ្ហាប្រឈមមួយ។

បញ្ហាទី២ សម្រាប់សមាជិកអង្គការកសិករ គឺដីកសិកម្មមានទំហំតូចពេក។ ស្ត្រីមានមតិបែបនេះច្រើនជាងបុរសបន្តិច ដោយហេតុថា ដីកសិកម្មរបស់គ្រួសារមានស្ត្រីជាមេគ្រួ មានទំហំតូចជាង ដីកសិកម្មរបស់គ្រួសារមានបុរសជាមេគ្រួ។ ដើម្បីប្រើបច្ចេកទេសកសិកម្ម ដែលខ្លួនបានរៀនពីទីភ្នាក់ងារផ្តល់ជំនួយ គ្រួសារជាសមាជិកអង្គការកសិករ ត្រូវមានដីកសិកម្ម។ ជាក់ស្តែងមានអង្គការកសិករខ្លះបានកំណត់ថា សមាជិកត្រូវតែមានដីកសិកម្មរបស់ខ្លួនផ្ទាល់។ គួរកត់សម្គាល់ថា សន្តិសុខដីធ្លី និងការចុះបញ្ជីដីធ្លី ជាបញ្ហាចោទយូរមកហើយនៅកម្ពុជា ហើយកម្មសិទ្ធិដីស្របច្បាប់ ផលិតភាពកសិកម្មក៏ជាប់ទាក់ទងគ្នាដែរ ព្រោះកម្មសិទ្ធិដីមានសុវត្ថិភាព ជំរុញគ្រួសារនានាឲ្យធ្វើវិនិយោគលើកសិកម្ម (Tong 2011)។

អនក្ខរភាពរបស់សមាជិកអង្គការ គឺជាបញ្ហាប្រឈមមួយទៀត ជាពិសេសសម្រាប់គ្រួសារមានស្ត្រីជាមេគ្រួ។ អង្កេត បង្ហាញថា ៤៩,៤០% នៃមេគ្រួសារជាស្ត្រី និង ៨០% នៃមេគ្រួសារជាបុរសចេះអាននិងចេះសរសេរ។ មេគ្រួសារជាស្ត្រីមានការអប់រំជាមធ្យមប្រហែលបីឆ្នាំ រីឯមេគ្រួសារជាបុរស មានការអប់រំជាមធ្យមប្រហែលប្រាំឆ្នាំ។ គ្រួសារទាំងពីរប្រភេទយល់ឃើញស្រដៀងគ្នាថា អនក្ខរភាពជាបញ្ហាចោទមួយមែន។

ទោះបីសមាជិកអង្គការកសិករអាចទទួលបានព័ត៌មាន និងការបណ្តុះបណ្តាលអំពី ផលិតកម្មកសិកម្មផ្តល់ដោយទីភ្នាក់ងារផ្តល់ជំនួយក្តី ក៏មានជាង ៥០% នៃសមាជិកអង្គការកសិករក្នុងអង្កេតបានប្រាប់ថា ព័ត៌មាននិងការបណ្តុះបណ្តាលទាំងនោះមិនសូវមានប្រយោជន៍ទេ។ ស្ត្រី និងបុរស ហាក់យល់ឃើញខុសគ្នាខ្លះក្នុងបញ្ហានេះ ដោយសារមានការងារកសិកម្មខុសគ្នា ប៉ុន្តែអង្កេតរបស់យើងមិនបានពិនិត្យពីកត្តានេះទេ។ ហេតុផលមួយដែលអាចនាំឲ្យសមាជិកអង្គការកសិករ ចាត់ទុកបញ្ហានេះថាសំខាន់ គឺប្រហែលមកពី អង្គការកសិករទាំងឡាយដែលមានការពឹងផ្អែកលើអង្គការមិនមែនរដ្ឋាភិបាលនោះ ត្រូវតែបង្ហាញថា ខ្លួនបានបំពេញតាមរបៀបវារៈរបស់ម្ចាស់ជំនួយហើយ (Couturier *et al.* 2006)។

បញ្ហាប្រឈមសំខាន់បំផុតមួយចំពោះអង្គការកសិករ គឺលទ្ធភាពចូលទៅកាន់ទីផ្សារ ដែលជួយឲ្យផលិតករខ្នាតតូចនៅ

[៦] ចំណេញដុល = (ចំណូល - ចំណាយលើធាតុចូល)/ផ្ទៃដីដាំស្រូវ។

តារាង ៤៖ ការយល់ឃើញពីឧបសគ្គចំពោះអង្គការកសិករ (គិតជា %)

| | គ្រួសារទាំងអស់ | គ្រួសារស្ត្រីជាមេគ្រួ | គ្រួសារបុរសជាមេគ្រួ |
|---|---|---|---|
| កង្វះឥណទាន | 82.73 | 74.7 | 85.43 |
| កង្វះដីកសិកម្ម* | 79.7 | 81.93 | 78.95 |
| អនក្ខរភាព | 79.39 | 80.72 | 78.95 |
| កង្វះការគាំទ្រពីខាងក្រៅ(ការទទួលបានព័ត៌មាននិងសេវាកម្ម) | 70.61 | 65.06 | 72.47 |
| ចំណេះដឹងនិងបច្ចេកទេសពិបាកអនុវត្ត ផ្ដល់ដោយទីភ្នាក់ងារផ្ដល់ជំនួយ | 68.79 | 71.08 | 68.02 |
| ចំណេះដឹងតិចតួចអំពីការធ្វើផែនការ | 63.94 | 61.45 | 64.78 |
| អង្គការកសិករមិនឆ្លើយតបទៅនឹងតម្រូវការរបស់សមាជិក | 62.12 | 61.45 | 62.35 |
| ការអនុវត្តមិនត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុង | 61.21 | 56.63 | 62.75 |
| កង្វះអ្នកដឹកនាំល្អ | 51.82 | 48.19 | 53.04 |
| រចនាសម្ព័ន្ធក្រុមមិនល្អ | 50.3 | 49.4 | 50.61 |
| កង្វះទឹកចិត្តចូលរួមក្នុងសកម្មភាពរួម | 45.15 | 43.37 | 45.75 |
| ការច្រណែនគ្នាក្នុងចំណោមសមាជិក | 38.79 | 43.37 | 37.25 |
| ការចុះបញ្ជីគណនេយ្យនិងការគ្រប់គ្រងហិរញ្ញវត្ថុមិនបានល្អ | 36.36 | 37.35 | 36.03 |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យអង្កេតរបស់ CDRI (ចេញផ្សាយនាពេលឆាប់ៗ)
សម្គាល់៖ *គ្រួសារមួយចំនួនលំបាកនឹងប្រើបច្ចេកទេសដែលគេបង្រៀន ដោយសារគាត់មានដីកសិកម្មតូចពេក។

ជនបទ អាចទទួលបានអត្ថប្រយោជន៍ពីសេដ្ឋកិច្ចមាត្រដ្ឋាន។ ប្រហែល ៨០% នៃគ្រួសារជាសមាជិកអង្គការកសិករ (ទាំងគ្រួសារមានបុរសនិងគ្រួសារមានស្ត្រីជាមេគ្រួ) មិនមានលទ្ធភាពរួមគ្នាក្នុងការទិញធាតុចូល និងលក់ផលិតផលនៅលើទីផ្សារឡើយ ហើយលទ្ធភាពរួមគ្នានេះជាសេវាដ៏សំខាន់ដែលគេរំពឹងថាអង្គការកសិករត្រូវផ្ដល់ឲ្យបាន។ ការពិភាក្សាតាមក្រុមស្នូល និងការសម្ភាសជាមួយអ្នកផ្ដល់ព័ត៌មានគន្លឹះ បានបង្ហាញថា បញ្ហាទំនុកចិត្តមិនមានចោទទេ។ ពួកកសិករបញ្ជាក់ថា ការចូលទៅទីផ្សារជារួម ឬជាបុគ្គល គ្មានអ្វីខុសគ្នាច្រើនទេ ប៉ុន្តែជួនកាលការសម្របសម្រួលការចូលទៅទីផ្សារជារួម វាលំបាកជាងការចូលទៅជាលក្ខណៈបុគ្គល។ បញ្ហានេះជានិន្នាការមួយគួរឲ្យបារម្ភ ហើយអាចនាំឲ្យពួកសមាជិកមានការរិះគន់ថា អង្គការកសិករខ្វះការគាំទ្រពីខាងក្រៅ ខ្វះលទ្ធភាពទទួលបានព័ត៌មាន និងមានការបារម្ភថា រចនាសម្ព័ន្ធក្រុមមានលក្ខណៈអន់ខ្សោយ (តារាង ៤)។

## អនុសាសន៍គោលនយោបាយមួយចំនួន សម្រាប់លើកកម្ពស់ការខារសមរម្យក្នុងកសិកម្ម

ទោះបីជាអង្គការកសិករមួយចំនួន បានបង្កើតយុទ្ធសាស្ត្ររបស់ខ្លួនផ្ទាល់សម្រាប់ផ្ដល់ឥណទាន ទាំងនៅក្នុង និងតាមរយៈអង្គភាពរបស់ខ្លួនក្ដី ក៏រដ្ឋាភិបាលត្រូវបង្កើតឲ្យមានគោលនយោបាយ និងសេវាកម្មផ្ដល់ឥណទានជាក់លាក់ផ្សេងៗ ដើម្បីធានាថាគ្រួសារមានបុរសនិងមានស្ត្រីជាមេគ្រួមានលទ្ធភាពដូចគ្នាដើម្បីទទួលបានឥណទាន។

ការបណ្ដុះបណ្ដាលអំពីផលិតកម្មកសិកម្ម ជាធាតុចូលដ៏ចាំបាច់សម្រាប់ញ៉ាំងឲ្យអង្គការកសិករមានប្រសិទ្ធភាព ហើយវាសំខាន់ខ្លាំងពេកមិនអាចទុកឲ្យអង្គការកសិករ និងរបៀបវារៈរបស់ទីភ្នាក់ងារផ្ដល់ជំនួយនានា គ្រប់គ្រងតែឯងបានទេ។ រដ្ឋាភិបាល ត្រូវមានយុទ្ធសាស្ត្របណ្ដុះបណ្ដាលដ៏សក្តិសិទ្ធិមួយដែលជួយឲ្យអង្គការកសិករ អាចពង្រឹងសេវាកម្មផ្សេងៗផ្ដល់ទៅឲ្យសមាជិកខ្លួន។ ការបណ្ដុះបណ្ដាលទាំងនេះ គួរមានដាក់បញ្ចូលនូវ ព័ត៌មាន និងជំនួយបច្ចេកទេស ទាក់ទងនឹងការធ្វើផែនការ ការផ្សព្វផ្សាយក្នុងទីផ្សារ និងលទ្ធភាពទិញលក់ផលិតផលនៅក្នុងទីផ្សារ។ ម៉្យាងទៀត គួរមានការបណ្ដុះបណ្ដាលជាក់ស្ដែងលើគ្រប់មុខព្រួញនៃផលិតកម្មកសិកម្ម ហើយកម្មវិធីទាំងឡាយគួរបំពេញឲ្យបានតាមតម្រូវការជាក់ស្ដែងរបស់ស្ត្រី ទាំងក្នុងខ្លឹមសារ និងការអនុវត្ត។ ការគិតគូរទៅដល់យេនឌ័រ គួររួមមាន កម្រិតអក្ខរភាពរបស់ស្ត្រី ការរៀបចំការបណ្ដុះបណ្ដាលឲ្យបានស្របតាមទំនួលខុសត្រូវនៅក្នុងគ្រួសារ ដូចជា ពេលម៉ោងដែលស្ត្រីអាចចូលរួមបាន និងរបៀបរៀបចំជួយមើលថែទាំកុមារ។ ស្ត្រី ទំនងត្រូវការនូវការកសាងសមត្ថភាព ដែលជួយលើកទឹកចិត្តពួកគេឲ្យចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលផ្សេងៗ ដើម្បីទទួលបានជំនាញមូលដ្ឋានផ្នែកអាជីវកម្ម និងការចរចា។

ដើម្បីឲ្យខ្លួនកាន់តែមានអត្ថប្រយោជន៍ទ្វេឡើងទៀត អង្គការកសិករត្រូវលើកកម្ពស់លទ្ធភាពរួមគ្នាក្នុងការទិញធាតុចូល និងលក់ផលិតផលនៅលើទីផ្សារ។ ម៉្យាងទៀត ត្រូវមានការទទួលស្គាល់ និងគាំទ្រតួនាទីរបស់ស្ត្រីនៅក្នុងផលិតកម្មកសិកម្ម និងត្រូវមានការផ្ដល់សិទ្ធិអំណាចដល់ទាំងគ្រួសារមានស្ត្រី និងមានបុរសជាមេគ្រួ ឲ្យចូលរួមដោយស្មើភាពគ្នាក្នុងសកម្មភាពនេះ។ ការធ្វើបែបនេះ អាចជួយជំរុញឲ្យមានការផ្លាស់ប្ដូរឈានទៅកាន់កសិកម្មបែបពាណិជ្ជកម្មខ្នាតតូច និងជួយស្ត្រីនៅតាមជនបទឲ្យចេញផុតពីការធ្វើកសិកម្មចិញ្ចឹមពោះ។

## ឯកសារយោង

តទៅទំព័រ ២៧

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស[1]

ផ្នែកនេះរៀបរាប់ពី សូចនាករនៃសេដ្ឋកិច្ចពិភពលោកសំខាន់ៗ និងសេដ្ឋកិច្ចនៅអាស៊ីខាងត្បូង និងខាងកើត។

កំណើនសេដ្ឋកិច្ចនៅអាស៊ី និងប្រទេសឧស្សាហកម្មមួយចំនួន មានស្ថិរភាពឡើងវិញនៅឆ្នាំ២០១២។ ដូច្នេះការងារនៅសល់ត្រូវបន្តដោះស្រាយ គឺការស្តារឡើងវិញនូវទំនុកចិត្តរបស់អ្នកប្រើប្រាស់ និងវិនិយោគិន ឲ្យដល់កម្រិតនៅមុនពេលមានវិបត្តិ និងខ្ពស់ជាងនោះទៀត។ អាស៊ីនៅតែជាកម្លាំងជំរុញកំណើនក្នុងពិភពលោកបន្តទៀត នៅពេលដែលបណ្ដាប្រទេសអភិវឌ្ឍន៍ចម្បងៗកំពុងព្យាយាមងើបឡើងវិញ។

នៅឆ្នាំ២០១២ ផសស ពិត នៅឥណ្ឌូនេស៊ី មានកំណើនជាមធ្យម ៦,០% ទោះបីជាមានការធ្លាក់ចុះបន្តិច ក្នុងត្រីមាសទី៤ ឆ្នាំ២០១២ ដល់ ៦,១% ធៀបនឹង កម្រិត ៦,៥% នៅត្រីមាសដូចគ្នាកាលពីឆ្នាំមុន។ ផសស នៅម៉ាឡេស៊ីកើន ៦,៤% ធៀបនឹងមួយឆ្នាំមុន រីឯ ផសស នៅសិង្ហបុរី ធ្លាក់កំណើនមកត្រឹម ១,៥% ធៀបនឹង ៣,៦% ក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ថៃសម្រេចបានកំណើនប្រចាំឆ្នាំខ្ពស់ណាស់ ដល់ទៅ ១៩,៥% នៅត្រីមាសទី៤ ដោយសារចំណាយប្រើប្រាស់ក្នុងស្រុក និងការនាំចេញកើនឡើងយ៉ាងខ្លាំង។ កំណើននៅចិន ថយចុះ ប៉ុន្តែនៅតែខ្ពស់ដល់ ៧,៩% នៅត្រីមាសទី៤។ ភាពតានតឹងខាងនយោបាយ និងយោធា រវាងចិន និងជប៉ុន លើបញ្ហាកោះតូចៗមួយចំនួន មិនបានធ្វើឲ្យខូចខាតដល់សេដ្ឋកិច្ចចិនទេ ហើយការតាំងចិត្តរបស់ប្រទេសទាំងពីរ ក្នុងការដោះស្រាយជម្លោះដោយសន្តិភាព អាចជះឥទ្ធិពលធ្វើឲ្យកំណើនមានស្ថិរភាព។ នៅត្រីមាសទី៤ កំណើន ផសស ប្រចាំឆ្នាំ នៅហុងកុង ធ្លាក់ចុះមកត្រឹម ២,៥% ធៀបនឹង កម្រិត ៣,០% ក្នុងពេលដូចគ្នាកាលពីឆ្នាំមុន រីឯកំណើន ផសស នៅកូរ៉េ គឺ ១,៦%។

កំណើនក្នុងប្រទេសអ្នកមាន ជាពិសេសនៅតំបន់អឺរ៉ូ នៅតែបន្តឡើងចុះ ដោយសារអន្តរាគមន៍សេដ្ឋកិច្ចមិនបានផ្តល់លទ្ធផលគួរជាទីពេញចិត្ត។ នៅត្រីមាសទី៤ សេដ្ឋកិច្ចតំបន់អឺរ៉ូ បានធ្លាក់ចុះយ៉ាងខ្លាំង ដោយមានកំណើន ផសស អវិជ្ជមាន (-0,៩%) ដល់ទៅ បីត្រីមាសជាបន្តបន្ទាប់ និងកំណើនសូន្យនៅត្រីមាសទី១។ បញ្ហាវិបត្តិធនាគារ បន្តរីករាលដាល ហើយថ្មីៗនេះបានរាលដាលដល់ប្រទេស Cyprus។ កំណើននៅសហរដ្ឋអាមេរិក មានស្ថិរភាពឡើងវិញ ដោយសេដ្ឋកិច្ចមានអត្រាកំណើនប្រចាំឆ្នាំ១,៦%នៅត្រីមាសទី៤និងបានបង្កើតការងារជាច្រើនថែមទៀត។ប៉ុន្តែអ្នកបង្កើតគោលនយោបាយ និងរដ្ឋាភិបាលនៅតែត្រូវចរចាគ្នាដោះស្រាយឲ្យបាននូវ បញ្ហាថវិកាសម្រាប់ឆ្នាំសារពើពន្ធ និងតុល្យភាពថវិកា ដើម្បីរក្សាកំណើនក្នុងរយៈពេលវែង។ ជប៉ុនកំពុងបន្តស្តារ និងកសាងសេដ្ឋកិច្ចឡើងវិញ ប៉ុន្តែកំណើននៅតែបន្តឡើងចុះ។ បញ្ហាបន្ទាន់ៗ រួមមាន កំណើនចំណាយរបស់រដ្ឋាភិបាលទៅលើកម្មវិធីសង្គមកិច្ច សម្រាប់មនុស្សចាស់ជរា កម្មវិធីកសាងឡើងវិញ សម្រាប់តំបន់រងគ្រោះដោយរលកសមុទ្រយក្សស៊ូណាមិ និងជម្លោះដែនដីជាមួយ ចិន កូរ៉េខាងត្បូង និងរុស្ស៊ី។

### អតិផរណាក្នុងពិភពលោក និងអត្រាប្ដូរប្រាក់

ក្នុងពេញមួយឆ្នាំ២០១២ អត្រាអតិផរណានៅប្រទេសភាគច្រើន ស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន។ នៅត្រីមាសទី៤ កំណើនថ្លៃសរុបនៅកម្ពុជាធ្លាក់ចុះដល់ ១,៨% ធៀបនឹងកំណើន ៤,៩% ក្នុងពេលដូចគ្នាកាលពីឆ្នាំមុន។ ប៉ុន្តែថ្លៃប្រេងឥន្ធនៈ និងឧស្ម័ន នៅតែខ្ពស់ដដែល ដែលជះឥទ្ធិពលដល់បន្ទុកចំណាយផលិតកម្មរបស់អាជីវកម្មផ្សេងៗ និងកម្រិតជីវភាពរបស់គ្រួសារនានា។ នៅត្រីមាសទី៤ អតិផរណានៅវៀតណាមធ្លាក់ចុះដល់ ៧,០% ធៀបនឹង អត្រា ១៩,៨% ក្នុងពេលដូចគ្នាកាលពីឆ្នាំមុន។ កំណើនកម្រិតថ្លៃសរុប បណ្ដាលជាសំខាន់មកពី ការដាក់អនុវត្តកញ្ចប់លើកទឹកចិត្តរបស់រដ្ឋាភិបាលដើម្បីសម្រាលការប៉ះទង្គិចពីខាងក្រៅ។ នៅត្រីមាសទី៤ អតិផរណានៅចិន ធ្លាក់ចុះដល់ ២,១% ធៀបនឹង កម្រិត ៤,៦% ក្នុងពេលដូចគ្នាកាលពីឆ្នាំមុន ចំណែកឯនៅហុងកុង វាកើនដល់ ៣,៨%។ នៅត្រីមាសទី៤ ជប៉ុននៅតែបន្តមានបរិត្តផរណា ដែលបានដាក់សម្ពាធបង្កើនអត្រាការប្រាក់ពិត។

នៅត្រីមាសទី៤ ប្រាក់រៀលឡើងថ្លៃ ១,៦% ធៀបនឹងត្រីមាសមុន (១,៩% ធៀបនឹងមួយឆ្នាំមុន) ទល់នឹងប្រាក់ដុល្លារ និង 0,0៤% (0,៨% ធៀបនឹងមួយឆ្នាំមុន) ទល់នឹងប្រាក់ដុងវៀតណាម។ ប្រាក់យ៉េនជប៉ុន ធ្លាក់ថ្លៃ ៣,៤% ធៀបនឹងត្រីមាសមុន (៤,៥% ធៀបនឹងមួយឆ្នាំមុន) ទល់នឹងប្រាក់ដុល្លារ។

### ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

នៅត្រីមាសទី៤ ពោត (US No. 2) ធ្លាក់ថ្លៃ ៥,0% (តែឡើងថ្លៃ ១៤,៨% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ៣១0,៩ដុល្លារ/តោន សណ្ដែកសៀង (US No. 1) ធ្លាក់ថ្លៃ ១១% (ឡើងថ្លៃ ២៧% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ៥៧៧,៨ដុល្លារ/តោន ហើយប្រេងម៉ាសូត (low sulphur No. 2) ធ្លាក់ថ្លៃ ១,0% (ឡើងថ្លៃ ៣,៩% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម 0,៨0ដុល្លារ/លីត្រ។ នៅត្រីមាសទី៤ កៅស៊ូ (SMR 5) ឡើងថ្លៃ ៥,១% ធៀបនឹងត្រីមាសមុន (ប៉ុន្តែធ្លាក់ថ្លៃ ១៩,៦% ធៀបនឹងមួយឆ្នាំមុន) ដល់ ២៩៤១,៥ដុល្លារ/តោន, ប្រេងឆៅ (OPEC spot) ចុះថ្លៃ 0,៧% (ឡើងថ្លៃ ៧,២% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ១0៧,៣ដុល្លារ/ធុង, ហើយ សាំងឡើងថ្លៃ ២,៥% (៧,២% ធៀបនឹងមួយឆ្នាំមុន) ដល់ 0,៧៣ដុល្លារ/លីត្រ។ នៅត្រីមាសទី៤ អង្ករថៃ (Thai 100% B) ឡើងថ្លៃ 0,២% ធៀបនឹងត្រីមាសមុន ដល់ ៥៩៧ដុល្លារ/តោន ប៉ុន្តែ ចុះថ្លៃ ២,២% ធៀបនឹងមួយឆ្នាំមុន។

[1] អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

### តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១២ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 10.2 | 6.8 | 0.1 | - | - | - | - | - | - | - | - | - |
| ឥណ្ឌូណេស៊ី | 6.3 | 6.1 | 4.2 | 6.2 | 6.5 | 6.5 | 6.5 | 6.5 | 6.3 | 6.4 | 6.2 | 6.1 |
| ម៉ាឡេស៊ី | 6.3 | 4.6 | -2.4 | 9.0 | 4.6 | 4.0 | 5.8 | 5.2 | 4.7 | 5.4 | 5.2 | 6.4 |
| សិង្ហបុរី | 7.7 | 1.1 | -4.5 | 14.7 | 8.3 | 0.9 | 5.9 | 3.6 | 1.6 | 1.9 | 0.3 | 1.5 |
| ថៃ | 4.9 | 2.6 | 3.3 | 7.9 | 3.0 | 2.6 | 3.5 | -9.0 | 0.0 | 4.2 | 3.3 | 19.5 |
| វៀតណាម | 8.5 | 6.2 | 4.7 | 6.7 | 5.4 | 5.7 | 7.2 | 6.1 | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 11.9 | 9.0 | 8.2 | 10.4 | 9.7 | 9.5 | 9.1 | 8.9 | 8.1 | 7.6 | 7.4 | 7.9 |
| ហុងកុង | 6.4 | 2.4 | -3.2 | 6.9 | 7.2 | 5.1 | 4.3 | 3.0 | 4.2 | 3.6 | 1.3 | 2.5 |
| កូរ៉េខាងត្បូង | 4.9 | 2.2 | -1.0 | 6.1 | 4.2 | 3.4 | 3.4 | 3.4 | 3.0 | 2.4 | 1.5 | 1.6 |
| តៃវ៉ាន់ | 5.2 | 0.1 | -3.6 | 11.1 | 6.5 | 4.9 | 3.4 | 1.9 | 0.4 | -0.2 | 1.0 | 3.7 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.9 | 0.9 | -3.8 | 1.6 | 2.5 | 1.6 | 1.4 | 0.7 | 0.0 | -0.4 | -0.6 | -0.9 |
| ជប៉ុន | 2.0 | -0.7 | -5.4 | 4.1 | -1.0 | -1.0 | 0.0 | -1.0 | 2.8 | 3.5 | 0.1 | 0.5 |
| សហរដ្ឋអាមេរិក | 2.2 | 1.1 | -2.5 | 2.7 | 2.3 | 1.5 | 1.6 | 1.6 | 2.1 | 2.2 | 2.5 | 1.6 |

*Sources: International Monetary Fund, Economist and countries' statistic offices.*

### តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១២ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 10.5 | 19.7 | -0.5 | 4.1 | 3.6 | 6.2 | 6.7 | 4.9 | 5.5 | 2.9 | 1.6 | 1.8 |
| ឥណ្ឌូណេស៊ី | 6.4 | 10.1 | 4.7 | 5.1 | 6.8 | 5.9 | 4.7 | 4.1 | 3.8 | 4.5 | 4.5 | 4.4 |
| ម៉ាឡេស៊ី | 2.0 | 5.3 | 0.4 | 1.7 | 2.8 | 3.3 | 3.4 | 3.2 | 2.3 | 1.7 | 1.4 | 1.3 |
| សិង្ហបុរី | 2.1 | 6.5 | 0.5 | 2.9 | 5.2 | 4.7 | 5.5 | 5.5 | 4.9 | 5.2 | 4.2 | 4.0 |
| ថៃ | 2.2 | 5.5 | -0.9 | 3.1 | 3.0 | 4.1 | 4.1 | 4.0 | 3.4 | 2.6 | 2.9 | 3.2 |
| វៀតណាម | 8.3 | 23.3 | 7.3 | 9.0 | 12.8 | 19.4 | 22.5 | 19.8 | 16.0 | 8.6 | 5.6 | 7.0 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 4.8 | 5.9 | -0.8 | 3.2 | 5.1 | 5.7 | 6.3 | 4.6 | 3.8 | 2.9 | 1.9 | 2.1 |
| ហុងកុង | 2.0 | 4.3 | -0.3 | 2.4 | 4.0 | 5.1 | 6.5 | 5.7 | 5.2 | 4.2 | 3.1 | 3.8 |
| កូរ៉េខាងត្បូង | 2.5 | 4.6 | 2.8 | 3.0 | 4.4 | 4.2 | 4.8 | 4.1 | 2.9 | 2.4 | 1.6 | 1.7 |
| តៃវ៉ាន់ | 1.8 | 3.2 | -1.1 | 1.0 | 1.3 | 1.6 | 1.3 | 1.4 | 1.3 | 1.6 | 3.0 | 1.9 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.1 | 3.3 | 0.4 | 1.6 | 2.5 | 2.7 | 2.7 | 2.9 | 2.7 | 2.5 | 2.5 | 2.3 |
| ជប៉ុន | 0.1 | 1.4 | -1.3 | -0.7 | 0.0 | 0.3 | 0.2 | -0.3 | 0.3 | 0.2 | -0.4 | -0.2 |
| សហរដ្ឋអាមេរិក | 2.9 | 3.8 | -0.4 | 1.7 | 2.1 | 3.5 | 3.8 | 3.3 | 2.8 | 1.9 | 1.7 | 1.9 |

*Sources: International Monetary Fund, Economist and National Institute of Statistics.*

### តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៧-២០១២ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4062.7 | 4054.2 | 4140.5 | 4187.1 | 4041.9 | 4044.9 | 4095.7 | 4071.9 | 4046.0 | 4054.3 | 4060.2 | 3995.9 |
| ឥណ្ឌូណេស៊ី (រូពីយ៉ា) | 9419.0 | 9699.0 | 10413.8 | 9089.9 | 8902.0 | 8593 | 8625.8 | 8985.7 | 9078.6 | 9281.3 | 9490.3 | 9614.6 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.3 | 3.3 | 3.5 | 3.2 | 3.1 | 3.0 | 3.0 | 3.2 | 3.1 | 3.1 | 3.1 | 3.1 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.5 | 1.4 | 1.5 | 1.4 | 1.3 | 1.2 | 1.2 | 1.3 | 1.3 | 1.3 | 1.6 | 1.2 |
| ថៃ (បាត) | 32.2 | 33.4 | 34.3 | 31.7 | 30.6 | 30.3 | 30.2 | 31.0 | 31.0 | 31.3 | 31.3 | 30.7 |
| វៀតណាម (ដុង) | 16,030.0 | 16,382.0 | 17,725.2 | 19,200.8 | 20,2738 | 20,693.6 | 20,699.6 | 20,997.7 | 20,971.2 | 20849.7 | 20847.5 | 20839.3 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ៉ន់) | 8.0 | 6.9 | 6.8 | 6.76 | 6.6 | 6.5 | 6.4 | 6.36 | 6.3 | 6.3 | 6.4 | 6.2 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.8 | 7.77 | 7.8 | 7.8 | 7.8 | 7.78 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 929.0 | 1137.2 | 1277.8 | 1156.3 | 1120.2 | 1084.3 | 1084.9 | 1144.87 | 1131.2 | 1152.6 | 1132.9 | 1089.9 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 32.9 | 31.5 | 33.0 | 31.3 | 29.3 | 28.9 | 29.2 | 30.26 | 29.7 | 29.6 | 29.8 | 29.2 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.7 | 0.8 | 0.7 | 0.8 | 0.7 | 0.7 | 0.7 | 0.74 | 0.8 | 0.8 | 0.8 | 0.8 |
| ជប៉ុន (យ៉េន) | 117.8 | 102.5 | 93.6 | 87.8 | 82.3 | 81.7 | 77.9 | 77.78 | 79.3 | 80.1 | 78.6 | 81.3 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

### តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៧-២០១២ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ពោត (US No. 2) - USA (USD/តោន) | 149.08 | 218.15 | 167.31 | 169.90 | 280.3 | 311.6 | 302.8 | 270.8 | 277.5 | 270.5 | 327.1 | 310.9 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 707.68 | 912.23 | 686.84 | 834.75 | 1251.0 | 1147.0 | 1079.0 | 1024.7 | 1106.7 | 1083.3 | 993.0 | 809.3 |
| កៅស៊ូ SMR 5 (USD/តោន) | 2202.30 | 2586.30 | 1884.84 | 3152.17 | 5278.0 | 4968.8 | 4617.6 | 3658.0 | 3701.2 | 3361.0 | 2799.2 | 2941.5 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 305.36 | 615.32 | 524.47 | 456.67 | 528.3 | 514.3 | 581.3 | 610.3 | 549.0 | 600.3 | 595.7 | 597.0 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 294.59 | 460.41 | 414.03 | 375.38 | 537.2 | 525.7 | 514.0 | 454.8 | 490.8 | 546.5 | 649.4 | 577.8 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 69.25 | 95.44 | 60.50 | 71.61 | 100.7 | 113.3 | 108.9 | 109.1 | 117.3 | 106.7 | 106.6 | 107.3 |
| សាំង - US Gulf Coast (សេន/លីត្រ) | 53.58 | 62.22 | 42.91 | 49.83 | 67.9 | 78.7 | 74.6 | 68.5 | 79.0 | 74.0 | 71.6 | 73.4 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 55.51 | 76.20 | 43.05 | 51.62 | 72.5 | 75.7 | 77.3 | 77.3 | 83.8 | 77.8 | 81.1 | 80.3 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច-ស្ថានភាពក្នុងប្រទេស[1]

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

ទោះបីមានការយឺតយ៉ាវក្នុងវិស័យមួយចំនួនក្តី ក៏សេដ្ឋកិច្ចកម្ពុជាជារួម នៅតែមានកំណើនមាំទាំនិងរស់រវើកនៅឆ្នាំ២០១២ ដោយមានអត្រាកំណើនរំពឹងទុកប្រមាណ ៧,៣%។ ទោះយ៉ាងណាក៏ដោយ កម្ពុជាត្រូវតែប្រយ័ត្នប្រយែងធានាឲ្យបាននូវលក្ខណៈប្រកួតប្រជែង នៅចំពោះមុខភាពមិនប្រាកដប្រជា និងភាពងាយរងគ្រោះនៃសេដ្ឋកិច្ចពិភពលោក ជាពិសេសនៅតំបន់អឺរ៉ូ និងសហរដ្ឋអាមេរិក។

នៅត្រីមាសទី៤ ឆ្នាំ២០១២ វិនិយោគគិតជាទ្រព្យសកម្មជាប់លាប់អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កើន ១៦៩,៧% ធៀបនឹងត្រីមាសមុន ប៉ុន្តែធ្លាក់ចុះ ១៣,៦% ធៀបនឹងមួយឆ្នាំមុន មកត្រឹម ១,១ពាន់លានដុល្លារ។ វិនិយោគក្នុងវិស័យកសិកម្ម ធ្លាក់ចុះ ៣៦,៧% ធៀបនឹងត្រីមាសមុន (៧៤% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ១១៤,៦លានដុល្លារ ទោះបីរដ្ឋាភិបាលកាន់តែយកចិត្តទុកដាក់ប្រឹងលើកកម្ពស់ ភាពប្រកួតប្រជែង និងផលិតភាពក្នុងវិស័យនេះក្តី។ ឧស្សាហកម្មនៅតែជាកម្លាំងចម្បងមួយជំរុញកំណើន ផសស ជាពិសេសការនាំចេញ។ វិនិយោគក្នុងវិស័យនេះកើន ១២,៣% ធៀបនឹងមួយឆ្នាំមុន។ វិនិយោគក្នុងផ្នែកកាត់ដេរសម្លៀកបំពាក់ ដែលជាផលិតផលកម្មន្តសាលចម្បងគេ កើន ៤២,៦% ធៀបនឹងត្រីមាសមុន (២៨,៨% ធៀបនឹងមួយឆ្នាំមុន) ដល់ ១៥២,៩ លានដុល្លារ។ វិស័យទេសចរណ៍ ក៏មានលក្ខណៈរឹងមាំដែរ ដោយបានទាក់ទាញវិនិយោគក្នុងផ្នែកសណ្ឋាគារ និងអាជីវកម្មពាក់ព័ន្ធនឹងទេសចរណ៍ មានតម្លៃសរុប ៦៤០,៦លានដុល្លារ ឬកើន ១៤៩,៣% បើធៀបនឹងមួយឆ្នាំមុន។

វិស័យសំណង់ ជាសសរស្តម្ភមួយនៃកំណើនសេដ្ឋកិច្ច ដែលទទួលរងផលប៉ះពាល់ពីវិបត្តិហិរញ្ញវត្ថុសកល និងមានការរើបឡើងវិញយឺតៗ។ តម្លៃគម្រោងសាងសង់សរុបនៅត្រីមាសទី៤ ធ្លាក់ចុះ ៦៥,៨% ធៀបនឹងត្រីមាសមុន (៥៩,៧% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ៥៩,៩លានដុល្លារ ក្នុងនោះ គម្រោងភូមិគ្រឹះនិងផ្ទះធ្លាក់ចុះ៥៣,៦%(៨៦%ធៀបនឹងមួយឆ្នាំមុន)មកត្រឹម ៨,៥លានដុល្លារ គម្រោងផ្ទះល្វែង ធ្លាក់ចុះ ៨៣,៤% (៨២,៦% ធៀបនឹងមួយឆ្នាំមុន)មកត្រឹម១០,២លានដុល្លារ។នៅឆ្នាំ២០១២ មានភ្ញៀវបរទេស ប្រហែល ៣,៥លាននាក់ មកទស្សនាកម្ពុជា ហើយនៅត្រីមាសទី៤ នេះ ចំនួនភ្ញៀវបរទេស កើន ២២,៦% បើធៀបនឹងត្រីមាសមុន (២៦,៣% ធៀបនឹងមួយឆ្នាំមុន)។ ភ្ញៀវទេសចរមកដល់តាមផ្លូវអាកាស កើន ៣៥,១% (១៦,៣% ធៀបនឹងមួយឆ្នាំមុន) រីឯ ភ្ញៀវមកដល់តាមផ្លូវគោក និងផ្លូវទឹក កើន ១២,៤% (៣៨,២% ធៀបនឹងមួយឆ្នាំមុន)។

ការនាំចេញនៅតែមាំទាំដដែល ទោះបីមានការឡើងចុះតាមត្រីមាសក្តី។ នៅត្រីមាសទី៤ ការនាំចេញសរុប កើន ៩,៩% ធៀបនឹងពេលដូចគ្នាកាលពីឆ្នាំមុន ដល់ ១,៤ពាន់លានដុល្លារ។ វិស័យកាត់ដេរ ដែលរួមចំណែក ៧៨,៤% នៃតម្លៃនាំចេញសរុបនោះ បានកើន ១,០% ដល់ ១,១ពាន់លានដុល្លារ ក្នុងនេះមាន ៤០% បាននាំចេញទៅសហរដ្ឋអាមេរិក, ៣៧% ទៅសហភាពអឺរ៉ុប, ០,៨% ទៅបណ្តាប្រទេសអាស៊ាន និង ៣,៧% ទៅជប៉ុន។ ទោះបីការនាំចេញផលិតផលកសិកម្មដែលមានកៅស៊ូ និងស្រូវជាសំខាន់ បានកើន ១៨,២% ធៀបនឹងមួយឆ្នាំមុនក្តី ក៏ចំណែកផលិតផលកសិកម្មនៅក្នុងតម្លៃនាំចេញសរុប នៅមានតិច (៣,០%) បើធៀបនឹងផលិតផលនាំចេញដទៃទៀត។ នៅត្រីមាសទី៤ ការនាំចូលសរុប កើន ១៣,២% ធៀបនឹងមួយឆ្នាំមុន ក្នុងនេះ ការនាំចូលប្រេងម៉ាស៊ូត កើន ៣២,៦% ការនាំចូលបរិក្ខារសំណង់ កើន ៣៨,៣% រីឯការនាំចូលប្រេងសាំង ធ្លាក់ចុះ ៣,៧%។

## ហិរញ្ញវត្ថុសាធារណៈ

កំណើនមធ្យោបាយសារពើពន្ធ តាមរយៈការពង្រឹងការប្រមូលចំណូល ចាំបាច់ខ្លាំងណាស់ចំពោះរដ្ឋាភិបាល និងសេដ្ឋកិច្ច។ សញ្ញាមួយបង្ហាញពីភាពរីកចម្រើន គឺ កំណើនប្រាក់ចំណូលរដ្ឋាភិបាលពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេស ចំណូលចរន្តក្នុងទូទាំងឆ្នាំ២០១២។ នៅត្រីមាសទី៤ ចំណូលសរុប កើន ៦,១% ធៀបនឹងត្រីមាសមុន (១៣,៥% ធៀបនឹងមួយឆ្នាំមុន) ដល់ ២០១៧ពាន់លានរៀល។ ចំណូលចរន្ត កើន ១០,៩% (១៤,៥% ធៀបនឹងមួយឆ្នាំមុន) ចំណូលពន្ធ កើន ៥,៦% (១៣,៤% ធៀបនឹងមួយឆ្នាំមុន) ហើយចំណូលមិនមែនពន្ធ កើន ៤៦,២% (២០,៦% ធៀបនឹងមួយឆ្នាំមុន)។ ចំណូលមូលធន ធ្លាក់ចុះ ៧៧,១% (៣៤,៥% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ២៣,៩ពាន់លានរៀល ដែលអាចនឹងប៉ះពាល់ដល់គម្រោងហេដ្ឋារចនាសម្ព័ន្ធមួយចំនួន។ ការថយចុះចំណាយរដ្ឋាភិបាលនៅត្រីមាសទី៤ ឆ្លុះបញ្ចាំងពីកិច្ចប្រឹងប្រែងបំបាត់ការខ្ជះខ្ជាយក្នុងចំណាយរបស់រដ្ឋាភិបាល។ ចំណាយសរុប ធ្លាក់ចុះ ៦,៨% ធៀបនឹងត្រីមាសមុន (១១,៧% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ២៧៥១,៥ពាន់លានរៀល។ ចំណាយមូលធន ធ្លាក់ចុះ ១៤,៨% (២៩,៦% ធៀបនឹងមួយឆ្នាំមុន), ចំណាយលើបៀវត្សរ៍ ធ្លាក់ចុះ ៩,៥% (២,២% ធៀបនឹងមួយឆ្នាំមុន) ហើយ ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច ធ្លាក់ចុះ ៩,០% (១៣,៧% ធៀបនឹងមួយឆ្នាំមុន)។

[1] អត្ថបទនេះរៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

## អតិផរណា និងអត្រាប្តូរប្រាក់បរទេស

នៅត្រីមាសទី៤ អតិផរណា ស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន ដោយធ្លាក់ចុះមកត្រឹម ១,៨% ធៀបនឹង ៤,៩% នៅត្រីមាសដូចគ្នាកាលពីឆ្នាំមុន។ សន្ទស្សន៍ថ្លៃម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា កើន ១,៤% ថ្លៃដឹកជញ្ជូន កើន ១,២% ធៀបនឹងមួយឆ្នាំមុន។ ក្នុងត្រីមាសនេះដែរ ប្រាក់រៀល ឡើងថ្លៃ ១,៦% ធៀបនឹងត្រីមាសមុន (១,៩% ធៀបនឹងមួយឆ្នាំមុន) ទល់នឹងប្រាក់ដុល្លារ។ មាស ឡើងថ្លៃ ៤,១% (១,៣% ធៀបនឹងមួយឆ្នាំមុន) ដល់ ២០៦,៥ដុល្លារ/ជី ប្រេងម៉ាស៊ូត ឡើងថ្លៃ ២,៩% (៤,៥% ធៀបនឹងមួយឆ្នាំមុន) ដល់ ៥១២៩រៀល/លីត្រ ហើយប្រេងសាំងឡើងថ្លៃ ០,៨% (៣,៦% ធៀបនឹងមួយឆ្នាំមុន) ដល់ ៥២៩៥ រៀល/លីត្រ។

## ការវិវត្តរូបិយវត្ថុ

នៅត្រីមាសទី៣ ទ្រព្យសកម្មបរទេសសុទ្ធ ធ្លាក់ចុះ ០,០៣% ធៀបនឹងត្រីមាសមុន (កើន ៥,៨% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ១៨.៧២៣,៦ពាន់លានរៀល។ ទ្រព្យសកម្មក្នុងស្រុកសុទ្ធ កើន ១០% (៧៥,៦% ធៀបនឹងមួយឆ្នាំមុន) ដល់ ៨៧១៧,២ពាន់លានរៀល។ សាច់ប្រាក់ងាយស្រួលសរុប កើន ២១,១% ធៀបនឹងមួយឆ្នាំមុន រូបិយវត្ថុ កើន ៧,៦% ហើយ រូបិយវត្ថុផ្សេងៗ កើន ២៣,៨%។

## ស្ថានភាពក្រីក្រ

អង្កេតប្រចាំត្រីមាសរបស់វិទ្យាស្ថាន CDRI លើពលករងាយរងគ្រោះ ធ្វើឡើងក្នុងខែកុម្ភៈ បង្ហាញថា មានតែប្រាក់ចំណូលរបស់អ្នកលក់បន្លែតូចតាចប៉ុណ្ណោះ ដែលបានធ្លាក់ចុះ បើធៀបនឹងខែកុម្ភៈឆ្នាំមុន។ ពលករ ៩ក្រុមផ្សេងទៀត មាន អ្នកជាក់ស៊ីក្លូ អ្នកលីសែង អ្នករើសអេតចាយ អ្នករត់តុភោជនីយដ្ឋាន អ្នកស៊ីឈ្នួលធ្វើស្រែ កម្មកររោងចក្រកាត់ដេរ អ្នករត់ម៉ូតូឌុប និងកម្មករសំណង់មានជំនាញ និងគ្មានជំនាញ សុទ្ធតែមានប្រាក់ចំណូលខ្ពស់ជាងមុន។

ប្រាក់ចំណូលមធ្យមប្រចាំថ្ងៃរបស់ អ្នកស៊ីឈ្នួលធ្វើស្រែ កើនក្នុងអត្រាខ្ពស់បំផុត គឺ ២៤% ដល់ ៥៨២៨រៀល ប៉ុន្តែពួកគេប្រើវាអស់ជិត ៥៤% ទៅលើចំណាយប្រចាំថ្ងៃ។ គ្រប់គ្នាក្នុងក្រុមនេះ មានដីដាំដុះតិចជាងបីហិកតា ហើយមាន ៦៨% ប្រាប់ថា ការងារធ្វើស្រែជាប្រភពចំណូលចម្បងរបស់គ្រួសារខ្លួន។

ចំណូលប្រចាំថ្ងៃរបស់អ្នករើសអេតចាយ ធ្លាក់ចុះ ៩,៣% ធៀបនឹងកាលពីបីខែមុន ប៉ុន្តែកើន ១៩% ធៀបនឹងមួយឆ្នាំមុន ដល់ ៩៨៨៣រៀល។ របស់អេតចាយ បានធ្លាក់ថ្លៃ រីឯចំនួនអ្នករើសអេតចាយ បានកើនឡើង។ ក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ មាន ៧០% ប្រាប់ថា បានខ្ចីបុលគេដើម្បីដោះស្រាយចំណាយចិញ្ចឹមជីវិត។ ពួកគេចំណាយអស់ ៦៨% នៃប្រាក់ចំណូលទៅលើការចាយវាយប្រចាំថ្ងៃដោយមិនរាប់បញ្ចូលការបង់ថ្លៃការប្រាក់ និងចំណាយលើការព្យាបាលជំងឺទេ។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកលីសែង កើន ៩,៤% ធៀបនឹងបីខែមុន ឬ ១៨% ធៀបនឹងមួយឆ្នាំមុន ដល់ ១២.៧៨៤រៀល។ ក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ ៤០នាក់ មាន ៨៥% បានចាកចេញពីគ្រួសារដើម្បីមកធ្វើការនៅភ្នំពេញ។ ក្នុងចំណោមពលករទាំងនេះ មាន ១០% រស់នៅតាមចិញ្ចើមថ្នល់ ឬនៅតាមវត្ត ហើយអ្នកក្រៅពីនោះ ជួលផ្ទះស្នាក់នៅ។ បន្ទាប់ពីការចាយវាយប្រចាំថ្ងៃ ពួកគេស្ទើរមិនមាននៅសល់លុយសម្រាប់សន្សំទេ។

នៅខែកុម្ភៈ ប្រាក់ចំណូលរបស់អ្នករត់ម៉ូតូឌុប កើន ១៨% ធៀបនឹងមួយឆ្នាំមុន ឬ ១,១% ធៀបនឹងបីខែមុន ដល់ ១៤.៤២៧ រៀល។ អ្នករត់ម៉ូតូឌុបទាំងនេះ ជាប្រភពប្រាក់ចំណូលចម្បងក្នុងគ្រួសារខ្លួន ហើយបានចេញមកនៅទីក្រុងតែម្នាក់ឯង ក្នុងនេះមាន ៥៨% ត្រូវជួលផ្ទះស្នាក់នៅ, ២៣% មានផ្ទះផ្ទាល់ខ្លួន ហើយក្រៅពីនោះ មកស្នាក់នៅជាមួយសាច់ញាតិ ឬនៅតាមវត្ត។

ប្រាក់ចំណូលរបស់កម្មករសំណង់មានជំនាញ កើន ៩,៦% ធៀបនឹងមួយឆ្នាំមុន ប៉ុន្តែធ្លាក់ចុះ ៤,៤% ធៀបនឹងបីខែមុន។ សកម្មភាពសំណង់បានរីកដុះដាល ប៉ុន្តែចំនួនកម្មករក៏កើនឡើងដែរ។ ទោះយ៉ាងនេះក្តី មាន ៩០% បានគិតថា ខ្លួនមានជីវភាពប្រសើរជាងមុន។ ប្រាក់ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់គ្មានជំនាញ កើន ១៨% ធៀបនឹងមួយឆ្នាំមុន និង ១៥% ធៀបនឹងបីខែមុន។ ទោះបីជា ៦៨% នៃកម្មករទាំងនេះត្រូវជួលផ្ទះគេស្នាក់នៅក្តី ក៏ពួកគេអាចទ្រទ្រង់ជីវភាពបាននៅទីក្រុងភ្នំពេញ ហើយអាចផ្ញើប្រាក់ខ្លះទៅឲ្យគ្រួសារខ្លួនទៀតផង។

ចំណូលរបស់អ្នកលក់បន្លែតូចតាច កើន ៤៩% ធៀបនឹងបីខែមុន ប៉ុន្តែធ្លាក់ចុះ ១៩% បើធៀបនឹងមួយឆ្នាំមុន មកត្រឹម ៩៩៥៨រៀល។ ពួកគេប្រាប់ថា ចំនួនអ្នកលក់បន្លែបានកើនឡើង ហើយពួកគេមិនអាចពង្រីកអាជីវកម្មរបស់ខ្លួនបានទេ ដោយសារបញ្ហាកង្វះដើមទុន។ ទោះជាយ៉ាងនេះក្តី ពួកគេអាចសន្សំប្រាក់បានមួយចំនួន បន្ទាប់ពីការដោះស្រាយចំណាយប្រចាំថ្ងៃដែលស្មើនឹង ៦៣% នៃប្រាក់ចំណូល។ ពួកគេ មានជីវភាពប្រសើរជាងមុន ដោយសាររបរលក់ដូររបស់ខ្លួន។

នៅខែកុម្ភៈ ចំណូលរបស់កម្មកររោងចក្រកាត់ដេរ កើន ៤,៧% ធៀបនឹងបីខែមុន ឬ ១៧% បើធៀបនឹងមួយឆ្នាំមុន ដល់ ១០.០០០រៀល។ ក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ទាំង ១២០នាក់ មាន ៥៥% មានមុខងារខាងដេរ, ១៣% ជាអ្នកត្រួតពិនិត្យគុណភាព ហើយអ្នកក្រៅពីនោះ មិនបានប្រាប់ពីមុខងារខ្លួនទេ។ ពួកគេសន្សំប្រាក់បានជាមធ្យម ២០០.០០០រៀល/ខែ ហើយផ្ញើវាទៅឲ្យក្រុមគ្រួសារ។ កម្មករទាំងនេះប្រាប់ថា ពួកគេធ្វើការជាមធ្យម ៥៨ម៉ោង/សប្តាហ៍ ហើយចង់បានម៉ោងការងារបន្ថែមទៀត ដើម្បីបានចំណូលកាន់តែច្រើន។

# តាមដានសេដ្ឋកិច្ច-សូចនាករ

## តារាង១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៧-១២*

| | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 135.6 | 92.0 | 615.0 | 530.68 | 4.1 | 156.4 | 123.9 | 440.6 | 154.7 | 81.2 | 181.1 | 114.6 |
| ឧស្សាហកម្ម | 709.1 | 724.9 | 818.5 | 403.66 | 67.1 | 257.1 | 2361.0 | 174.9 | 208.7 | 173.7 | 245.6 | 196.5 |
| *កាត់ដេរ* | *170.7* | *142.8* | *90.1* | *122.81* | *57.1* | *108.4* | *109.7* | *118.7* | *139.4* | *97.5* | *107.2* | *152.9* |
| សេវាកម្ម | 1742.5 | 10,003.2 | 4432.0 | 1337.34 | 209.5 | 2229.2 | 264.1 | 722.6 | 50.9 | 18.0 | 2.1 | 845.6 |
| *សណ្ឋាគារ និងទេសចរណ៍* | *1048.3* | *8758.1* | *3980.1* | *1105.14* | *107.9* | *2221.9* | *264.1* | *257.0* | *50.9* | *0.0* | *0.0* | *640.6* |
| សរុប | 2587.2 | 10,570.9 | 5865.5 | 2271.7 | 280.2 | 2642.7 | 2748.9 | 1338.1 | 414.4 | 273.0 | 428.8 | 1156.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | -77 | 8.41 | -4 | -51.3 | -69 | -33.9 | 55.6 | 169.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -32 | 308.6 | -44.5 | -61.3 | -24.8 | 643.2 | 753 | 9.6 | 48.4 | -89.6 | -84.4 | -13.6 |

** Including expansion project approvals. Source: Cambodian Investment Board*

## តារាង២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៧-១២

| | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 79.1 | 154.7 | 64.3 | 36.2 | 4.1 | 5.9 | 106.3 | 60.9 | 64.8 | 66.6 | 18.3 | 8.5 |
| ផ្ទះល្វែង | 297.2 | 221.6 | 149.6 | 183.8 | 16.1 | 22.8 | 90.0 | 58.5 | 60.8 | 219.3 | 61.6 | 10.2 |
| ផ្សេងៗ | 259.6 | 740.9 | 227.3 | 269.7 | 23.6 | 48.7 | 51.1 | 29.3 | 197.2 | 47.8 | 94.9 | 41.2 |
| សរុប | 635.8 | 1117.0 | 441.2 | 489.8 | 43.8 | 77.4 | 247.4 | 148.7 | 322.8 | 333.6 | 174.9 | 59.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 76.7 | 219.7 | -39.9 | 117.1 | 3.3 | -47.6 | -65.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 96.7 | 75.7 | -60.5 | 11 | -14.8 | -61.7 | 215.6 | 40.29 | 637.1 | 331.1 | -29.3 | -59.7 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង៣. ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៧-១២

| | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 1296.5 | 1239.4 | 1111.7 | 1304.3 | 4.1 | 286.9 | 335.3 | 430.7 | 513.6 | 317.1 | 370.5 | 500.7 |
| តាមផ្លូវគោក និងទឹក | 718.6 | 881.9 | 999.7 | 1094.6 | 16.1 | 319.6 | 364.5 | 366.3 | 481.5 | 424.3 | 450.3 | 506.1 |
| សរុប | 2015.1 | 2121.3 | 2111.5 | 2398.9 | 23.6 | 606.5 | 699.8 | 797.1 | 995.2 | 761.4 | 820.9 | 1006.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | -22.1 | 15.4 | 13.9 | 24.9 | -23.5 | 7.8 | 22.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 28.4 | 5.3 | 0.5 | 13.6 | -14.8 | 12.8 | 20.2 | 13.0 | 27.8 | 25.5 | 17.3 | 26.3 |

*Source: Ministry of Tourism*

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៧-១២

| | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | | | | | | | លានដុល្លារ | | | | | |
| ការនាំចេញសរុប | 3050.3 | 3097.8 | 2901.6 | 3630.2 | 1017.7 | 1132 | 1455.6 | 1324.2 | 1280.1 | 1775.9 | 1595.8 | 1454.7 |
| ក្នុងនេះ៖ សម្លៀកបំពាក់ | 2938.9 | 2986.2 | 2565.3 | 3223.4 | 880.48 | 964.15 | 1285.71 | 1129.23 | 1070.8 | 1474.7 | 1329.1 | 1140.83 |
| *- សហរដ្ឋអាមេរិក* | 1956.5 | 1908.3 | 1512.6 | 1853.9 | 464.47 | 466.7 | 619.38 | 504.71 | 493.3 | 627.3 | 566.6 | 456.07 |
| *- សហភាពអឺរ៉ុប* | 654.3 | 689.0 | 644.7 | 809.5 | 232.0 | 301.4 | 397.5 | 391.3 | 328.4 | 504.1 | 462.7 | 421.82 |
| *- អាស៊ាន* | 3.2 | 10.76 | 6.9 | 9.9 | 3.77 | 4.18 | 4.73 | 4.95 | 6.4 | 11.7 | 11.4 | 9.76 |
| *- ជប៉ុន* | 28.5 | 25.2 | 44.5 | 86.5 | 34.3 | 28 | 43.4 | 41.25 | 50.1 | 48.9 | 47.1 | 42.47 |
| *- ប្រទេសផ្សេងៗ* | 296.4 | 352.9 | 356.5 | 463.6 | 145.9 | 163.89 | 220.68 | 187.03 | 192.5 | 282.7 | 241.3 | 210.71 |
| កសិកម្ម | 55.7 | 44.5 | 73.1 | 164.9 | 74.01 | 97.07 | 98.91 | 92.06 | 80.5 | 101.3 | 86.1 | 108.77 |
| *- កៅស៊ូ* | 41.0 | 35.8 | 51.6 | 89.1 | 49.86 | 48.6 | 56.11 | 43.06 | 40.3 | 46.4 | 46.1 | 43.84 |
| *- ឈើ* | 8.7 | 3.4 | 3.5 | 34.1 | 6.2 | 16.8 | 16.1 | 9.7 | 8.9 | 12.4 | 4.1 | 11.6 |
| *- ត្រី* | 3.2 | 2.3 | 3.9 | 2.8 | 0.6 | 0.4 | 1.4 | 0.7 | 0.5 | 0.7 | 0.4 | 0.4 |
| *- អង្ករ* | 1.5 | 2.6 | 10.9 | 34.7 | 16.9 | 30.3 | 22.4 | 37.0 | 27.1 | 37.531.7 | | 50.2 |
| *- ផលិតផលកសិកម្មផ្សេងៗ* | 1.2 | 0.5 | 3.0 | 4.1 | 0.5 | 1.0 | 2.9 | 1.6 | 3.9 | 4.4 | 3.9 | 2.8 |
| ផ្សេងៗ | 55.8 | 67.1 | 263.22 | 242.0 | 63.2 | 70.8 | 71.0 | 102.9 | 128.8 | 199.9 | 180.6 | 205.1 |
| ការនាំចូលសរុប | 3770.2 | 4272.5 | 4331.5 | 5190.6 | 1454.9 | 1690.1 | 1519.1 | 1711.9 | 1609.2 | 1885.4 | 2015.2 | 1938.2 |
| ក្នុងនេះ៖ សាំង | 73.6 | 84.8 | 91.13 | 108.6 | 62.2 | 76.7 | 73.8 | 81.8 | 70.7 | 76.7 | 78.0 | 78.8 |
| ម៉ាស៊ូត | 133.7 | 119.5 | 180.67 | 203.8 | 92.7 | 129.9 | 118.9 | 105.5 | 139.4 | 126.6 | 138.3 | 139.9 |
| សម្ភារៈសំណង់ | 44.31 | 56.3 | 49.74 | 57.6 | 11.8 | 12.7 | 11.6 | 12.0 | 13.5 | 14.1 | 16.5 | 16.6 |
| ផ្សេងៗ | 3518.5 | 4011.8 | 4010 | 4820.6 | 1288 | 1471 | 1315 | 1513 | 1386 | 1668.0 | 1782.4 | 1703.0 |
| ជញ្ជីងពាណិជ្ជកម្ម | -719.9 | -1174.7 | -1429.9 | -1560.5 | -437.2 | -558.1 | -63.5 | -387.6 | -329.1 | -642.2 | -419.4 | -483.6 |
| | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | -6.6 | 9.5 | 33.4 | -12.2 | -5.2 | -37.7 | -9.9 | -14.2 |
| ការនាំចេញសរុប | - | - | - | - | -4.9 | 11.2 | 28.6 | -9.0 | -3.3 | 38.7 | -10.1 | -8.8 |
| ការនាំចូលសរុប | - | - | - | - | 8.9 | 16.2 | -10.1 | 12.7 | -6.0 | 17.2 | 6.9 | -3.8 |
| | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 8.9 | 1.6 | -14.1 | 25.7 | 40.8 | 34.5 | 37.0 | 19.8 | 21.6 | 53.0 | 3.4 | 1.0 |
| ការនាំចេញសរុប | 8.5 | 1.6 | -6.3 | 25.1 | 46.7 | 37.9 | 39.3 | 23.7 | 25.8 | 56.9 | 9.6 | 9.9 |
| ការនាំចូលសរុប | 23.7 | 13.3 | 1.4 | 19.8 | 30.1 | 33.7 | 3.2 | 28.1 | 10.6 | 11.6 | 32.7 | 13.2 |

*Import data include tax-exempt imports. Sources: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF (web site)*

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៧-១២ (ពាន់លានរៀល)

| | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ចំណូលសរុប | 1146.1 | 5290.0 | 5988.99 | 2805.83 | 1400.46 | 1564.25 | 1510.1 | 1776.61 | 1728.9 | 2045.1 | 1900.8 | 2017.0 |
| ចំណូលចរន្ត | 1141.6 | 5210.7 | 5859.08 | 2786.12 | 1378.61 | 1563.01 | 1497.59 | 1740.12 | 1725.8 | 1928.6 | 1796.4 | 1993.1 |
| ចំណូលពន្ធ | 965.2 | 4409.9 | 4692.96 | 2457.02 | 1142.29 | 1367.52 | 1313.35 | 1454.33 | 1403.82 | 1721.8 | 1560.7 | 1648.5 |
| ពន្ធក្នុងស្រុក | 661.8 | 3248.4 | 3533.57 | 1727.10 | 875.569 | 1095.26 | 996.642 | 1104.12 | 1092.27 | 1403.4 | 1230.0 | 1277.2 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 303.5 | 1161.5 | 1159.39 | 639.00 | 266.719 | 272.27 | 316.709 | 350.207 | 311.253 | 318.4 | 330.7 | 371.4 |
| ចំណូលមិនមែនពន្ធ | 176.4 | 800.8 | 1166.13 | 507.13 | 236.329 | 195.48 | 184.23 | 285.8 | 330.98 | 206.9 | 235.7 | 344.6 |
| ចំណូលលើទ្រព្យសម្បត្តិ | 13.6 | 78.0 | 291.13 | 4.87 | 10.6426 | 18.64 | 15.19 | 19.35 | 91.28 | 13.1 | 22.5 | 16.2 |
| លក់ទំនិញ និងសេវា | 124.3 | 424.7 | 460.07 | 268.08 | 129.982 | 138.92 | 144.192 | 175.627 | 166.899 | 171.4 | 132.8 | 196.3 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 38.5 | 298.2 | 408.91 | 391.70 | 95.7053 | 37.9 | 24.856 | 90.815 | 63.8 | 22.4 | 80.5 | 132.1 |
| ចំណូលជាមូលធន | 4.5 | 79.3 | 129.92 | 2019.39 | 21.8524 | 1.25 | 12.513 | 36.486 | 3.148 | 116.4 | 104.4 | 23.9 |
| ចំណាយសរុប | 1689.7 | 6297.8 | 8784.65 | 4259.67 | 1581.62 | 2025.15 | 2310.61 | 3115.05 | 1688.33 | 2425.6 | 2951.3 | 2751.5 |
| ចំណាយជាមូលធន | 807.4 | 2574.4 | 2853.23 | 1495.19 | 579.818 | 721.01 | 801.167 | 1444.89 | 699.937 | 716.2 | 1194.5 | 1017.7 |
| ចំណាយចរន្ត | 882.3 | 3809.0 | 4773.07 | 2848.81 | 857.492 | 1304.13 | 1509.44 | 1670.15 | 988.398 | 1709.4 | 1756.7 | 1733.9 |
| បៀវត្សរ៍ | 362.6 | 1397.0 | 2048.81 | 1208.81 | 401.0 | 531.6 | 629.697 | 608.253 | 508.919 | 725.2 | 657.5 | 595.0 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 194.2 | 927.1 | 1099.42 | 613.31 | 257.356 | 450.85 | 323.282 | 487.345 | 189.594 | 514.6 | 462.1 | 420.5 |
| ចំណាយចរន្តផ្សេងទៀត | 325.5 | 1384.9 | 1624.84 | 1067.07 | 199.1 | 321.7 | 556.5 | 574.6 | 289.9 | 469.7 | 637.1 | 718.4 |
| សមតុល្យជាទូទៅ | -543.6 | -1007.8 | -2795.66 | -1453.83 | -181.2 | -460.9 | -800.5 | -1,338.4 | 196.5 | -380.6 | -1050.5 | -734.5 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 741.5 | 2055.10 | 1845.21 | 772.81 | 544.4 | 576.9 | 272.9 | 985.0 | 577.8 | 491.5 | 959.3 | 429.2 |
| ហិរញ្ញប្បទានក្នុងស្រុក | -185.8 | -127.00 | 938.64 | 567.96 | -1,745.2 | 238.7 | 312.5 | 105.6 | -565.7 | 148.4 | 22.1 | 62.4 |

*Source: MEF website.*

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៧-១២

| | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| (តុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 5.8 | 19.7 | -0.7 | 4.1 | 3.6 | 6.3 | 6.7 | 4.9 | 2.9 | 2.9 | 1.6 | 1.8 |
| - ស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 9.9 | 33.1 | -0.3 | 4.4 | 3.9 | 7.6 | 8.2 | 6.2 | 3.4 | 3.4 | 1.3 | 1.4 |
| - ដឹកជញ្ជូន | 5.8 | 19.4 | -10.7 | 7.0 | 5.0 | 7.3 | 8.8 | 6.3 | 3.0 | 3.0 | 1.1 | 1.2 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4062.7 | 4058.2 | 4140.5 | 4187.1 | 4041.9 | 4044.9 | 4095.7 | 4071.9 | 4046.0 | 4054.3 | 4060.7 | 3995.9 |
| រៀលក្នុង ១ បាតថៃ | 122.8 | 123.5 | 121.1 | 133.13 | 132.7 | 133.8 | 135.2 | 131.1 | 130.2 | 129.0 | 129.3 | 131.3 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.0 | 24.8 | 23.4 | 21.725 | 19.9 | 19.6 | 19.8 | 19.4 | 19.3 | 19.4 | 19.5 | 19.2 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 83.2 | 105.9 | 113.1 | 147.58 | 147.9 | 181.5 | 204.6 | 203.8 | 204.1 | 194.5 | 198.3 | 206.5 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 3262.3 | 4555.2 | 3170.9 | 3859.3 | 4427.2 | 4784.6 | 4924.5 | 4908.3 | 5193.9 | 4458.3 | 4983.9 | 5128.8 |
| ថ្លៃសាំង (រៀល/លីត្រ) | 4005.0 | 4750.8 | 3593.1 | 4368.1 | 4750.1 | 5065.5 | 5248.4 | 5113.8 | 5395.8 | 5308.3 | 5251.3 | 5295.4 |

*Sources: NIS, NBC and CDRI*

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៦-១២ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 7224.0 | 10,735.0 | 10,345.0 | 14,655.0 | 16,697.9 | 17,079.1 | 18,099.9 | 17,695.2 | 17,893.9 | 18,652.3 | 18,729.6 | 18,723.6 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -282.0 | 576.0 | 1513.3 | 1573.0 | 2778.9 | 3199.2 | 3907.7 | 4961.6 | 5760.8 | 6211.2 | 7922.3 | 8717.2 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -953.0 | -1816.0 | -2987.0 | -2252.0 | -2126.6 | -2252.7 | -2184.2 | -1925.8 | -2123.1 | -2542.4 | -2399.9 | -2534.2 |
| ឥណទានដល់ផ្នែកឯកជន | 3630.0 | 6386.0 | 9894.0 | 10,532.0 | 13,331.2 | 13,909.0 | 15,290.6 | 16,385.7 | 17,552.8 | 18,789.0 | 20,081.4 | 21658 |
| រូបិយវត្ថុទូទៅ M2 | 6942.0 | 11,311.0 | 11,858.0 | 16,228.0 | 19,476.8 | 20,278.3 | 22,007.6 | 22,656.8 | 23,654.7 | 24,863.5 | 26,651.9 | 27,440.8 |
| រូបិយវត្ថុ M1 | 1658.0 | 2052.0 | 2399.0 | 3120.0 | 3220.9 | 3497.2 | 3539.8 | 3681.3 | 3956.2 | 3984.6 | 3871.8 | 3861.7 |
| រូបិយវត្ថុផ្សេងៗ | 5285.0 | 9259.0 | 9459.0 | 13,108.0 | 16,255.9 | 16,781.1 | 18,467.8 | 18,975.5 | 19,698.5 | 20,878.9 | 22,780.1 | 23,579 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 38.1 | 62.9 | 4.8 | 36.9 | 20.0 | 17.7 | 20.5 | 20.0 | 21.5 | 20.2 | 21.1 | 21.2 |
| រូបិយវត្ថុ M1 | 25.3 | 23.8 | 16.9 | 30.1 | 3.2 | 11.1 | 13.6 | 20.2 | 22.8 | 11.4 | 9.4 | 7.6 |
| រូបិយវត្ថុផ្សេងៗ | 42.8 | 75.2 | 2.2 | 38.6 | 24.0 | 19.1 | 21.9 | 19.9 | 21.2 | 22.0 | 23.4 | 23.8 |

*Source: National Bank of Cambodia*

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2008 | 2009 | 2010 | 2011 | 2012 | | | | 2013 | 2012 | | 2013 |
| | | | | | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | សីហា | វិច្ឆិកា | កុម្ភៈ |
| អ្នកធាក់ស៊ីក្លូ | 12628 | 8091 | 9055 | 9532 | 9380 | 10,686 | 10,690 | 10,454 | 9588 | 8.6 | 12.5 | 2.2 |
| អ្នកលីសែង | 9005 | 9549 | 9964 | 10,785 | 10,804 | 12,713 | 12,479 | 12,574 | 2,744 | 18.5 | 9.4 | 18.0 |
| អ្នកលក់បន្លែតូចតាច | 9926 | 8273 | 8266 | 8337 | 12,292 | 9901 | 10,347 | 10,542 | 9949 | 22.4 | 49.0 | -19.1 |
| អ្នករើសអេតចាយ | 4652 | 5857 | 6698 | 8388 | 7986 | 8266 | 9139 | 9328 | 9483 | 20.2 | -9.3 | 18.7 |
| អ្នកបម្រើភោជនីយដ្ឋាន* | 4327 | 4646 | 5607 | 5986 | 6179 | 6261 | 5569 | 6436 | 6527 | 2.3 | 3.2 | 5.6 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 8697 | 6197 | 5691 | 5695 | 4690 | 6431 | 8483 | 5000 | 5828 | 14.8 | 9.9 | 23.8 |
| កម្មកររោងចក្រកាត់ដេរ | 6554 | 7085 | 7746 | 8409 | 8555 | 8391 | 9599 | 8989 | 10,000 | 9.8 | 4.7 | 16.9 |
| អ្នករត់ម៉ូតូឌុប | 15,691 | 10,685 | 10,623 | 11,568 | 12,256 | 13,616 | 12,807 | 13,042 | 14,427 | 14.2 | 1.1 | 17.7 |
| កម្មករសំណង់គ្មានជំនាញ | 8779 | 8343 | 8790 | 10,307 | 10,658 | 11,589 | 10,690 | 11,375 | 12,548 | 1.0 | 15.4 | 17.7 |
| កម្មករសំណង់មានជំនាញ | 12,710 | 12,487 | 11,952 | 13,159 | 13,824 | 12,847 | 14,029 | 14,270 | 15,156 | 10.0 | -4.4 | 9.6 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, motorcycle taxi drivers, unskilled construction workers and skilled construction workers began in February 2000. Source: CDRI*

*តពីទំព័រ ២៨* **ព័ត៌មានថ្មីៗ...**

អាទិភាពគោលនយោបាយសម្រាប់ចក្ខុវិស័យថ្មីឆ្នាំ២០៣០ របស់រដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិឆ្នាំ២០១៤-១៨។

## ផ្នែកស្រាវជ្រាវ

### *កម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ* (DGPSR)

ក្រុមស្រាវជ្រាវកំពុងអនុវត្តគម្រោងចំនួនប្រាំបួន ដែលទទួលមូលនិធិជាចម្បងពី ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិស៊ុយអែត (Sida) ហើយគម្រោងភាគច្រើនជិតឈានដល់ដំណាក់កាលបញ្ចប់ហើយ។ របាយការណ៍ស្ដីពី "អភិបាលកិច្ចតំបន់ទីក្រុងនៅកម្ពុជាក្រោយធ្វើវិមជ្ឈការ" កំពុងធ្វើការពិភាក្សា និងចងក្រងបង្ហើយដោយអ្នកនិពន្ធ និងទីប្រឹក្សាមកពីខាងក្រៅស្ថាប័ន។ របាយការណ៍សម្រេចនៃគម្រោង "អង្កេតមូលដ្ឋាននៅក្រុងភ្នំពេញ" ដែលបានចុះកិច្ចសន្យាស្រាវជ្រាវជាមួយក្រុមគាំទ្រក្រុង ស្រុក ខណ្ឌ នៃការិយាល័យច្រកចេញចូលតែមួយ (DST/OWSO) នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD) បានផ្ញើទៅឲ្យម្ចាស់ជំនួយរួចរាល់ហើយកាលពីខែមករា។ របាយការណ៍គម្រោង "វិមជ្ឈការបែបប្រជាធិបតេយ្យ និងយេនឌ័រ៖ ការវិភាគពីយេនឌ័រក្នុងគណបក្សនយោបាយនៅកម្ពុជា" កំពុងចងក្រងបញ្ចប់។ រីឯរបាយការណ៍គម្រោង "សង្គមស៊ីវិលថ្នាក់ក្រោមជាតិ នៅកម្ពុជា៖ ការវិភាគតាមទស្សនៈ Gramsci" បានយកទៅធ្វើបទបង្ហាញក្នុង សន្និសីទនៃការសិក្សាពីអាស៊ីអាគ្នេយ៍ នៅឯសាកលវិទ្យាល័យ Oxford កាលពីពាក់កណ្ដាលខែមិថុនា ហើយបច្ចុប្បន្នកំពុងចងក្រងបញ្ចប់ សម្រាប់បោះពុម្ពផ្សាយជាឯកសារពិភាក្សា។ សម្រាប់គម្រោង "ម្ភៃឆ្នាំបន្ទាប់ពីអាជ្ញាធរអ៊ុនតាក់៖ តើសង្គមស៊ីវិលកម្ពុជាបានរឹងមាំឡើងប៉ុណ្ណា?" ក្រុមអ្នកនិពន្ធកំពុងឆ្លើយតបនឹងមតិយោបល់ដែលទទួលបាន។

គម្រោង "រឿងល្អទាំងអស់ មិនមែនសុទ្ធតែដើរស្របគ្នានោះទេ៖ ការវិភាគពីភាពប្រទាំងប្រទើសគ្នារវាង ការកសាងសន្តិភាព និងប្រជាធិបតេយ្យភាវូបនីយកម្ម" ត្រូវបានអនុវត្តឡើងក្រោមកិច្ចសហការជាដៃគូជាមួយ សាកលវិទ្យាល័យ Gothenburg ដើម្បីកំណត់ពីបែបបទ និងមូលហេតុ ដែលទំនាស់បានផុសឡើង បន្ទាប់ពីមាន ឬក៏អាចកើតឡើងពី អន្តរាគមន៍ខាងកសាងសន្តិភាព។ អត្ថបទសារព័ត៌មានដំបូងផ្អែកលើគម្រោងនេះ កំពុងត្រៀមបោះពុម្ពផ្សាយ រីឯអត្ថបទទី២ អ្នកនិពន្ធក្នុងស្រុកកំពុងចងក្រងបញ្ចប់។

សម្រាប់គម្រោង"អភិបាលកិច្ចទឹកសម្រាប់កសិកម្ម៖វិមជ្ឈការអាជ្ញាធរច្រើនកម្រិត និងសហគមន៍មូលដ្ឋាន នៅអាងទន្លេសាប" ដែលជាការសិក្សាទទួលបានការទ្រទ្រង់មួយផ្នែកពី វិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី (AIT) ក្រុមស្រាវជ្រាវបានចុះសិក្សាបីវគ្គនៅកម្រិតឃុំអំពីភាពត្រឹមត្រូវនៃគម្រោង ហើយសព្វថ្ងៃកំពុងចងក្រងអត្ថបទស្ដីពីលទ្ធផលនៃការសិក្សា។ មានគម្រោងសិក្សាថ្មីពីរកំពុងរចនារៀបចំ ពោលគឺ គម្រោង "តួនាទីយុវជនកំពុងផុសឡើងនៅក្នុងសកម្មភាពនយោបាយ និងសេដ្ឋកិច្ច" ដែលសិក្សាពីតួនាទីរបស់យុវជនក្នុងការអភិវឌ្ឍផ្នែកនយោបាយ និងសេដ្ឋកិច្ចក្នុងតំបន់ ក្នុងបរិបទនៃការធ្វើវិមជ្ឈការ និងគម្រោង "វិមជ្ឈការនៅកម្ពុជា៖ តួនាទីអាជ្ញាធរមូលដ្ឋានក្នុងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់" ដែលពិនិត្យពីស្ថានភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់ នឹងតួនាទីរបស់អាជ្ញាធរមូលដ្ឋាននៅក្នុងនោះ។

### *កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់* (ETRC)

អង្កេតប្រចាំត្រីមាសលើពលករងាយរងគ្រោះ និងអង្កេតប្រចាំខែលើថ្លៃទំនិញតាមខេត្ត មានដំណើរការល្អ។ ក្រុមស្រាវជ្រាវក្នុងកម្មវិធី ETRC កំពុងចងក្រងបញ្ចប់នូវអត្ថបទវិភាគចំនួនប្រាំបី ដោយផ្អែកលើលទ្ធផលបានពីគម្រោង "វិបត្តិហិរញ្ញវត្ថុសាកល និងភាពងាយរងគ្រោះនៅកម្ពុជា" ដើម្បីចេញផ្សាយជា ឯកសារពិភាក្សារបស់វិទ្យាស្ថាន CDRI។

របាយការណ៍គម្រោង "អាស៊ានឆ្នាំ២០៣០ ដំណាក់កាលទី២៖ កំណើនទាំងអស់គ្នាដើម្បីវិបុលភាពសេដ្ឋកិច្ច - បញ្ហាប្រឈម៖ ព័ត៌មានទូទៅពីប្រទេសកម្ពុជា" បានចងក្រងរួចរាល់ និងបញ្ជូនទៅកាន់ផ្នែកពាក់ព័ន្ធនានាដើម្បីសុំមតិយោបល់។ លទ្ធផលស្រាវជ្រាវសំខាន់ៗនៃការសិក្សាស្ដីពី "ការវាយតម្លៃពីលក្ខណៈសម្រាប់គ្រប់គ្នានៃកំណើនសេដ្ឋកិច្ចកម្ពុជា៖ វិធីសាស្ត្រជួយទ្រទ្រង់ជនក្រីក្រតាមរយៈចំណូល និងកត្តាក្រៅពីចំណូល" បានយកទៅធ្វើបទបង្ហាញក្នុងសិក្ខាសាលានៃ បណ្ដាញវិភាគអភិវឌ្ឍន៍មហាអនុតំបន់មេគង្គ (GMS-DAN) កាលពីខែកុម្ភៈ ហើយរបាយការណ៍ការសិក្សានេះកំពុងចងក្រងបញ្ចប់។ របាយការណ៍សម្រេចសម្រាប់គម្រោង "តើមានឧបសគ្គអ្វីខ្លះចំពោះកំណើនសម្រាប់គ្រប់គ្នានៅកម្ពុជា?" និង "កញ្ចប់ឧស្សាហកម្ម សមាគមអាជីវកម្ម និងផលិតភាពសហគ្រាសខ្នាតតូចនិងមធ្យម (SME)៖ ភស្តុតាងបានពីអង្កេតសហគ្រាសនៅកម្ពុជា" បានបញ្ជូនរួចរាល់ទៅឲ្យ បណ្ដាញស្រាវជ្រាវ និងបណ្ដុះបណ្ដាលអាស៊ីប៉ាស៊ីហ្វិក (ARTNet)។ របាយការណ៍សម្រេចស្ដីពីគម្រោង "កម្រិត និងប្រភពចំណូលគ្រួសារនៅតំបន់ជនបទកម្ពុជា ឆ្នាំ២០១២" បានបញ្ជូនទៅឲ្យធនាគារពិភពលោករួចរាល់ ហើយបច្ចុប្បន្នកំពុងរៀបចំសម្រាប់បោះពុម្ពផ្សាយជាឯកសារពិភាក្សារបស់វិទ្យាស្ថាន CDRI។

គម្រោងស្រាវជ្រាវរយៈពេលប្រាំឆ្នាំមួយ ទទួលបានជំនួយទ្រទ្រង់ពី Sida ស្ដីពីកំណើនសម្រាប់គ្រប់គ្នា កំពុងដំណើរការទៅមុខ។ គម្រោងនេះចែកចេញជា ប្រាំអនុគម្រោង៖ ១) កំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ២) កំណើនសេដ្ឋកិច្ច វិសមភាព និងការកាត់បន្ថយភាពក្រីក្រ ៣) ការវាយតម្លៃពីភាពអំណោយផលដល់ជនក្រីក្រនៃគោលនយោបាយសារពើពន្ធ ៤) កំណើនសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការកាត់បន្ថយភាពក្រីក្រ និង ៥) មធ្យោបាយដើម្បីសម្រេចបានកំណើនសម្រាប់គ្រប់គ្នា។ អត្ថបទស្ដីពី "ឧបសគ្គរាំងស្ទះកំណើនសេដ្ឋកិច្ចនៅកម្ពុជា៖ វិធីសាស្ត្រវិភាគឧបសគ្គនៃកំណើន" ដែលជាផ្នែកមួយនៃអនុគម្រោង "កំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព" កំពុងរៀបចំបោះពុម្ពផ្សាយ

ជាឯកសារពិភាក្សារបស់ CDRI។ អត្ថបទមួយទៀតស្តីពី "ការលើកកម្ពស់ពាណិជ្ជកម្ម ដើម្បីកំណើនសេដ្ឋកិច្ចនៅកម្ពុជា" ដែលស្ថិតក្នុងអនុគម្រោង "កំណើនសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការកាត់បន្ថយភាពក្រីក្រ" បានចងក្រងរួចរាល់ដើម្បីស្នើសុំការជួយយោបល់។

### ***កម្មវិធីធនធានធម្មជាតិ និង បរិស្ថាន*** *(NRE)*

ក្រុមស្រាវជ្រាវ កំពុងអនុវត្តគម្រោងប្រាំមួយ ក្នុងនោះមានបីគម្រោងទទួលបានមូលនិធិពី Sida។ ឯកសារពិភាក្សាសម្រាប់គម្រោង "ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងជីវភាពរស់នៅក្នុងប្រទេសកម្ពុជា" កំពុងកែសម្រួលដើម្បីបោះពុម្ពផ្សាយជាឯកសារពិភាក្សារបស់ CDRI។ លទ្ធផលរកឃើញក្នុងគម្រោង "យេនឌ័រ និងអភិបាលកិច្ចទឹកៈ ការគ្រប់គ្រង និងអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ ក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ" កំពុងចងក្រងសម្រាប់បោះពុម្ពផ្សាយជាឯកសារពិភាក្សា។ សម្រាប់គម្រោង "សមត្ថភាពបន្សាំរបស់ប្រជាជនជនបទក្នុងតំបន់កសិអេកូឡូស៊ីចម្បងៗ (តំបន់ទន្លេសាប, តំបន់ភ្នំនិងខ្ពង់រាប, តំបន់មេគង្គក្រោម និងតំបន់ឆ្នេរ)" ក្រុមស្រាវជ្រាវកំពុងរៀបចំឯកសារគោលគំនិត ក្របខ័ណ្ឌស្រាវជ្រាវ និងធ្វើការសិក្សាឯកសារយោង។

ក្រុមស្រាវជ្រាវកំពុងអនុវត្តការសិក្សាពី សមិទ្ធិលទ្ធភាពសម្រាប់គម្រោង "ប្រទេសចិនឈានឡើងកម្រិតសាកលៈ ការសិក្សាប្រៀបធៀបពីទំនប់វារីអគ្គិសនីចិននៅទ្វីបអាហ្វ្រិក និងអាស៊ី" ដែលទ្រទ្រង់ដោយ ក្រុមប្រឹក្សាស្រាវជ្រាវសេដ្ឋកិច្ចនិងសង្គម (ESRC)។ នៅខែមករា សិក្ខាសាលាបំផុសគោលគំនិតសម្រាប់គម្រោង"ការប្រែប្រួលអាកាសធាតុនិងអភិបាលកិច្ចទឹកនៅកម្ពុជា" ដែលទ្រទ្រង់ដោយ មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) បានដំណើរការនៅសណ្ឋាគារកាំបូឌីយ៉ាណា ក្រុងភ្នំពេញ។ ផែនការស្រាវជ្រាវសម្រាប់ការសិក្សាតូចៗចំនួន ៥ បានរៀបចំឡើង និងដាក់អនុវត្ត។ សម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធនានាបានចប់សព្វគ្រប់សម្រាប់គម្រោង "វិធីសាស្ត្រជាក់ស្តែង ដើម្បីជួយទ្រទ្រង់សមត្ថភាពប្រកួតប្រជែងនៃ ប្រទេសមានចំណូលទាប/មធ្យមកម្រិតទាប នៅក្នុងពិភពលោកក្រោមការដាក់កំហិតផ្នែកកាបូន" ដែលជាគម្រោងសហការគ្នាជាមួយ វិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេស (ODI) ។ ក្រុមស្រាវជ្រាវកំពុងវិភាគទិន្នន័យ និងរៀបចំចងក្រងអត្ថបទសង្ខេបប្រចាំប្រទេសកម្ពុជាស្តីពី"ទេសចរណ៍កម្មន្តសាលកម្ម និងថាមពលៈ ឱកាស បញ្ហាប្រឈម និង ការពាក់ព័ន្ធផ្នែកនយោបាយនៅកម្ពុជា" ដោយរួមសហការជាមួយ ODI។ សិក្ខាសាលាផ្សព្វផ្សាយព័ត៌មានមួយ គ្រោងរៀបចំឡើងក្នុងខែមេសា។

ក្រុមស្រាវជ្រាវក្នុងកម្មវិធីនេះ បានដាក់ស្នើឡើងនូវគម្រោងស្រាវជ្រាវចំនួនបី ហើយកំពុងរង់ចាំលទ្ធផលអំពី ១) គណៈកម្មការបញ្ជាក់កម្រិតស្តង់ដារ អង្គភាពស្ថាបនីតិសម្បទា/ទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ (CARF/AusAID) សម្រាប់គម្រោង"ការចិញ្ចឹមត្រីខ្នាតតូច"២) អង្គការសហភាពអឺរ៉ុប សម្រាប់គម្រោង "ការដោះស្រាយបញ្ហាសង្គមកិច្ច បរិស្ថាន និងអភិវឌ្ឍន៍តាមរយៈទំនួលខុសត្រូវផ្នែកសង្គមកិច្ចជាសាកល របស់ក្រុមហ៊ុន (SEED-CSR)" ដែលជាកិច្ចសហការស្រាវជ្រាវរវាង កម្មវិធីអភិវឌ្ឍសង្គមនៃ CDRI និងសាកលវិទ្យាល័យ Nottingham Ningbo China និង ៣) ADB សម្រាប់គម្រោង "អង្កេត និងករណីសិក្សាលើ ការយល់ឃើញពីការប្រែប្រួលអាកាសធាតុ និងអាទិភាពនៃការបន្សាំខ្លួន ក្នុងមជ្ឈដ្ឋានអ្នកធ្វើផែនការធនធានទឹក និងអ្នកបង្កើតគោលនយោបាយនៅកម្ពុជា"។

ដើម្បីជួយទ្រទ្រង់ដល់កិច្ចប្រឹងប្រែងសហការគ្នា រវាងកម្មវិធីនានា អ្នកស្រាវជ្រាវក្នុងកម្មវិធី NRE បានជួយដល់គណៈកម្មការរៀបចំសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៣ ដោយចូលរួមកត់ត្រាខ្លឹមសារលើកឡើងក្នុងសន្និសីទ និងតាក់តែងអត្ថបទសង្ខេបចក្ខុវិស័យ។

### ***កម្មវិធីភាពក្រីក្រ កសិកម្ម និង អភិវឌ្ឍន៍ជនបទ*** *(PARD)*

ក្រុមស្រាវជ្រាវកំពុងអនុវត្តគម្រោងសិក្សាចំនួនប្រាំ។ របាយការណ៍សំយោគសម្រាប់គម្រោង "ការសិក្សាពីការរួមចំណែកនៃសេវាកម្មក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីកែលំអទំនាក់ទំនងខាងឧស្សាហកម្មនៅកម្ពុជាៈ ករណីរោងចក្រកាត់ដេរ" បានបញ្ជូនទៅឲ្យអង្គការមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលរួចរាល់ ហើយបច្ចុប្បន្ន ក្រុមស្រាវជ្រាវកំពុងឆ្លើយតបនឹងមតិយោបល់ទទួលបាន។ សម្រាប់គម្រោង "ការកសាងគោលនយោបាយកសិកម្មសម្រាប់ប្រព័ន្ធកសិកម្មផ្អែកលើដំណាំស្រូវនៅកម្ពុជា និងឡាវ" របាយការណ៍ករណីសិក្សាពី ឥណទានកសិកម្ម ខ្សែចង្វាក់តម្លៃដី និងខ្សែចង្វាក់តម្លៃអង្ករ បានបញ្ជូនទៅឲ្យម្ចាស់ជំនួយរួចរាល់ ហើយរបាយការណ៍សម្រេចលើ ករណីសិក្សាពីការធ្វើកសិកម្មតាមកិច្ចសន្យា កំពុងតែចងក្រងឡើង។ ករណីសិក្សាទាំងនេះ គ្រោងបោះពុម្ពផ្សាយជាបួនជំពូកនៅក្នុងសៀវភៅមួយរបស់មជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR) មានចំណងជើងថា "គោលនយោបាយ និងការអនុវត្តជាក់ស្តែងៈ ការប្រើភស្តុតាងបានពីការសិក្សាដល់កន្លែង ដើម្បីផ្តល់ព័ត៌មានដល់ការកំណត់គោលនយោបាយស្រូវនៅតំបន់មេគង្គ" ដែលគ្រោងចេញផ្សាយនៅពាក់កណ្តាលឆ្នាំ២០១៣។ ក្របខ័ណ្ឌទស្សនទាន និងឧបករណ៍សម្រាប់ធ្វើការស្រាវជ្រាវ នៃគម្រោងទទួលជំនួយហិរញ្ញវត្ថុពី Sida ស្តីពី "ផលប៉ះពាល់នៃការធ្វើកសិកម្មតាមកិច្ចសន្យា ទៅលើជីវភាពរស់នៅរបស់ម្ចាស់ដីតូចៗ" បានរចនារៀបចំរួចជាស្រេច។ ក្រុមស្រាវជ្រាវគម្រោង "ការសិក្សាកំណត់គោលដើមនៃកម្មវិធីការជួយដោះស្រាយបញ្ហានៃភាពងាយរងគ្រោះនៅតាមជនបទ និងស្ថិរភាពនៃប្រព័ន្ធអេកូឡូស៊ី (HARVEST) ផ្តល់ហិរញ្ញប្បទានដោយ USAID" បានបញ្ចប់ការវិភាគទិន្នន័យ និងកំពុងរៀបចំចងក្រងជារបាយការណ៍។

### ***កម្មវិធីអភិវឌ្ឍន៍សង្គម*** *(SD)*

កម្មវិធីនេះ កំពុងដំណើរការគម្រោងធំៗបី។ គម្រោង "ការកសាងប្រព័ន្ធសុខាភិបាលអំណោយផលដល់ជនក្រីក្រ ក្នុងពេលកសាងប្រទេសឡើងវិញបន្ទាប់ពីបានបញ្ចប់ទំនាស់" ទទួលបានជំនួយទ្រទ្រង់ពី ក្រសួងអភិវឌ្ឍន៍អន្តរជាតិ (អង់គ្លេស) (DFID) និងចែកចេញជា បីអនុគម្រោង គឺមាន ហិរញ្ញប្បទានផ្នែកសុខាភិបាល, ធនធានមនុស្សផ្នែកសុខាភិបាល និងការចុះកិច្ច

សន្យាលើការផ្ដល់សេវាសុខាភិបាល។ បន្ទាប់ពីគម្រោងដំណើរការបានពាក់កណ្ដាលពេលកំណត់ ក្រុមស្រាវជ្រាវធ្វើការបូកសរុបលទ្ធផលការងារសម្រេចបានមកទល់បច្ចុប្បន្ន និងត្រៀមរៀបចំអនុវត្តដំណាក់កាលបន្ទាប់ទៀត។ គម្រោងស្រាវជ្រាវរយៈពេលពីរឆ្នាំ ស្ដីពី "ការសិក្សាពីពលកម្មកុមារ" ចែកចេញជា បួនអនុគម្រោង ក្នុងនោះមានពីរបានចាប់អនុវត្តក្នុងខែមករា គឺមាន "ការងារក្នុងផ្ទះ របស់កុមារ" និង "ផលប៉ះពាល់លើពលកម្មកុមារនៃចំណាកស្រុកមនុស្សពេញវ័យ"។ ការសិក្សានេះជាផ្នែកមួយនៃ គម្រោងរយៈពេល ៤ឆ្នាំ មានឈ្មោះថា "Cambodians-EXCEL" របស់អង្គការទស្សនៈពិភពលោកកម្ពុជា ដែលទទួលបានហិរញ្ញប្បទានពី ក្រសួងការងាររបស់សហរដ្ឋអាមេរិក។ ឯកសារគោលគំនិតសម្រាប់អនុគម្រោង "ភាពជាដៃគូរវាងវិស័យឯកជន និងរដ្ឋ ដើម្បីផ្ដល់ការអប់រំបណ្ដុះបណ្ដាលផ្នែកបច្ចេកទេសនិងវិជ្ជាជីវៈ (TVET)" ដែលទ្រទ្រង់ដោយ Sida បានចងក្រងចប់សព្វគ្រប់ ហើយក្រុមស្រាវជ្រាវកំពុងធ្វើការសិក្សាលើឯកសារយោង។ បច្ចុប្បន្នក្រុមស្រាវជ្រាវក្នុងកម្មវិធីSDកំពុងអនុវត្តគម្រោងពីរគឺ"ការត្រួតពិនិត្យពីលទ្ធផលផ្នែកអនាម័យនៅកម្ពុជា" និង "ការវាយតម្លៃផលប៉ះពាល់នៃគម្រោងផ្ដល់មូលនិធិដោយ CARF"។ មានសំណើស្រាវជ្រាវជាច្រើនត្រូវបានរៀបចំ និងដាក់ស្នើឡើង ហើយក្នុងនោះមាន សំណើមួយសម្រាប់គម្រោង ReBUILD និងសំណើផ្សេងៗទៀតសម្រាប់ការស្រាវជ្រាវអំពី ទំនួលខុសត្រូវផ្នែកសង្គមកិច្ចរបស់ក្រុមហ៊ុនចិន និងអាហារូបត្ថម្ភកុមារ។

---

*តពីទំព័រ ១៧* **វិសមភាពយេនឌ័រ...**


CDRI–Cambodia Development Resource Institute (forthcoming), *Impact Assessment of Farmer Organisation on Food Security of the Rural Poor,* CDRI Working Paper (Phnom Penh: CDRI)

Chea Saint Dona (2010), *Final Report on Policy Analysis for Farmer Organisation Development, Department of Agricultural Extension* (Phnom Penh: MAFF, sponsored by IFAD and FAO)

Couturier Julie, Savun Sam Ol& Ham Phalla (2006), "Inventory of Farmer Organisations in Cambodia, Cambodia", report prepared for Department of Agricultural Extension, Phnom Penh

NIS–National Institute of Statistics (2011), *National Accounts of Cambodia 1993-2011* (Phnom Penh: Ministry of Planning)

NIS–National Institute of Statistics (2009), *Population Census of Cambodia 2008* (Phnom Penh: Ministry of Planning)

NIS–National Institute of Statistics (2012), *Cambodia Socio-Economic Survey 2011* (Phnom Penh: Ministry of Planning)

Nou Keosothea (2006), "Emerging Structure of Agricultural Cooperatives in Cambodia", *Cambodia Development Review,* Vol.10 (1) (Phnom Penh: CDRI) pp.9-12

Tong Kimsun (2011), "Land Tenure and Paddy Productivity: Evidence from Rural Cambodia", *Annual Development Review 2010-2011* (Phnom Penh: CDRI) pp.143-155



## Cambodia Development Review—2013 Subscription Rates

**Domestic Subscription (Individual)**

❒ English edition ($14) ❒ Khmer edition (5,000 riels) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❒ English edition ($60 for five copies) ❒ Khmer edition (20,000 riels for five copies) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges). Total payment enclosed..........

**International Subscription (Individual)**

| | | |
|---|---|---|
| ❒ Thailand, Laos, Vietnam | ❒ English edition ($25)* | ❒ Khmer edition ($15)* |
| ❒ Asia and Europe | ❒ English edition ($30)* | ❒ Khmer edition ($20)* |
| ❒ Americas and Africa | ❒ English edition ($35)* | ❒ Khmer edition ($25)* |

**Details for payment by telegraphic transfer**

| | |
|---|---|
| Account Name: | CDRI |
| Account Number: | 133451 |
| Bank Name: | ANZ Royal Bank (Cambodia) Ltd |
| Bank Address: | Phnom Penh, Cambodia Head Office |
| Swift Code: | ANZBKHPP |
| Receiver Correspondent Bank: | JP Morgan Chase Manhattan Bank, N.A., New York, USA<br>Swift Code: CHASUS33 |

Title: ❒Mr ❒Ms ❒Dr ❒ Other ..........

First name: .......... Last name: .......... Position: ..........

Organisation / Company: ..........

Address (CCC Box if applicable): ..........

City / Province: .......... Country: ..........

Telephone: .......... Fax: ..........

e-mail: .......... ❒ Tick to receive regular information about CDRI publications via e-mail

To subscribe, please fill in this form and return it to CDRI with your payment. Do not send cash through the post.
You will need to inform the Publishing Department at CDRI if your contact details change.

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ព្រឹត្តិការណ៍សំខាន់ៗ

នៅដើមខែកុម្ភៈ ២០១៣ បណ្តាញវិភាគអភិវឌ្ឍន៍មហាអនុតំបន់មេគង្គ (GMS-DAN) សម្របសម្រួលដោយ វិទ្យាស្ថាន CDRI និងទ្រទ្រង់ដោយ មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិកាណាដា (IDRC) និងមូលនិធិ Rockefeller បានធ្វើសិក្ខាសាលាបច្ចេកទេសមួយនៅទីក្រុងដាណាង ប្រទេសវៀតណាម លើគម្រោងបច្ចុប្បន្នរបស់ខ្លួនស្តីពី កំណើនសម្រាប់គ្រប់គ្នាក្នុង GMS ដោយមានវគ្គមួយស្តីពីការធ្វើផែនការពីទិសដៅទៅអនាគត។

សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៣ ដែលជាកិច្ចសហការជាដៃគូរវាង CDRI និងធនាគារ ANZ Royal បានប្រារព្ធឡើងនៅទីក្រុងភ្នំពេញ កាលពីថ្ងៃពុធ ទី២០ កុម្ភៈ ២០១៣ ក្រោមប្រធានបទ "ការពង្រឹងអនាគតប្រទេសកម្ពុជា៖ ស្បៀងអាហារ ថាមពល និងធនធានធម្មជាតិ" ។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ជាថ្មីម្តងទៀត ដោយអញ្ជើញជាអធិបតី និងថ្លែងសុន្ទរកថាគន្លឹះបើកសន្និសីទដែលមានភ្ញៀវកិត្តិយសប្រមាណ ៤០០នាក់ ជាថ្នាក់ដឹកនាំមកពីខាងរដ្ឋាភិបាល វិស័យឯកជន អង្គការអន្តរជាតិ និងសហគមន៍ស្រាវជ្រាវ។ កម្មវិធីរួមមាន វគ្គស្តីពី ការពង្រឹងអនាគតប្រទេសកម្ពុជា- សូចនាករ ការរំពឹងទុក និងអាទិភាពគោលនយោបាយ, ការពង្រឹងកំណើនប្រកបដោយចីរភាពនៅកម្ពុជា- ថាមពល និងហេដ្ឋារចនាសម្ព័ន្ធ, និងសន្តិសុខស្បៀងអាហារ និងការអភិវឌ្ឍវិស័យកសិកម្ម- មូលដ្ឋានគ្រឹះនៃកំណើនសម្រាប់គ្រប់គ្នា និងការអភិវឌ្ឍប្រកបដោយចីរភាព។ អត្ថបទសង្ខេបចក្ខុវិស័យកម្ពុជាមួយឃុតបង្ហាញពីបញ្ហាសំខាន់ៗ និងអនុសាសន៍គោលនយោបាយបានមកពីសន្និសីទចក្ខុវិស័យ ព្រមទាំង កម្មវិធី និងបទបង្ហាញផ្សេងៗក្នុងសន្និសីទ អាចស្វែងរកបានក្នុងវេបសាយ CDRI ។

កិច្ចប្រជុំពេញអង្គប្រចាំឆ្នាំនៃក្រុមប្រឹក្សាភិបាលរបស់ CDRI ដែលមានឯកឧត្តម បណ្ឌិត សុក ស៊ីផាន់ណា ជាប្រធាន បានប្រព្រឹត្តិទៅកាលពីថ្ងៃទី២១ កុម្ភៈ ២០១៣។ ក្រុមប្រឹក្សាភិបាលបានអនុម័តយល់ព្រមលើគោលនយោបាយកៀងគរធនធន និងគោលនយោបាយបំពេញចិត្តបុគ្គលិករបស់ CDRI សម្រាប់អនុវត្តក្នុងឆ្នាំ២០១៣។ តាងនាមឲ្យ CDRI លោកប្រធានក្រុមប្រឹក្សាភិបាលបានថ្លែងអំណរគុណដល់ សមាជិកក្រុមប្រឹក្សាភិបាលពីររូបដែលបានបំពេញការងារជាយូរឆ្នាំរហូតដល់ចប់អាណត្តិគឺ លោកស្រី ប៉ុក បញ្ញាវិចិត្រ និង លោកស្រី Carol Strickler។ ក្នុងឱកាសពិសារអាហារថ្ងៃត្រង់រួមគ្នារវាង ក្រុមប្រឹក្សាភិបាល និងបុគ្គលិក CDRI មានការផ្តល់រង្វាន់ប្រចាំឆ្នាំដល់អ្នកស្រាវជ្រាវមានស្នាដៃល្អ ក្នុងគម្រោងមួយចំនួនដែលបានចប់សព្វគ្រប់នៅឆ្នាំ២០១២គឺមានការវាយតម្លៃពីផលប៉ះពាល់នៃអង្គការកសិករទៅលើ សន្តិសុខស្បៀងសម្រាប់ប្រជាជនក្រីក្រ, ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសកលទៅលើទីផ្សារពលកម្មនៅកម្ពុជា, អង្គការមិនមែនរដ្ឋាភិបាល និងស្រមោលនៃសង្គមស៊ីវិលនៅកម្ពុជា។

នៅខែមីនា ២០១៣ ឯកឧត្តម ម៉ី កល្យាណ បានបន្តវេណពីឯកឧត្តម ហង់ ជួន ណារ៉ុន ធ្វើជាប្រធានគណៈកម្មាធិការដឹកនាំការងារនៃវេទិកាស្រាវជ្រាវអភិវឌ្ឍន៍ជំហាន ២ ដែលជាកិច្ចសហការជាដៃគូររវាងវិទ្យាស្ថាន CDRI, វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល, សមាគមសេដ្ឋកិច្ចកម្ពុជា, វិទ្យាស្ថានជាតិសុខភាពសាធារណៈ, ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, និង សកលវិទ្យាល័យភូមិន្ទកសិកម្ម។

កាលពីថ្ងៃទី ២៨-២៩ មីនា លោកនាយកប្រតិបត្តិ និងលោកប្រធានផ្នែកស្រាវជ្រាវរបស់ CDRI បានចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលធ្វើឡើងដោយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) នៅឯខេត្តកំពង់ចាម ដើម្បីសុំការចូលរួមផ្តល់គំនិតពីដៃគូអភិវឌ្ឍន៍នានារបស់កម្ពុជា និងបណ្តាស្ថាប័នស្រាវជ្រាវក្នុងស្រុក អំពី

(តទៅទំព័រ ២៥)

ទស្សនាវដ្តី
អភិវឌ្ឍន៍កម្ពុជា
ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ឆ្នាំទី១៧ លេខ១ ខែមីនា ឆ្នាំ២០១៣

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរការនៃសេដ្ឋកិច្ចប្រទេសកម្ពុជា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន។ លិខិត ត្រូវចុះហត្ថលេខាអាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន។ អ្នកនិពន្ធ ត្រូវទាក់ទងវិទ្យាស្ថាន CDRI មុននឹងផ្តល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ព។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល។

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
☛ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
☒ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ 🖷 (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@cdri.org.kh
website: http://www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយ: វបសអ
គ្រប់គ្រងកែសំរួល: យូ សិទ្ធិរិទ្ធ
កែសំរួលផលិតកម្ម: អ៊ុំ ចាន់ថា និង ម៉េន ច័ន្ទធីតា
ជំនួយការកែសំរួល: ខេង សេង
សហគ្រាសបោះពុម្ព សាលាបច្ចេកទេសដុនបូស្កូ ភ្នំពេញ រូបភាពទំព័រមុខ: រូបភាព វបសអ

© រក្សាសិទ្ធិ ២០១៣ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វិទ្យាស្ថានCDRI ឡើយ។

ISSN 1560-7615 / ISBN 978-99950-52-06-5

គំនិត ការលើកពីហេតុការណ៍ និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់អ្នកនិពន្ធ។ ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ វិទ្យាស្ថាន CDRI ទេ។

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្តល់ជូនដោយឥតគិតថ្លៃតាមរយៈគេហទំព័រ www.cdri.org.kh